ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត




◆ តើនៅពេលណាទើបមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមត្រូវកាត់ទោស?

◆ ការសម្រេចយកនូវការកាត់ទោសដ៏សមរម្យមួយសម្រាប់ ឌុច

◆ ការសួរនាំឪពុកម្តាយអំពីរបបខ្មែរក្រហមដែលគាត់ធ្លាប់បានឆ្លងកាត់ គឺជាការលើកទឹកចិត្តដល់ឪពុកម្តាយ ដែលខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាយើងរហូតមកដល់សព្វថ្ងៃ ហើយអាចឈានទៅរកការផ្សះផ្សាជាតិមួយផងដែរ។

◆ ការរៀបរាប់ប្រាប់ដល់កូនចៅអំពីរបបខ្មែរក្រហម គឺជាការអប់រំកូនចៅឱ្យសាងតែអំពើល្អ ចេះអត់ឱន អធ្យាស្រ័យគ្នានៅក្នុងសង្គមមួយដែលបានបាក់បែក ប្រេះស្រាំ ហើយដែលកំពុងត្រូវស្តាបនានិងកសាងឡើងវិញ។

◆ ការសួរនាំឪពុកម្តាយ ឬការរៀបរាប់ប្រាប់ដល់កូនចៅអំពីរបបខ្មែរក្រហម គឺជាការទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឱ្យកើតឡើងសាជាថ្មីម្តងទៀតនៅកម្ពុជា និងនៅគ្រប់ទីកន្លែងទាំងអស់ទូទាំងសាកលលោក។


ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១២០ ខែធ្នូ ឆ្នាំ២០០៩

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១២០ ខែធ្នូ ឆ្នាំ២០០៩

## មាតិកា

◆តើនៅពេលណាទើបមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ........................................១

**ផ្នែកឯកសារ**

◆ជីវិតនារីពេទ្យនៅក្នុងសម័យខ្មែរក្រហម........................................២

◆ជនជាតិចាមនៅភូមិស្វាយឃ្លាំង ........................................៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ដើមបណ្ដឹងរដ្ឋប្បវេណីចែករំលែករឿងរ៉ាវទុក្ខសោក ..............................៧

◆តើជនរងគ្រោះអាចអត់ឱនទោសដល់កម្មាភិបាល ..............................១០

◆ទួលស្លែង និង មន្ទីរស-២១ ........................................១៣

◆ដេវីដ ឆេនដល័រ សាក្សីដ៏មានជំនាញ........................................១៥

◆វេទិកាពិភាក្សាកម្រិតមូលដ្ឋាន ៖ ភូមិស្វាយឃ្លាំង..............................១៨

**ផ្នែកច្បាប់**

◆កំហុសរបស់មេធាវីការពារក្តី........................................២២

◆ការចោទប្រកាន់អំពើពុករលួយដែលពុំមានភស្តុតាងនៅ........................៣២

◆ការសម្រេចយកនូវការកាត់ទោសដ៏សមរម្យមួយសម្រាប់ ឌុច..............៣៩

**វេទិកាពិភាក្សាសាធារណៈ**

◆វិធីទៅរកការផ្សះផ្សានៅកម្ពុជា ........................................៤៥

◆ការអនុវត្តនៃការទទួលខុសត្រូវថ្នាក់លើរបស់មេដឹកនាំស៊ីវិល............៥០

◆ស្ត្រីនៅប្រទេសកម្ពុជា ៖ សង្កេតទៅលើឋានៈស្ត្រីខ្មែរ.......................៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ក្លាយជាអ្នកទោសនៅកោះមុខឈ្នាង ........................................៥៩



នួន ជា



ខៀវ សំផន



អៀង សារី



អៀង ធីរិទ្ធ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ ៖*** *ដា ធីតា, មីសែល សាលីបា, ម៉ែន ពិចិត្រ, ដេវីដ ឆេនដល័រ, រ៉េនដល ឌើហ្វាល់កូ, អាដាម ខូឌី, អេលីហ្សាបែត នៀលសែន, ឆាល ជេគសាន់, អាន នីវ៉ូស៊ីកា វ៉ាស, រីហាន អាបេយរ៉េនី, ម៉ាក់ អាដាម និង ទា ឡុង* ***អ្នកនិពន្ធនិងស្រាវជ្រាវ ៖*** *គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា, ទេស ម៉ារ៉ែម* ***អ្នកបកប្រែៈ*** *ដា ដល្លា, ទែន សុខស្រីនិត* ***និពន្ធនាយកខ្ទង់ៈ*** *ឆាំង យុ* ***ជំនួយការនិពន្ធនាយកៈ*** *ទេព ម៉េងឃាន និង ញាណ សុជាតិ* ***ក្រាហ្វិកកុំព្យូទ័រៈ*** *ស៊ឹម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយៈ*** *ម៉ម សុផាត*

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# តើនៅពេលណាទើបមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមត្រូវកាត់ទោស?

## សារសំខាន់នៃករណី០០២

កាលពីសប្តាហ៍មុន អង្គជំនុំជម្រះវិសាមញ្ញដែលទទួលភារកិច្ចក្នុងការកាត់ទោសចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បានចេញសេចក្តីសម្រេចចុងក្រោយចំពោះករណី ០០១។ ករណីនេះ ផ្តោតការស៊ើបអង្កេតចំពោះ ឌុច (ឬ កាំង ហ្គិចអ៊ាវ) ជាប្រធានគុកស-២១ ដែលមានមនុស្សប្រមាណ ១៤,០០០នាក់ ត្រូវបានបង្ខំឲ្យផ្តល់ចម្លើយសារភាព ដោយការធ្វើទារុណកម្ម និងបន្ទាប់មកត្រូវបានសម្លាប់។ ក្នុងនាមជាមន្ទីរសន្តិសុខធំបំផុតរបស់ខ្មែរក្រហម ភាគច្រើនគឺកម្មាភិបាលខ្មែរក្រហមផ្ទាល់និងបក្សជនជាច្រើនទៀតត្រូវបានយកមកដាក់ឃុំឃាំងនៅទីនោះ។ ពេញមួយរយៈកាលនៃការធ្វើសវនាការ ឌុច មិនបានបង្ហាញអំពីវិប្បដិសារីចំពោះអំពើរបស់ខ្លួនសោះឡើយ ដែលផ្ទុយស្រឡះពីកាលដែល ឌុច បានសុំខមាទោសពីសំណាក់សាធារណជនតាំងពីការចាប់ផ្តើមសវនាការដំបូង កាលពីខែកុម្ភៈនោះ។ ជាការពិតណាស់ ជនរងគ្រោះជាច្រើនសម្លឹងឃើញការសុំខមាទោសនោះដោយការងឿងឆ្ងល់ ហើយអ្នកជំនាញជាច្រើនក៏ឃើញថាវាគ្រាន់តែជាវិធីសាស្ត្រមួយសម្រាប់បន្ធូរបន្ថយទោសតែប៉ុណ្ណោះ។ ចំណាប់អារម្មណ៍ចុងក្រោយរបស់ ឌុច កាលពីសប្តាហ៍មុនបញ្ជាក់យ៉ាងច្បាស់ចំពោះភាពស្រពិចស្រពិលនេះ និងការប៉ុនប៉ងរបស់ខ្លួនក្នុងការប្រើប្រាស់សាលាក្តីជាការតស៊ូចុងក្រោយចំពោះការជឿជាក់របស់ខ្លួនទៅលើបដិវត្តន៍ខ្មែរក្រហម។ ពាក្យសម្តីនិងគំនិតរបស់ ឌុច នៅតែបង្ហាញយ៉ាងច្បាស់អំពីភាពឃោរឃៅមិនមែនជាមនុស្សនៅក្នុងក្រសែភ្នែកជនរងគ្រោះ ហើយអត្តចរិតរបស់ឌុចក៏មិនបានផ្លាស់ប្តូរអ្វីសូម្បីតែបន្តិច។ អង្គជំនុំជម្រះវិសាមញ្ញគួរដាក់ទោស ឌុច អតីតមេគុកទួលស្លែង (ស-២១) ដោយដាក់គុកអស់មួយជីវិត។ នៅក្នុងគុក ឌុច ត្រូវអានចម្លើយសារភាពទាំងអស់ដែលមាននៅសារមន្ទីរទួលស្លែង។ អានហើយត្រូវទន្ទេញឲ្យចាំទាំងអស់។ ករណីបន្ទាប់របស់តុលាការនេះគឺករណី០០២ ដែលមានសារសំខាន់ខ្លាំងណាស់ ទាំងផ្នែកនយោបាយនិងប្រវត្តិសាស្ត្រ ដោយសារករណីនេះនឹងធ្វើការស៊ើបអង្កេតលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំនួន៤រូប ដែលនៅរស់រានមានជីវិតដល់បច្ចុប្បន្ននេះគឺនួនជា អៀងសារី អៀងធិរិទ្ធ និងខៀវ សំផន។ មានសំនួរជាច្រើនទាក់ទងនឹងការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យដែលមានរយៈកាល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ មិនទាន់បានទទួលចម្លើយនៅឡើយទេ។ អ្នកដឹកនាំជាន់ខ្ពស់ទាំងនេះមិនបានទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មណាមួយដែលបានប្រព្រឹត្តឡើងនៅក្នុងរបបនេះឡើយ ផ្ទុយទៅវិញថែមទាំងទម្លាក់កំហុសទៅលើកម្មាភិបាលថ្នាក់ក្រោម និងមនុស្សផ្សេងទៀតទៅវិញ។ ប៉ុន្តែមានឯកសារជាច្រើនដែលបង្ហាញអំពីទោសកំហុសរបស់ជនទាំងនេះដែលមានដូចជាឯកសារដ៏សន្ធឹកសន្ធាប់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាបញ្ជាក់យ៉ាងលម្អិតអំពីសកម្មភាព និងមានសាក្សីជាច្រើនទៀតដែលអាចផ្តល់សក្ខីកម្មចំពោះការបង្កើត និងការដាក់អនុវត្តនូវសកម្មភាពរបស់ជនទាំងនេះ។ ដូច្នេះហើយតុលាការនេះផ្តល់ឱកាសដ៏មានសារសំខាន់ដើម្បីបើកចំហរនិងវិភាគថាតើមេដឹកនាំទាំងនេះសម្រេចសេចក្តីយ៉ាងណា ដែលបណ្តាលឲ្យមនុស្សជិតពីរលាននាក់ត្រូវបាត់បង់ជីវិតនោះ។ ករណី០០២នេះ នឹងផ្តល់នូវចម្លើយចំពោះចម្ងល់ជាច្រើនទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យដែលជនរងគ្រោះបានរង់ចាំអស់រយៈពេលជាយូរមកហើយនោះ។ លើសពីនេះទៅទៀត ករណីនេះដែរក៏នឹងផ្តល់នូវយុត្តិធម៌និងការធូរស្បើយចំពោះការឈឺចាប់ និងទុក្ខវេទនាទាំងឡាយរបស់ជនរងគ្រោះកម្ពុជាតាមរយៈការដាក់ទោសចំពោះបុគ្គលដែលត្រូវទទួលខុសត្រូវទាំងនេះ។ **ឆាំង យុ**

# ជីវិតនារីពេទ្យនៅក្នុងសម័យខ្មែរក្រហម

បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ របស់លោកសេនាប្រមុខ លន់ នល់ នៅឆ្នាំ១៩៧០ មានប្រជាជនខ្មែរមួយចំនួនបានចុះចូលជាមួយនឹងខ្មែរក្រហមដើម្បីតស៊ូប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ ដោយសារយល់ឃើញថា មានតែរបបរាជានិយមទេដែលស័ក្តិសមនឹងប្រទេសកម្ពុជាព្រោះរបបនេះមានតាំងពីយូរយារណាស់មកហើយ ជារបបដែលគ្មានអំពើពុករលួយការជិះជាន់ ការកេងប្រវ័ញ្ចនិងការគាបសង្កត់ ។ ជាក់ស្តែង អឿង ផាន ដែលជាយុទ្ធនារីមួយរូបនៅក្នុងសម័យនោះបានសម្រេចចិត្តរត់ចូលក្នុងព្រៃធ្វើជាគ្រូពេទ្យម្នាក់ដើម្បីព្យាបាលជំងឺឲ្យប្រជាជននិងកងទ័ពនៅក្នុងខេត្តកំពង់ស្ពឺ ។

ដោយសាររដ្ឋប្រហារទម្លាក់ សម្តេច សីហនុ នៅឆ្នាំ១៩៧០ ផាន ក៏បានសម្រេចចិត្តបោះបង់ចោលការសិក្សាត្រឹមថ្នាក់ទី១០នៅសាលាបន្ទាយខ្មែរមកជួយធ្វើការឪពុកម្តាយនៅផ្ទះ ។ រហូតមកដល់ឆ្នាំ១៩៧២ ផាន បានចាកចេញពីផ្ទះទៅរស់នៅក្នុងព្រៃដើម្បីធ្វើជាគ្រូពេទ្យព្យាបាលជំងឺកងទ័ពនៅក្នុងខេត្តកំពង់ឆ្នាំង ស្ថិតក្នុងកងពលទី១ ក្រោមការគ្រប់គ្រងរបស់ សឿង ជាប្រធានកងពល ។ នៅទីនោះ ផាន គ្រាន់តែជាសិស្សពេទ្យស្រីម្នាក់ដែលត្រូវបានគេបង្ហាត់បង្រៀនពីរបៀបវះកាត់និងជាជំនួយការដើរចល័តតាមសមរភូមិប៉ុណ្ណោះ ប៉ុន្តែមិនទាន់អនុវត្តការងារជាក់ស្តែងនៅឡើយទេ ។

នៅក្នុងឆ្នាំ១៩៧៦ ផាន ត្រូវបាន សឿង ដែលជាប្រធានកងពលទី១ផ្លាស់ឲ្យទៅធ្វើការនៅមន្ទីរពេទ្យក្រុងលង្វែកវិញ ។ នៅក្នុងមន្ទីរពេទ្យនោះ ផាន មានតួនាទីមើលថែទាំទារកប្រហែល ៣០នាក់ ដែលមានអាយុចាប់ពីមួយឆ្នាំឡើងទៅព្រោះឪពុកម្តាយរបស់ក្មេងទាំងនោះត្រូវចេញទៅធ្វើការនៅតាមអង្គភាព ។ ក្រៅពីការងារទាំងនេះ ផាន ជួយសម្រាលកូនឲ្យអ្នកដទៃនិងព្យាបាលជំងឺប្រជាជននិងកងទ័ពដែលមកសម្រាកនៅទីនេះ ។ ជាងនេះទៅទៀត ផាន បានជួយពិនិត្យមើលអាការៈរបស់អ្នកជំងឺផ្សេងៗទៀតដែលមានបញ្ហាមិនស្រួលដើម្បីបញ្ជូនអ្នកទាំងនោះទៅកាន់មន្ទីរពេទ្យនៅទីក្រុងភ្នំពេញ ។ ភាគច្រើន អ្នកជំងឺដែល ផាន បានបញ្ជូនទៅសុទ្ធតែបានជាសះស្បើយនិងបានវិលត្រឡប់មកផ្ទះវិញ ព្រោះមានការយកចិត្តទុកដាក់និងមើលថែទាំយ៉ាងដិតដល់ពីសំណាក់ក្រុមគ្រូពេទ្យ ។

នៅឆ្នាំ១៩៧៨ សឿង បានផ្លាស់ ផាន មកធ្វើការនៅក្នុងមន្ទីរពេទ្យព-១ ស្ថិតនៅក្នុងខេត្តសៀមរាប ដែលមានឈ្មោះ កាន់



ការផលិតថ្នាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ជាប្រធានមន្ទីរពេទ្យ ។ នៅទីនោះ ផាន ធ្វើការនៅកន្លែងវះកាត់ឆ្មបសម្រាលកូន និងកន្លែងរុំរបួសដល់ប្រជាជននិងកងទ័ព ។ ផាន បានជួយមនុស្សជាច្រើន ដូចជា ស្ត្រីម្នាក់ដែលមានជំងឺបេះដូង ដោយបានបញ្ជូនគាត់ទៅព្យាបាលនៅទីក្រុងភ្នំពេញរហូតបានជាសះស្បើយត្រឡប់មកផ្ទះវិញដោយសុវត្ថិភាព ។ លើសពីនេះទៅទៀត រយៈពេលប្រហែលមួយខែក្រោយមក ស្ត្រីម្នាក់នោះក៏បានមកលេង ផាន ហើយបានយកនំចំណីខ្លះមកជូនគាត់ជាការដឹងគុណទៀតផង ។

ប៉ុន្តែ ផាន ដែលមានបទពិសោធន៍គ្រប់គ្រាន់ មិនអាចជួយសង្គ្រោះស្ត្រីម្នាក់ដែលឈឺពោះសម្រាលកូនឲ្យរួចផុតពីសេចក្តីស្លាប់បានឡើយ ដោយសារតែគាត់ធ្វើដំណើររយៈពេលយូរនិងធ្លាក់ឈាមច្រើនពេក ទម្រាំដឹកមកដល់មន្ទីរពេទ្យ ។ ម្យ៉ាងទៀតដោយសារស្ត្រីនោះមានវ័យចំណាស់ ហើយក៏ជាការសម្រាលកូនលើកទី១៥របស់គាត់ផងដែរ ដូច្នេះ ទោះជា ផាន និងបុគ្គលិកដទៃទៀតខិតខំជួយយ៉ាងណាក៏ដោយ ក៏មិនអាចជួយសង្គ្រោះម្តាយនិងកូនដែលនៅក្នុងផ្ទៃបានដែរ ។

នៅដើមឆ្នាំ១៩៧៩ ខណៈពេលដែលមានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងរវាងកងទ័ពវៀតណាមនិងកងទ័ពខ្មែរក្រហម បុគ្គលិកដែលធ្វើការនៅក្នុងមន្ទីរពេទ្យព-១ទាំងអស់ក៏បំបែកគ្នាជាច្រើន



ការផលិតថ្នាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ក្រុមធ្វើដំណើរត្រឡប់មករកលំនៅឋានរៀងៗខ្លួន ។ ចំណែក ផាន បានរត់ភៀសខ្លួនជាមួយនឹងក្រុមគ្រូពេទ្យមួយចំនួនទៀតបែរជារត់ទៅរស់នៅលើភ្នំដងរែកទៅវិញ ។ ពេលធ្វើដំណើរ មានក្មេងៗជាច្រើននាក់ដែលត្រូវបានប្រធានពេទ្យឈ្មោះ កាន់ បង្ហាត់បង្រៀនពីវិជ្ជាពេទ្យបានសុំ ផាន រត់ទៅជាមួយដែរ ។ ពេលនោះ ទោះបីជា ផាន ហាមប្រាមមិនឲ្យក្មេងៗទាំងនោះរត់ទៅជាមួយក៏ដោយ ក៏ក្មេងៗទាំងនោះនៅតែធ្វើដំណើរមកតាមគាត់ដដែល ។ នៅតាមផ្លូវធ្វើដំណើរទៅកាន់ភ្នំដងរែក ដោយសារតែមានការអាណិតអាសូរដល់ស្ត្រីម្នាក់ដែលឈឺពោះឆ្លងទន្លេនៅតាមផ្លូវ ផាន ក៏បានជួយសម្រាលកូនដល់ស្ត្រីម្នាក់នោះនិងជួយកងទ័ពដែលរងរបួសជាច្រើននាក់ទៀតដោយសារជាន់មីន ។ បន្ទាប់មក ក្រុមរបស់ ផាន បានបន្តដំណើររហូតមកដល់ភ្នំខៀវ ដែលស្ថិតនៅម្តុំស្រុកសំឡូត ហើយក៏បានជួបជាមួយ កាន់ នៅតាមផ្លូវដែលកំពុងនាំក្មេងៗអាយុជាង១០ឆ្នាំធ្វើដំណើរជាមួយ ។ ក្នុងចំណោមក្មេង១០នាក់នោះ មានតែក្មេងចំនួន៥នាក់ប៉ុណ្ណោះ ដែលបានធ្វើដំណើរមកតាមជាមួយក្រុមរបស់ ផាន ។ ការរស់នៅលើភ្នំមានការលំបាកយ៉ាងខ្លាំង ដោយសារមានអាកាសធាតុត្រជាក់ ហើយសម្បុរទៅដោយទឹកសន្សើមនិងមិនសូវមានពន្លឺព្រះអាទិត្យចេញចូលគ្រប់គ្រាន់ រហូតធ្វើឲ្យមនុស្សដែលរស់នៅទីនោះស្ទើរតែទាំងអស់កើតជំងឺគ្រុនចាញ់គ្រប់គ្នា ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏ ផាន នៅតែបន្តជួយព្យាបាលអ្នកជំងឺដែលរស់នៅទីនោះទៅតាមលទ្ធភាពដែលគាត់អាចជួយបាន ។

រហូតមកដល់ឆ្នាំ១៩៨០ ផាន និងក្រុមកងពលផ្សេងៗទៀតបានចុះមកបោះទីតាំងនៅតាមជើងភ្នំខៀវវិញដែលធ្វើឲ្យប្រជាជននិងក្មេងៗទាំងអស់លែងកើតជំងឺគ្រុនបន្តទៀត ។ ចំណែកក្មេងៗមួយចំនួនដែលបានធ្វើដំណើរមកតាម ផាន បានចាកចេញពីកងពលរបស់ខ្លួនដើម្បីស្វែងរកបងប្អូន ហើយមួយចំនួនទៀតក៏បានបន្តរស់នៅទីនោះទៀត ប៉ុន្តែភាគច្រើនក្មេងទាំងនោះមិនសូវស្គាល់ឪពុកម្តាយរបស់ខ្លួនទេ ។ កងពលនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អ៊ី ឈាន ជាមេដឹកនាំកងពលដែលចេញមកពីខេត្តសៀមរាបមកតាំងមូលដ្ឋាននៅលើភ្នំ ហើយបច្ចុប្បន្នគាត់គឺជាអភិបាលក្រុងប៉ៃលិន ។ អ៊ី ឈាន បានខិតខំជួយទំនុកបម្រុងនិងដោះស្រាយបញ្ហាផ្សេងៗដល់ប្រជាជន និងកងទ័ពជាច្រើនគ្រួសារ ចំណែក ផាន ខិតខំជួយព្យាបាលជំងឺដល់ប្រជាជននិងកងទ័ពដែរ ។

នៅឆ្នាំ១៩៨១ ផាន បានរៀបការជាមួយបុរសម្នាក់ឈ្មោះ សំណាង និងមានកូនចំនួន ៤នាក់ ។ ក្រោយពីការងារធ្វើស្រែចម្ការ ផាន ក៏មានតួនាទីជាប្រធានភូមិទឹកចេញចាប់តាំងពីឆ្នាំ២០០៦ ក្នុងសង្កាត់ស្ទឹងកាច់ ខណ្ឌសាលាក្រៅ ក្រុងប៉ៃលិន ។

**ឌា ធីតា**

# ជនជាតិចាមនៅភូមិស្វាយឃ្លាំង

ភូមិស្វាយឃ្លាំង ជាភូមិដែលមានជនជាតិចាមចំនួនប្រមាណជាង២.០០០គ្រួសាររស់នៅមុនរបបខ្មែរក្រហម ។ ក្រោយឆ្នាំ១៩៧៩ ជនជាតិចាមដែលនៅសល់តែជាងមួយរយគ្រួសារប៉ុណ្ណោះ ។ ស្មាស់ បានរស់រានមានជីវិតពីការជម្លៀសជនជាតិចាមចេញពីភូមិនិងការបង្ក្រាបយ៉ាងឃោរឃៅពីសំណាក់កងទ័ពខ្មែរក្រហមទៅលើអ្នកបះបោរជនជាតិចាម ។

ស្មាស់ បានរៀបរាប់ថា «នៅពេលរំឭករឿងនេះធ្វើឲ្យខ្ញុំឈឺក្បាលជាខ្លាំង» ។ ឈប់និយាយមួយស្របក់ ស្មាស់ ក៏ចាប់ផ្តើមបន្តទាំងសំឡេងរអាក់រអួលថា ឪពុកម្តាយរបស់គាត់មិនមែនជាជនជាតិចាមសុទ្ធសាធទេ គឺជាកូនកាត់ចិនដែលប្រកបមុខរបរធ្វើស្រែដាំល្ង អំពៅ និងថ្នាំជក់ដើម្បីចិញ្ចឹមកូន ចំនួន១២នាក់ ។ នៅក្នុងវ័យ១៨ឆ្នាំ ស្មាស់ មិនបានចូលរៀននៅសាលាសាសនា ឬភាសាខ្មែរទេ គឺគាត់ត្រូវ មកជួយធ្វើការជំនួសឪពុកម្តាយនៅផ្ទះវិញ ។ រហូតមកដល់ពេល លន់ នល់ ធ្វើរដ្ឋប្រហារ ទម្លាក់សម្តេច សីហនុ ឆ្នាំ១៩៧០ ជនជាតិចាមមួយចំនួននៅក្នុងភូមិស្វាយឃ្លាំង ស្រុកក្រូចឆ្មារ បានចូលរួមហែក្បួនធ្វើបាតុកម្មដើម្បីទាមទារឲ្យសម្តេច សីហនុ ឡើងកាន់អំណាចវិញ ប៉ុន្តែត្រូវកងទ័ព លន់ នល់ បាញ់បង្ក្រាបយ៉ាងសាហាវបណ្តាលឲ្យប្រជាជនខ្លះរបួស ខ្លះបាក់ដៃបាក់ជើង ។ បន្ទាប់ពីការបង្ក្រាបដ៏ឃោរឃៅនេះ មិនយូរប៉ុន្មាន គ្រួសារជនជាតិចាមទាំងអស់ រួមទាំងគ្រួសាររបស់ ស្មាស់ ផង បានចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហម ដោយអង្គការចាត់តាំងជាប្រធានក្រុម មេកង មេភូមិ មេឃុំ ដើម្បីដឹកនាំការងារធ្វើស្រែចម្ការប្រវាស់ដៃ ប៉ុន្តែគ្រួសារជនជាតិចាមនៅក្នុងភូមិអាចហូបបាយនៅតាមផ្ទះរៀងខ្លួនបាន ។

ក្រោយមក ខ្មែរក្រហមចាប់ផ្តើមលុបបំបាត់បន្តិចម្តងៗនូវទំនៀមទម្លាប់ចាមដោយមិនឲ្យគ្រូបស្សែ ថ្វាយបង្គំ និងសូត្រធម៌នៅវិហារ ។ ខ្មែរក្រហមបានកត់ឈ្មោះ និស្សិត គ្រូបង្រៀន អ្នកចេះដឹងខាងសាសនាដែលទៅថ្វាយបង្គំនៅព្រះវិហារ រហូតប្រជាជនសាមញ្ញនៅក្នុងភូមិស្វាយឃ្លាំង រួចហើយក៏ធ្វើការចាប់ខ្លួនអ្នកទាំងអស់នោះ ។ ដោយសារមិនអាចទ្រាំទ្រនឹងការរឹតបន្តឹងនេះបាន ប្រជាជនចាមក្នុងភូមិស្វាយឃ្លាំងបានក្រោកឡើងបះបោរប្រឆាំងទៅនឹងខ្មែរក្រហម ។ ក្រោយពីធ្វើការបាញ់បង្ក្រាបបាតុករយ៉ាងសាហាវឃោរឃៅរួចមក ខ្មែរក្រហមក៏ជម្លៀសជនជាតិចាមទាំងអស់ចេញពីភូមិ រួចហើយបញ្ចូលគ្រួសារខ្មែរឲ្យមករស់ក្នុងភូមិស្វាយឃ្លាំងវិញ ។

ស្មាស់ និងក្រុមគ្រួសារ ត្រូវខ្មែរក្រហមជម្លៀសទៅនៅភូមិខ្សាច់ប្រឆេះលើ បន្ទាប់មកអង្គការ បានរៀបចំជាក្រុមសាមគ្គី និងសហករណ៍ដោយមានចែកអង្ករដល់គ្រួសារជម្លៀសទាំងអស់ ។ ប្រមាណ២ខែក្រោយមក អង្គការបានប្រមូលរបស់របរប្រើប្រាស់ និងទ្រព្យទាំងអស់មកដាក់ជាសមូហភាព និងសាងសង់រោងបាយ



ជនជាតិចាមកំពុងមើលសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ចំនួនពាកន្លែងសម្រាប់ឲ្យប្រជាជនមកហូបរួម ។ នៅទីនោះ ស្អាស់ ត្រូវបានខ្មែរក្រហមឲ្យប្តូរឈ្មោះជា សាន់ វុត្ថា ចំណែកបងស្រី សារី ប្តូរជាឈ្មោះ អ៊ាង ហើយ សារីអាស់ ប្តូរជាឈ្មោះ ជឿន វិញ ដើម្បីកុំឲ្យច្រឡំជាមួយឈ្មោះបងប្អូនជនជាតិចាមផ្សេងទៀត ។ បន្ទាប់ពីប្តូរ ឈ្មោះរួច ស្អាស់ ត្រូវជ្រើសរើសឲ្យដឹកនាំការងាររកងចល័តភូមិដែលមានប្រមាណ៣០គ្រួសារ ។ ដោយមានការស្រលាញ់រាប់អានកាន់តែច្រើនពីប្រជាជនដែលរស់នៅក្នុងភូមិ គាត់ត្រូវបានអង្គការដំឡើងការងារជាអ្នកកាន់សោឃ្លាំងសម្ភារៈ ។ ចំណែកគ្រួសារជនជាតិចាមផ្សេងទៀត ដែលជម្លៀសចេញពីភូមិស្វាយឃ្លាំងទៅនៅភូមិខ្សាច់ប្រឆេះលើ ត្រូវកងទាហានខ្មែរក្រហមយាមទាំងយប់ទាំងថ្ងៃ ហើយគ្រួសារខ្លះត្រូវខ្មែរក្រហមចោទប្រកាន់ថាលួចថ្វាយបង្គំព្រះទៀតផង ។ ដោយឃើញ ពីការខ្វះអាហារនិងការលំបាកក្នុងការងារប្រចាំថ្ងៃ ស្អាស់ តែងតែលួចចាក់សោឃ្លាំងអង្ករ និងឃ្លាំងពោតនៅពេលយប់ ដោយឲ្យគ្រួសារជម្លៀសចូលមកយកទៅដាំហូបជារឿយៗ ។

រហូតដល់ឆ្នាំ១៩៧៨ បន្ទាប់ពីកងទ័ពភូមិភាគកណ្តាលចូលមកផ្លាស់ប្តូរប្រធានភូមិខ្សាច់ប្រឆេះលើ និងធ្វើការចាប់ខ្លួនប្រធាន «ខ» គណៈ «ង» និងមេបញ្ជាកងទ័ពភូមិភាគបូព៌ាដែលដឹកនាំដោយ សោ ភឹម រួចប្រជាជនចាមដែលជម្លៀសចេញពីភូមិជាច្រើនគ្រួសារបានវិលចូលមករស់នៅក្នុងភូមិ ស្វាយឃ្លាំងវិញ ដោយគិតថា កងទ័ពបានរំដោះហើយ ។ បន្ទាប់ពីមានគ្រួសារចាមចូលមករស់នៅក្នុងភូមិស្វាយឃ្លាំងច្រើនហើយ គ្រួសារមួយចំនួនដែលរស់នៅក្នុងភូមិនេះក៏រាយការណ៍ប្រាប់អង្គការថា ចាមបះបោរបានវិលត្រឡប់ចូលភូមិវិញ ។ ពេលនោះខ្មែរក្រហមចាប់ផ្តើមជម្លៀសម្តងទៀត ដោយបំបែកឲ្យប្រុសៗចាមនៅដាច់ដោយឡែកពីស្រីៗ ហើយអ្នកមានឈ្មោះត្រូវចាប់យកទៅសម្លាប់ចោលនៅក្នុងឃុំទ្រា និងភូមិកោះផល ។ នៅខណៈនោះ ដោយសារមិនបានដឹងពីការសម្លាប់និងជម្លៀសនេះ គ្រួសាររបស់ ស្អាស់ បានរៀបចំខោអាវ រួចធ្វើដំណើរចូលមករស់នៅក្នុងភូមិវិញ ប៉ុន្តែនៅពេលដើរមកដល់ព្រែកតាដួងមេទាហានខ្មែរក្រហមមកពីភូមិភាគកណ្តាលបានហាមឃាត់ និងប្រាប់ឲ្យទៅរស់នៅភូមិខ្សាច់ប្រឆេះកណ្តាលវិញ ។ ដោយសារ ស្អាស់ មានការចាប់ចិត្តស្រលាញ់ពីអ្នកធ្វើការនៅកងចល័តអនុបញ្ជាការកងទ័ពឈ្មោះ ស្រ៊ុន និងការរាប់អានពីមេបញ្ជាការកងទ័ពឈ្មោះ សារឿន ដែលស្រលាញ់ បងស្រីរបស់គាត់ឈ្មោះ អ៊ាង ផងនោះ គាត់ក៏ត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកដាំបាយនៅអង្គភាពទ័ពភូមិភាគកណ្តាលដែលមានទីតាំងនៅក្នុងវត្តខ្សាច់ប្រឆេះកណ្តាល និងមានសិទ្ធិចូលមកសួរសុខទុក្ខបងប្អូនរបស់គាត់នៅក្នុងភូមិស្វាយឃ្លាំងដែលខ្មែរក្រហមមិនបានជម្លៀសចេញ ។ ចំណែកជនជាតិចាមជាច្រើនគ្រួសារទៀតត្រូវខ្មែរក្រហមប្រមូលមកដាក់នៅមាត់ទន្លេមេគង្គដែលស្ថិតនៅទល់មុខវត្តខ្សាច់ប្រឆេះកណ្តាល ដើម្បីជម្លៀសទៅនៅភូមិផ្សេងទៀត ដែលក្នុងចំណោមនោះ ស្អាស់ ក៏បានជូនដំណើរគ្រួសារខ្លះឡើងកាណូតដែរ ព្រោះតែគាត់នឹកអាឡោះអាល័យអ្នកដែលធ្លាប់រស់នៅក្នុងភូមិជាមួយគ្នា ទោះបីមានការហាមឃាត់ពីអង្គការក៏ដោយ ។

នៅថ្ងៃមួយ ស្អាស់ បានទៅឈរលេងលើកាណូតកងទ័ពដែលដឹកសុទ្ធតែកុមារចាមតូចៗដែលចតក្បែរមាត់ច្រាំងទន្លេ មួយរយៈក្រោយមក កាណូតក៏បើកចេញពីច្រាំងបានប្រហែល២០០ម៉ែត្រ កងទ័ពក៏ចាប់ផ្តើមចាប់ក្មេងៗទាំងនោះច្រកចូលបាវចំនួនពីររួចទម្លាក់ចូលក្នុងទន្លេ ។ ខណៈនោះ ដោយឃើញ ស្អាស់ កំពុងនៅលើកាណូត មេបញ្ជាការទ័ពឈ្មោះ សារឿន បាន គេអូ (វិទ្យុទាក់ទង) ទៅអ្នកបើកឲ្យត្រឡប់មកចតនៅមាត់ច្រាំងទន្លេ ដើម្បីឲ្យ ស្អាស់ ឡើងមកលើដីគោកវិញ រួចហើយប្រាប់ថា «ថ្ងៃស្អែកកុំមកនៅលាយឡំជាមួយកងទ័ពទាំងនេះទៀត ហើយកុំនិយាយភាសាចាមជាមួយប្រជាជនចាមដែលចាប់មកទីនេះ» ។

ក្រោយមក ដោយមានការទុកចិត្តកាន់តែខ្លាំង សារឿន បានហៅ ស្អាស់ ឲ្យឡើងជិះទូកជាមួយ រួចចែវទៅទាញយកសាកសពមនុស្សជាច្រើនដែលចងភ្ជាប់ទៅនឹងដើមឫស្សីហើយអណ្តែតមកប្របមាត់ច្រាំងទន្លេឲ្យគាត់មើលដោយផ្ទាល់តែម្តង ។ ប៉ុន្តែ ដោយសារមានការភ័យខ្លាច ស្អាស់ បានអង្វរ សារឿន ថា «បង! ថ្ងៃក្រោយសូមកុំនាំខ្ញុំមកមើលដូច្នេះទៀត» ។ បន្ទាប់ពីពាក្យនេះ សារឿន ឆ្លើយទាំងទឹកមុខស្មើថា «ខ្លាចអី! បងធ្លាប់សម្លាប់មនុស្សជាង២.០០០នាក់ឯណោះ» ។ មួយថ្ងៃក្រោយមកទើប ស្អាស់ បានឮសម្តីតាមរយៈអនុបញ្ជាកងទ័ពឈ្មោះ ស្រ៊ុន ដែលស្រលាញ់គាត់ប្រាប់ថា «សាកសពទាំងនោះ សារឿន ជាអ្នកចេញបញ្ជាឲ្យ

សម្លាប់» ស្មាស់ ចាប់ផ្តើមរន្ធត់ក្នុងចិត្ត និងភិតភ័យពីការកាប់សម្លាប់ដ៏សាហាវឃោរឃៅនេះ រហូតបណ្តាលឲ្យគាត់ធ្លាក់ខ្លួនឈឺគ្រុន ។ នៅកន្លែងដាំបាយ ស្មាស់ និងបងស្រី សារី តែងតែធ្វើឲ្យមានកំហុសដូចជាកំពប់បាយ សម្ល និងលួចធ្វើម្ហូបហូបក្នុងគ្រួសារទៀត ប៉ុន្តែរាល់កំហុសទាំងអស់នេះ សារឿន តែងតែអនុគ្រោះ ហើយថែមទាំងធានាមិនឲ្យនរណាប៉ះពាល់ក្រុមគ្រួសារគាត់ទៀតផង ។

មិនយូរប៉ុន្មាន ខ្មែរក្រហមចាប់ផ្តើមយកអ្នកទោសដែលឃុំនៅទីបញ្ជាការកងទ័ពក្នុងវត្តប្រឆេះខ្សាច់កណ្តាលទៅសួរពីប្រវត្តិរូប ។ ពេលនោះជនជាតិចាមដែលបានឆ្លើយលាក់អត្តសញ្ញាណថាខ្មែរ ទើបអង្គការដោះលែង ចំណែកជនជាតិចាមដែលនៅសេសសល់រាប់រយនាក់ត្រូវចាប់ខ្លួនជាបន្តបន្ទាប់ រួចបញ្ជូនយកទៅសម្លាប់ចោលនៅបឹងកេត ក្នុងស្រុកស្ទឹងត្រង់ ហើយជនជាតិចាមនៅក្នុងភូមិស្វាយឃ្លាំងជាច្រើននាក់ ទៀតក៏ត្រូវចាប់ខ្លួនយកទៅសម្លាប់នៅលើដៃក្នុងស្រុកក្រូចឆ្មារដែរ ។ នៅខណៈនោះអ្នកធ្វើការនៅកងចល័តដែលចូលស្ទីដណ្តឹង ស្មាស់ ម្នាក់ក៏ត្រូវខ្មែរក្រហមចាប់ចងបណ្តើរយកទៅបាត់ ដោយគ្រាន់តែអនុញ្ញាតឲ្យឈប់នៅមុខផ្ទះរបស់ ស្មាស់ ដើម្បីនិយាយពាក្យលាទាំងអារម្មណ៍រន្ធត់ប៉ុណ្ណោះ ។ ទោះបី ស្មាស់ ដឹងប្រាកដថាខ្មែរក្រហមបណ្តើរយកទៅសម្លាប់ចោលក៏ដោយ ក៏គាត់មិនអាចជួយបុរសនោះឲ្យរស់បានដែរ ។ រហូតមានការវាយប្រយុទ្ធគ្នារវាងកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជាជាមួយនឹងកងទ័ពខ្មែរក្រហម ក្រុមគ្រួសាររបស់ ស្មាស់ បានរត់ភៀសខ្លួនចូលព្រៃមួយរយៈ រួចហើយក៏វិលត្រឡប់ចូលមករស់នៅភូមិស្វាយឃ្លាំងវិញ ចំណែកគ្រួសារអ្នកភូមិជាច្រើនទៀតត្រូវខ្មែរក្រហមកៀរយកទៅសម្លាប់ចោលទាំងអស់ ។

រយៈពេល៣ឆ្នាំដែល ស្មាស់ រស់នៅក្នុងភូមិឃើញតែការកាប់សម្លាប់ បានធ្វើឲ្យខួរក្បាលរបស់គាត់ដក់ជាប់នូវអារម្មណ៍ភ័យខ្លាចដោយសារតែអំពើឃោរឃៅរបស់ខ្មែរក្រហមធ្វើទៅលើគ្រួសារជនជាតិចាម ហើយគាត់ក៏មិនចង់រំឭកឡើងវិញនូវរឿងរ៉ាវឈឺចាប់ទាំងអស់នេះទៀតដែរ ។ ចុងក្រោយ ស្មាស់ បានបញ្ជាក់ថា «ជីវិតរបស់គាត់ និងក្រុមគ្រួសារដែលរស់មកដល់សព្វថ្ងៃ គឺដោយសារតែការស្រលាញ់របស់មេបញ្ជាការខ្មែរក្រហមប៉ុណ្ណោះ ហើយទោះបីជាអ្នកទាំងនោះមានឈ្មោះអាក្រក់យ៉ាងណាក៏ដោយ ក៏គាត់មិនអាចបំភ្លេចគុណអ្នកដែលជួយគាត់ឲ្យរស់ជីវិតបានដែរ» ។

**សោម ប៊ុនថន**



ផ្ទះចាស់ ៖ ផ្ទះចាស់នេះ គឺជាផ្ទះមួយក្នុងចំណោមផ្ទះមួយចំនួនតូចដែលនៅសេសសល់នៅភូមិស្វាយឃ្លាំង នៃខេត្តកំពង់ចាម ។ ផ្ទះទាំងនេះមានអាយុដល់ទៅជិត១០០ឆ្នាំ ឬក៏ច្រើនជាងនេះ ។ បើតាមប្រជាជននៅតំបន់នោះបានឲ្យដឹងថា ភូមិនេះគឺជាប្រភពនៃសាសនាអ៊ីស្លាមក្នុងប្រទេសកម្ពុជា ។

# ដើមបណ្តឹងរដ្ឋប្បវេណីចែករំលែករឿងរ៉ាវទុក្ខសោក

ថ្ងៃនេះ តុលាការបន្តស្តាប់សក្ខីកម្មពីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការកាត់ក្តី កាំង ហ្កេកអ៊ាវ ហៅ ឌុច ។ ក្នុងអំឡុងពេលពីរថ្ងៃចុងក្រោយ សាលាក្តីបានទទួលសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៧ ហើយក៏កំពុងដំណើរការយ៉ាងលឿនដាងការរំពឹងទុកទៅទៀត ។

**មិនដែល មិនដែលថាខ្ញុំនឹងលើកលែងទោសឲ្យគាត់**

អង្គសវនាការនៅពេលព្រឹកនេះបានចាប់ផ្តើមដោយ ការផ្តល់សក្ខីកម្មរបស់ អង់តូនីញ៉ា ដូឡុង ជាជនជាតិបារាំងដែលមានឪពុកម្តាយជាជនជាតិខ្មែរ ។ បងស្រីរបស់នាង រង្សី ដូឡុង និងបងថ្លៃរបស់នាង លីម គីម៉ារី ដែលអ្នកទាំងពីរត្រូវបានឃុំឃាំងជាអ្នកទោសនៅក្នុងគុកទួលស្លែង ហើយត្រូវបានសម្លាប់ ។ អង់តូនីញ៉ា ដូឡុង បានផ្តល់សក្ខីកម្មនៅក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែជាអ្នកនាំពាក្យឲ្យក្រុមគ្រួសារទាំងមូល ។

ឪពុករបស់គាត់គឺជាមន្ត្រីជាន់ខ្ពស់ម្នាក់ដែលធ្វើការជាមួយរដ្ឋាភិបាលសម្តេច សីហនុ ។ ដោយសារតួនាទីអចិន្ត្រៃយ៍របស់គាត់នៅក្នុងរដ្ឋាភិបាលគ្រួសាររបស់ ដូឡុង ត្រូវបាននិរទេសចេញពីប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧០ បន្ទាប់ពី លន់ នល់ បានគ្រប់គ្រងប្រទេស ។ ទោះបីជាមានបញ្ហាបែបនេះក្តី រង្សី ដូឡុង បានសម្រេចចិត្តស្នាក់នៅក្នុងប្រទេសកម្ពុជាតទៅទៀត ដោយប្រើឈ្មោះប្តីរបស់គាត់ ។ រង្សី និងប្តីរបស់គាត់មិនចង់ចាកចេញពីប្រទេសកម្ពុជាជាកន្លែងដែលគាត់ធ្វើការជាអ្នកអានព័ត៌មាននៅស្ថានីយវិទ្យុបារាំងនិងប្តីគាត់ធ្វើជាបុគ្គលិកធនាគារទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ខណៈពេលដែលស្ថានការណ៍នយោបាយ និងសន្តិសុខមានសភាពយ៉ាប់យ៉ឺននៅក្នុងប្រទេសកម្ពុជា រង្សី បានបញ្ជូនកូនរបស់គាត់ទៅកាន់ទីក្រុងប៉ារីសដើម្បីទទួលការអប់រំល្អប្រសើរនៅក្នុងបរិយាកាសមួយដ៏មានសុវត្ថិភាព ។ ចុងក្រោយគ្រួសាររបស់គាត់បានព្រាត់ប្រាសពី រង្សី នៅក្នុងខែមីនា ឆ្នាំ១៩៧៥ ។ តាំងពីពេលនោះមក ពួកគេបានអត់ទ្រាំជាមួយនឹងការលំបាកយ៉ាងស្ងប់ស្ងាត់អស់រយៈពេលជាច្រើនឆ្នាំ ។ បន្ទាប់ពីការដួលរលំរបស់របបខ្មែរក្រហម ប្រទេសបារាំងបានបើកព្រំដែនសម្រាប់ជនភៀសខ្លួនដ៏ច្រើនសន្ធឹកសន្ធាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ រង្សី និងប្តីរបស់គាត់មិនមានវត្តមាននៅក្នុងចំណោមអ្នកទាំងអស់នោះដែលបានធ្វើដំណើរទៅកាន់ទឹកដីប្រទេសបារាំងឡើយ ពីព្រោះពួកគេបានបាត់បង់ជីវិតរួចទៅហើយដោយសារស្នាដៃនៃរបបដ៏ព្រៃផ្សៃនោះ ។

គ្រួសាររបស់ ដូឡុង ក្រោយមកក៏បានជួបជុំគ្នាវិញជាមួយបងប្អូនជីដូនមួយដែលបានធ្វើដំណើរទៅកាន់ប្រទេសបារាំងក្នុងនាមជាជនភៀសខ្លួន ។ រឿងរ៉ាវដែលពួកគេបានរៀបរាប់គឺពិតជាគួរឲ្យរន្ធត់ ។ ពួកគេបានធ្វើដំណើរឆ្លងកាត់ឋាននរក ប៉ុន្តែក៏អាចចាត់ទុកថាមានមានសំណាងមួយដែរ ។ គ្រួសារនេះបានលាតត្រដាងដំណឹងដ៏អាក្រក់មួយដែល រង្សី និង ប្តីរបស់គាត់មិនមានសំណាងពីព្រោះពួកគេមិនបានរស់រានមានជីវិតពីរបបដ៏ព្រៃផ្សៃនេះ ។ ពួកគេត្រូវបានដាក់គុក និងសម្លាប់នៅក្នុងមន្ទីរស-២១ ។ ដំណឹងនេះត្រូវបានបំផ្លាញនិងក្លាយទៅជាភាពភ័យរន្ធត់ដ៏ធំសម្រាប់ក្រុមគ្រួសាររបស់ ដូឡុង ។

សមាជិកគ្រួសារដទៃទៀតត្រូវស្ថិតនៅក្នុងពេលវេលាដ៏លំបាកជាច្រើនក្នុងការប្រឈមមុខជាមួយនឹងការបាត់បង់ ហើយគ្រប់គ្នាគ្រប់គ្រងការព្រួយចិត្តរបស់ពួកគេ ។ កូនៗរបស់ រង្សី បានវិវត្តន៍ទៅរកបញ្ហាផ្លូវចិត្តដ៏ធ្ងន់ធ្ងរ ។ ពេទ្យវិកលចរិតបានបញ្ជាក់ថា រូបកាយរបស់ពួកគេផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងការប៉ះទង្គិចផ្លូវចិត្តទាក់ទងទៅនឹងការបាត់បង់ឪពុកម្តាយរបស់ពួកគេ ។ ពួកគេមិនអាចបង្ហាញខ្លួននៅសាលាក្តីបាន ពីព្រោះតែមិនទាន់ត្រៀមខ្លួនរួចរាល់ដើម្បីប្រឈមមុខជាមួយនឹងជនត្រូវចោទ ។ អង់តូនីញ៉ា ដូឡុង បានបាត់បង់បងស្រី ឪពុកម្តាយរបស់នាងបាត់បង់កូនស្រីម្នាក់ និងក្មួយស្រីព្រមទាំងក្មួយប្រុសរបស់គាត់បានបាត់បង់ម្តាយ

របស់ពួកគេ ។

គាត់បានសង្កត់ធ្ងន់ថា ការសុំទោសគឺមិនគ្រប់គ្រាន់សម្រាប់យុត្តិធម៌ដែលត្រូវធ្វើទេ ហើយគាត់បានជំរុញឲ្យសាលាក្តីដាក់ទណ្ឌកម្ម ឌុច ក្នុងរបៀបមួយឲ្យសមនឹងអំពើឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្ត ។ គាត់បានធ្វើការកត់សម្គាល់ថា ក្នុងអំឡុងពេលកាត់


ឌុច ក្នុងឆ្នាំ២០០៩

ទោសនៅ នូរ៉ឹមប៊េក ភាគច្រើននៃអ្នកដែលរកឃើញថាមានកំហុសត្រូវបានគេកាត់ទោសប្រហារជីវិត ។ គាត់ហាក់បីដូចជាមិនចង់និយាយថា គាត់សង្ឃឹមថា តុលាការនេះនឹងដើរតាមតុលាការនូរ៉ឹមប៊េកចំពោះការកាត់ក្តីនេះ ប៉ុន្តែគាត់បង្ហាញអំពីភាពចាំបាច់ចំពោះបទឧក្រិដ្ឋកម្មជាជាងប្រកបដោយលក្ខណៈប្រវត្តិសាស្ត្រមួយ ។ ការដាក់ទោសប្រហារជីវិតគឺជាទម្រង់កាត់ទោសដែលត្រូវហាមឃាត់មិនឲ្យមាននៅក្នុងសាលាក្តីនេះ ។ គាត់បានត្អូញត្អែរថា នៅពេលនេះ ឌុច ត្រូវទទួលការកាត់ទោសដោយយុត្តិធម៌ និងការស្នាក់នៅដ៏សមរម្យមួយ ប៉ុន្តែជនរងគ្រោះទាំងអស់របស់គាត់មិនបានទទួលនូវសិទ្ធិមូលដ្ឋានទាំងអស់នេះឡើយ ។ ចំពោះករណីនេះ គាត់បានបញ្ជាក់យ៉ាងច្បាស់ថា «ខ្ញុំមិនអាច ហើយក៏មិនដែលនឹងអត់ឱនទោសឲ្យគាត់ជារៀងរហូត» ។

**សាក្សីដើមបណ្តឹងរដ្ឋប្បវេណី**

បន្ទាប់មក អង្គជំនុំជម្រះបានកោះហៅ ហាវ សុភា ដើម្បីធ្វើសាក្សីអំពីការបាត់បង់ឪពុករបស់នាង ចាន់ ស៊ី នៅមន្ទីរស-២១ ។ ឪពុករបស់គាត់គឺជាទាហានម្នាក់ ប៉ុន្តែត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៦ ហើយត្រូវបានសម្លាប់នៅថ្ងៃទី១៥ ខែឧសភា នៅក្នុងឆ្នាំដែលបានចាប់ខ្លួន ។ ដូចជា អ៊ុក នារី ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីកាលពីម្សិលមិញ សុភាមិនដែលបានស្គាល់មុខឪពុករបស់គាត់ឡើយ ប៉ុន្តែនៅតែមានការឈឺចាប់យ៉ាងខ្លាំងពីការបាត់បង់និងការស្លាប់របស់ឪពុកគាត់ ។ ចាន់ ស៊ី ត្រូវបានចាប់ខ្លួនបន្ទាប់ពីនាងកើតបាន២១ថ្ងៃនាងនិងម្តាយរបស់នាងបានរង់ចាំអស់រយៈពេលជាច្រើនឆ្នាំមកហើយមុនពេលទទួលបានដំណឹងអំពីការស្លាប់របស់ឪពុកនាង ។

សុភា រៀបរាប់ទាំងទឹកភ្នែកនៅក្នុងការធំដឹងក្តីដោយមិនមានឪពុក «ការតស៊ូក្រោកឈរតទល់នឹងជីវិត» ។ អវត្តមានរបស់ឪពុកនាងធ្វើឲ្យគ្រួសារជួបនឹងវិបត្តិហិរញ្ញវត្ថុ ឈឺចាប់ផ្លូវកាយ និងការលំបាកផ្លូវចិត្ត ។ ក្តីស្រមៃរបស់នាងចង់ក្លាយជាគ្រូបង្រៀនម្នាក់ ប៉ុន្តែនាងត្រូវបោះបង់ចោលសាលានៅត្រឹមថ្នាក់ទី៧ ពីព្រោះម្តាយរបស់នាងគ្មានថវិកាដើម្បីឧបត្ថម្ភការរៀនសូត្ររបស់នាង ។ ទីបំផុតនៅពេលម្តាយរបស់នាងបានទទួលឯកសារ ដែលបង្ហាញថាប្តីរបស់គាត់ត្រូវបានសម្លាប់នៅមន្ទីរស-២១ នាងបានស្រក់ទឹកភ្នែក ។ ម្តាយរបស់នាងមិនបានធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទេពីព្រោះនាងនៅមិនអាចប្រឈមមុខជាមួយនឹងជនត្រូវចោទ ។ សុភា រៀបរាប់ពីការឈឺចាប់ផ្ទាល់ខ្លួនរបស់នាងនិងការឈឺចាប់ដែលនាងទទួលបាន ។ ការឈឺចាប់មានកាន់តែខ្លាំងឡើងៗក្រោយពេលដឹងថាឪពុករបស់នាងបានស្លាប់ដោយសាររបបដ៏ឃោរឃៅនេះ ។ បន្ទាប់ពីមកទស្សនាដោយផ្ទាល់នៅមន្ទីរស-២១ នាងបន្តការនឹកឃើញ និងសុបិនជាញឹកញាប់ ។ នាងបានពន្យល់ពីអារម្មណ៍ដែលនាងមិនធ្លាប់បានឃើញមុខឪពុកនៅពេលដែលគាត់នៅរស់ប៉ុន្តែមិនអាចបំភ្លេចរូបភាពឪពុកបន្ទាប់ពីការស្លាប់របស់គាត់បានឡើយ ។

ដើមបណ្តឹងរដ្ឋប្បវេណីទីបីត្រូវបានតុលាការហៅឲ្យធ្វើសក្ខីកម្មគឺ សូ សុង ។ ដូចជាអ្នកដទៃទៀត នាងបានបាត់បង់បងថ្លៃដោយសារស្នាដៃនៃរបបខ្មែរក្រហម ។ មុនការផ្តល់សក្ខីកម្មរបស់

នាងដែលជាដើមបណ្តឹងរដ្ឋប្បវេណីនាង និងមេធាវីការពារក្តីបាន ជជែកគ្នាពេញមួយថ្ងៃអំពីភាពទទួលយកបាននៃសក្ខីកម្មរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ។

មេធាវីការពារក្តីបានជជែកគ្នាថា មានភាពខុសគ្នាជាមួយ នឹងឯកសារជាច្រើនដែលបានផ្តល់ឲ្យ ដើម្បីចោទជាសំណួរពីទំនាក់ ទំនងពិតប្រាកដរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងបងថ្លៃ របស់នាង ហើយថាតើគាត់ពិតជាត្រូវបានឃុំឃាំងនិងសម្លាប់នៅ ក្នុងមន្ទីរស-២១ដែរឬទេ ។ ទោះបីជាការពិតថាគាត់ជាដើម បណ្តឹងរដ្ឋប្បវេណីដែលបង្កើតភ័ស្តុតាងដាក់បន្ទុកដើម្បីបង្ហាញពី ទំនាក់ទំនងមួយរវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទ ក៏ដោយ ក៏លោកប្រធានបានសម្រេចស្តាប់នូវចម្លើយសក្ខីកម្មមុន ហើយក្រោយមកទើបធ្វើការកំណត់ពីតម្លៃដែលអាចទទួលយក បាននៃសក្ខីកម្មដោយផ្អែកទៅលើការប្រកាន់ភ្ជាប់ការពិតរបស់ សាក្សី ។


នេត ប៊ុនធី និងបងប្រុស នេត ផល្លី

សូ សុង បានតំណាងឲ្យបងស្រីរបស់គាត់ជាដើមបណ្តឹង រដ្ឋប្បវេណី ពីព្រោះបងស្រីរបស់គាត់ឈឺធ្ងន់ពេក ក្នុងការផ្តល់ សក្ខីកម្មលើរឿងរបស់នាង ។ គាត់បានពន្យល់ថា គាត់បានរស់នៅ ជាមួយបងស្រីរបស់នាង និងបងថ្លៃរបស់នាងតាំងពីនាងមាន អាយុ៧ឆ្នាំម្ល៉េះ ។ ទំនាក់ទំនងរបស់គាត់និងពួកគេមានច្រើនដូចជា ទំនាក់ទំនងឪពុកម្តាយនិងកូនដូចជាបងប្អូនបង្កើតដែរ ។ សូ សុង បានពន្យល់ថា បន្ទាប់ពីបានដឹងអំពីការស្លាប់របស់បងថ្លៃគាត់ជីវិត របស់គាត់និងបងស្រីបានចាប់ផ្តើមយ៉ាប់យ៉ឺន ។ គាត់បានបង្ហាញ ពីអារម្មណ៍របស់គាត់ថា «គាត់គឺជាប្តី ជាឪពុកដ៏គួរឲ្យគោរព និងជា បងប្រុសដ៏គួរឲ្យស្រឡាញ់ម្នាក់ យើងទាំងអស់គ្នាបានយំ» ។

ដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយដែលត្រូវបានហៅឲ្យធ្វើ សក្ខីកម្ម គឺ ឈ្មោះ នេត ផល្លី ។ គាត់ និងបងប្រុសរបស់គាត់ ស្ថិតនៅក្នុងកងយោធាជាមួយគ្នា ។ បងប្រុសរបស់គាត់បានទទួល រងរបួសយ៉ាងធ្ងន់នៅសមរភូមិមួយក្នុងឆ្នាំ១៩៧៨ ហើយត្រូវ បានបញ្ជូនទៅមន្ទីរពេទ្យនៅទីក្រុងភ្នំពេញ ។ នៅទីនោះ នេត ផល្លី បានទៅមើលបងប្រុសរបស់គាត់បានចំនួនពីរដង ។ យោងទៅតាម ការទៅសួរសុខទុក្ខលើកទីបីរបស់គាត់ នេត ផល្លី បានរកឃើញ ត្រឹមតែបន្ទប់មន្ទីរពេទ្យដែលទទេស្អាតប៉ុណ្ណោះ ។ គ្មាននរណាម្នាក់ អាចប្រាប់គាត់ថា បងប្រុសរបស់គាត់ត្រូវបានបញ្ជូនទៅទីណា នោះទេ ហើយគាត់មិនដែលបានឃើញបងប្រុសរបស់គាត់ម្តង ទៀតឡើយ ។ គាត់បានស្រាវជ្រាវរកបងប្រុសរបស់គាត់ជាច្រើន ខែដោយមិនទទួលបានលទ្ធផលអ្វីទាំងអស់ ។ ភ័ស្តុតាងបានបង្ហាញ នៅក្នុងឆ្នាំ២០០៨ ថាបងប្រុសរបស់ នេត ផល្លី ត្រូវបានបញ្ជូន ទៅមន្ទីរស-២១ ហើយត្រូវបានសម្លាប់នៅទីនោះ ។ ដំណឹងនេះ បានធ្វើឲ្យ នេត ផល្លី និង ក្រុមគ្រួសារពិបាកចិត្តជាខ្លាំង ។ នេត ផល្លី នៅតែរស់នៅជាមួយនឹងការឈឺចាប់ដ៏ធំធេង ដោយដឹងថា បងប្រុសរបស់គាត់ត្រូវបានសម្លាប់នៅមន្ទីរស-២១ ជាគុកមួយ ដែលអ្នកជាប់ឃុំឃាំងមិនត្រឹមតែត្រូវបានសម្លាប់ទេ ថែមទាំង ត្រូវបានធ្វើទារុណកម្មក្នុងរបៀបដ៏ព្រៃផ្សៃបំផុតទៀតផង ។

**មីសែល សាលីបា**

# តើជនរងគ្រោះអាចអត់ឱនទោសដល់កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមដែរឬទេ?

ក្រោយពីរបបដ៏ខ្មៅងងឹតមួយបានកើតឡើងនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលត្រូវបានគេស្គាល់ថា «កម្ពុជាប្រជាធិបតេយ្យ»នោះ បានឆក់យកជីវិតប្រជាពលរដ្ឋកម្ពុជាស្លូតត្រង់អស់ជិតពីរលាននាក់តាមរយៈការជម្លៀស ការបង្អត់អាហារ ការបង្ខំធ្វើការងារ ការធ្វើទារុណកម្ម ការសម្លាប់ កង្វះខាតឱសថសម្រាប់ព្យាបាលជំងឺ...អំពើទាំងអស់នេះបានកើតឡើងស្ទើរគ្រប់ទីកន្លែងនៅទូទាំងប្រទេសកម្ពុជា ។ ជាលទ្ធផល ជនពិការ កុមារកំព្រា ស្ត្រីមេម៉ាយជាច្រើនលាននាក់រស់នៅប្រកបដោយភាពភ័យខ្លាច និងសេចក្តីលំបាកវេទនា បន្ទាប់ពីរបបខ្មែរក្រហមត្រូវដួលរំលំ ។ ទោះបីជាពេលវេលាកន្លងផុតទៅជិត៣០ឆ្នាំហើយក៏ដោយ ក៏ប៉ុន្តែភាពឈឺចាប់ ភាពភ័យខ្លាច សេចក្តីសោកស្តាយនៅតែដក់ជាប់ក្នុងចិត្តរបស់ជនរងគ្រោះដែលធ្លាប់ឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យជានិច្ច ។ «រៀងរាល់ពេលដែលខ្ញុំនឹកដល់រឿងខ្មែរក្រហម ខ្ញុំមិនអាចទប់ទឹកភ្នែករបស់ខ្ញុំមិនឲ្យហូរចុះបានទេ ។ ខ្ញុំនៅតែនឹកឃើញពីប្តីរបស់ខ្ញុំ...» នេះជាសម្តីរបស់មីង ម៉ាក់ សព្វថ្ងៃរស់នៅខេត្តកំពង់ឆ្នាំង ។

ដោយសារតែមានរឿងរ៉ាវដ៏ឃោរឃៅនិងព្រៃផ្សៃជាច្រើនបានកើតឡើងចំពោះប្រជាជនកម្ពុជាកាលពីជំនាន់ ប៉ុល ពត ។ ទំហំនៃសេចក្តីឈឺចាប់ ទុក្ខលំបាកគ្រប់បែបយ៉ាង ការធ្វើទារុណកម្មដែលជនរងគ្រោះក្រោមរបបខ្មែរក្រហមធ្លាប់រងទទួល គឺពុំអាចនឹងយកអ្វីមកប្រៀបផ្ទឹមបានឡើយ ។ ដូចនេះតើការអត់ឱនទោសចំពោះកម្មាភិបាលខ្មែរក្រហមដែលបានធ្វើបាបផ្ទាល់មកលើប្រជាជនកម្ពុជាអាចកើតមានបានដែរឬទេ? ជាពិសេសទៅទៀតនោះ កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមទាំងនោះ គឺជាមនុស្សដែលរស់នៅក្នុងភូមិឃុំជាមួយជនរងគ្រោះសព្វថ្ងៃ ។ តើអ្នកទាំងពីរនឹងត្រូវប្រឈមមុខដាក់គ្នាបែបណា?

ការលើកលែង ឬអត់ឱនទោសដល់នរណាម្នាក់ បើស្តាប់ទៅវាហាក់ដូចជាងាយស្រួលណាស់សម្រាប់ជនទីបី ។ ប៉ុន្តែធាតុពិតជាក់ស្តែង ពិតជាមិនអាចនឹងអធិប្បាយបាននៅឡើយទេសម្រាប់ជនរងគ្រោះដោយផ្ទាល់ ថាតើពួកគាត់ពិតជាអាចបំភ្លេចនូវរឿងរ៉ាវកន្លងមក ហើយនឹងអាចលើកលែងទោសដល់ជនដៃដល់បានដែរឬយ៉ាងណានោះ ។ ខាងក្រោមនេះគឺជាសម្រង់មតិរបស់ជនរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យទាក់ទងទៅនឹងការអត់ឱនទោសដល់ជនដៃដល់ដែលធ្លាប់បានធ្វើទុក្ខបុកម្នេញពួកគាត់ ។ សព្វថ្ងៃពួកគាត់រស់នៅខេត្តកំពង់ឆ្នាំងៈ

### ១) សោម ម៉ាក់ អាយុ ៦៣ឆ្នាំ

មីង សោម ម៉ាក់ បានបាត់បង់ប្តីដោយសារខ្មែរក្រហមបានយកទៅសម្លាប់ដោយមិនបានដឹងពីមូលហេតុនៃការសម្លាប់នោះទេ ។ មីង ម៉ាក់ បានក្លាយជាស្ត្រីមេម៉ាយ និងត្រូវមើលថែទាំកូនៗទាំងពីររបស់គាត់បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ។ បន្ទុកគ្រួសារទាំងមូលត្រូវធ្លាក់មកលើគាត់ជាអ្នករ៉ាប់រង ។ គាត់បាននិយាយថាៈ «ប្រសិនបើប្តីរបស់មីងនៅរស់ដល់សព្វថ្ងៃ ម្ល៉ោះមីងមិនពិបាកវេទនាយ៉ាងនេះទេ ។ តែឥឡូវមីងត្រូវមើលថែកូនៗដោយខ្លួនឯង» ។ មីង ម៉ាក់ បានរំឭកឡើងវិញថា កាលពីមុនគាត់ធ្លាប់បានជួបមុខខ្មែរក្រហមដែលបានមកហៅប្តីគាត់យកទៅ ។ ប៉ុន្តែខ្មែរក្រហមរូបនោះបានគេចមុខចេញពេលដែលបានឃើញ មីង ម៉ាក់ ពីចម្ងាយ ។ មីង ម៉ាក់ គិតថាប្រហែលជាគាត់ខ្លាច មីង ម៉ាក់ សងសឹកនឹងគាត់ហើយមើលទៅ! មីង ម៉ាក់ នៅតែមិនអាចលើកលែងទោសដល់ជនដៃដល់បាននៅឡើយ ។ ប៉ុន្តែអារម្មណ៍របស់មីង ម៉ាក់ បានធូរស្រាលជាងមុនហើយ ពីព្រោះរឿងរ៉ាវនោះវាកន្លងទៅយូរហើយ ។ ទោះបីជាបច្ចុប្បន្នពេលខ្លះ មីង ម៉ាក់ ចង់ស្តុះទៅវាយតប់ ឬធ្វើបាបជនដៃដល់វិញក៏ដោយ ក៏ប្តីរបស់គាត់មិនអាចវិលត្រឡប់មករកគាត់វិញបានដែរ ។ មីង ម៉ាក់ មានតែខំកាត់ចិត្តតែប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ប្រសិនបើជនដៃដល់ចេញមុខ

មកសុំខមាលទោសនៅចំពោះមុខ មីង ម៉ាក់ អាចរំសាយកំហឹង និង លើកទោសដល់បុគ្គលនោះបានមួយកម្រិត ។ ប៉ុន្តែមិនអាចបាន ទាំងអស់នោះទេ ដោយសារតែរៀងរាល់ពេលដែល មីង ម៉ាក់ ជួប មុខជនដៃដល់ដែលបានមកហៅប្តីគាត់ទៅម្តងៗ ទិដ្ឋភាពនោះ ហាក់ដូចជាហេតុការណ៍ថ្មីៗដែលលេចឡើងនៅចំពោះមុខគាត់ ។

## ២) រស់ លាភ អាយុ ៤៥ឆ្នាំ

មីង លាភ មានបងប្អូនសាច់ញាតិជាច្រើនត្រូវខ្មែរក្រហម យកទៅសម្លាប់ និងខ្លះទៀតស្លាប់ដោយសារតែអត់អាហារនិង ជំងឺ ។ ចម្ងល់ជាច្រើននៅតែដក់ជាប់ក្នុងចិត្តរបស់មីង លាភ ជានិច្ច ។ គាត់ឆ្ងល់ថាមូលហេតុអ្វី បានជាខ្មែរក្រហមយកឪពុកគាត់ទៅ សម្លាប់? ហេតុអ្វីបានជាខ្មែរក្រហមចាប់ប្តីរបស់គាត់ដាក់គុក? មីង លាភ មានការខឹងសម្បានឹងមេកងខ្មែរក្រហមដែលធ្វើបាប ផ្ទាល់មកលើគាត់និងក្រុមគ្រួសាររបស់គាត់ ។ ជោគវាសនារបស់ គាត់កាលពីរបបខ្មែរក្រហម មិនមែនស្ថិតនៅក្នុងកណ្តាប់ដៃរបស់ គាត់ជាអ្នកសម្រេចនោះទេ ។ គាត់ត្រូវបានបង្ខំឲ្យធ្វើការទាំងយប់ ទាំងថ្ងៃទៅតាមការបញ្ជារបស់ខ្មែរក្រហម ។ ប្រជាពលរដ្ឋគ្មានសិទ្ធិ និយាយរិះគន់អង្គការនោះទេ បើមិនដូច្នេះទេនឹងត្រូវអង្គការ ស្នើឲ្យទៅ «រៀនសូត្រ» ជាមិនខាន ។ «រៀនសូត្រ» នៅសម័យខ្មែរ ក្រហមមានន័យថាយកទៅសម្លាប់ ។ សម្លាប់ដោយសារតែ ប្រឆាំងនឹងអង្គការបដិវត្តន៍ ។ ចំពោះ មីង លាភ ហាក់ដូចជាពុំសូវ ខឹងនឹងមេដឹកនាំខ្មែរក្រហមប៉ុន្មានទេ ។ មូលហេតុដែលគាត់ពុំសូវ ខឹងបែបនេះ ដោយសារតែគាត់មិនធ្លាប់បានជួបមុខពួកមេដឹកនាំ ទាំងនោះពីមុនមក ។ មិនតែប៉ុណ្ណោះ មេកងដែលធ្លាប់ធ្វើបាបគាត់ ផ្ទាល់ គឺជាអ្នកដែលរស់នៅក្នុងភូមិស្រុកជាមួយគាត់ មិនគួរណា មេកងមកធ្វើបាបគ្នាឯងនោះទេ ។ ប្រសិនបើមេកងដែលធ្លាប់ធ្វើ បាបគាត់រស់នៅក្នុងភូមិជាមួយគាត់សព្វថ្ងៃ មីង លាភ នឹងមិន និយាយរកទេ ពីព្រោះគាត់មិនចង់ឃើញមុខ ។ មីង លាភ សម្រេច ចិត្តដើរជៀសពីមេកងនោះ ដោយសារតែរៀងរាល់ពេលដែល គាត់បានឃើញមុខមេកង ធ្វើឲ្យគាត់នឹកឃើញរឿងដែលគាត់ធ្លាប់ ត្រូវបានធ្វើបាបកាលពីសម័យខ្មែរក្រហម ។ អ្វីដែល មីង លាភ អាចធ្វើបានគឺនៅឲ្យឆ្ងាយពីមេកង ដើម្បីរំងាប់កំហឹងរបស់គាត់ ។ តែប្រសិនបើមេកងព្រមចេញមកសារភាពកំហុស នោះ មីង លាភ អាចនឹងលើកលែងទោសកំហុសឲ្យបាន ។ មីង លាភ អាចនឹង ត្រឡប់ទៅរាប់អានគាត់ដូចធម្មតាវិញ ។ ជាចុងក្រោយ មីង លាភ បាននិយាយថា ៈ«ធ្វើម៉េចបើគេសុំអភ័យទោសហើយ យើងយក ទោសធ្វើអីទៀត ព្រោះយើងសុទ្ធតែចាស់ៗអស់ទៅហើយដែរ» ។

## ៣) សុខ យ៉ាន អាយុ ៥៨ឆ្នាំ

ឪពុករបស់ពូ សុខ យ៉ាន ត្រូវបានស្លាប់បាត់បង់ជីវិត ដោយសារជំងឺកាលពីជំនាន់ខ្មែរក្រហម ។ រីឯបងថ្លៃរបស់គាត់ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ដោយពុំបានដឹងពីមូលហេតុ ។ រាល់ពេលដែលគាត់នឹកដល់ព្រឹត្តិការណ៍ទាំងនោះម្តងៗ អារម្មណ៍របស់គាត់ហាក់ដូចជាពុះកញ្ជ្រោល ភាពខឹងសម្បានឹង របបខ្មែរក្រហមបានកើតឡើងវិញនៅក្នុងខ្លួនរបស់គាត់ ។ គាត់ត្រូវខ្មែរក្រហមធ្វើបាបបង្ខំឲ្យធ្វើការធ្ងន់ធ្ងរស្ទើរគ្មានពេល សម្រាក ។ ពូ យ៉ាន បានរំឭកប្រាប់ថាៈ «ខ្ញុំខឹងនឹងមេដឹកនាំ ខ្មែរក្រហម ហើយខ្ញុំក៏ខឹងនឹងអ្នកដែលទទួលបញ្ជាពីថ្នាក់លើដែរ ។ ជួនកាលថ្នាក់លើបញ្ជាមកតែត្រឹមនេះទេ តែអ្នកអនុវត្តផ្ទាល់វិញ អាចធ្វើលើសពីអ្វីដែលបានប្រាប់ទៅទៀតមើលទៅ» ។ កាលពីមុន ពូ យ៉ាន ធ្លាប់ខឹងនឹងប្រធានសហករណ៍របស់គាត់ជាខ្លាំង ។ ប៉ុន្តែ កំហឹងទាំងនោះបានរសាយទៅវិញ ដោយសារគាត់រស់នៅឆ្ងាយពី ប្រធានសហករណ៍នោះទេ ។ មិនតែប៉ុណ្ណោះ បច្ចុប្បន្នប្រធាន សហករណ៍របស់ ពូ យ៉ាន បានក្លាយទៅជាអាចារ្យវត្តទៅហើយ ។ ដូចនេះ ពូ យ៉ាន មានតែព្យាយាមសន្តោសនិងរាប់អានគាត់ដូច អ្នកស្គាល់គ្នាធម្មតា ។ ពូ យ៉ាន អាចលើកលែងនិងអត់ឱនឲ្យ ប្រធានសហករណ៍របស់គាត់បាន ប្រសិនបើប្រធានសហករណ៍ របស់គាត់អាចមកសារភាពពីទង្វើខុសឆ្គងរបស់គាត់ប្រាប់ ពូ យ៉ាន ហើយប្រសិនបើគាត់ពេលនោះពិតជាធ្វើតាមការបញ្ជារបស់ថ្នាក់ លើមែននោះ ។ តែប្រសិនបើជាគាត់ធ្វើតាមចិត្តខ្លួនឯងវិញនោះ ពូ យ៉ាន នឹងមិនអាចលើកលែងទោសឲ្យបាននោះទេ ។

## ៤) ប៊ូ ប៊ី អាយុ ៥៤ឆ្នាំ

កាលពីសម័យខ្មែរក្រហម ម្តាយនិងបងប្រុសរបស់ពូ ប៊ី បានស្លាប់បាត់បង់ជីវិតដោយសារតែពុំមានអាហារបរិភោគគ្រប់ គ្រាន់ ។ ចំណែកខ្លួនគាត់ផ្ទាល់ក៏ទទួលរងការលំបាកវេទនាមិនតិច ដែរទេ ។ គាត់ត្រូវខ្មែរក្រហមបញ្ជាឲ្យធ្វើការទាំងយប់ទាំងថ្ងៃរក

ពេលទំនេរសឹងមិនមាន ។ រៀងរាល់ពេលដែលគាត់នឹកឡើងវិញនូវអំពើទាំងឡាយដែលខ្មែរក្រហមបានប្រព្រឹត្តមកលើរូបគាត់ និងក្រុមគ្រួសាររបស់គាត់ អារម្មណ៍ក្តុកក្តួលបានកើតឡើងវិញ ធ្វើឲ្យគាត់នឹកខឹងនឹងមេដឹកនាំខ្មែរក្រហមដែលបានដឹកនាំប្រទេសជាតិទៅរកភាពវិនាសហិនហោច ។ ពូ ប៊ី ហាក់ដូចជាពុំមានការខឹងសម្បានឹងមេកង ឬកម្មាភិបាលថ្នាក់ក្រោមដែលបញ្ជាផ្ទាល់នោះទេ ។ ពូ ប៊ី បាននិយាយថាៈ «មនុស្សគ្រប់រូបមិនមាននរណាចង់ធ្វើខុសនោះទេ ។ នោះដោយសារតែមេដឹកនាំខ្មែរក្រហមបានបំពាក់មនោគមន៍វិជ្ជាមកលើពួកគេ ទើបបានជាពួកគេធ្វើបែបនោះ ។ ហើយប្រសិនបើជនដៃដល់ ឬកម្មាភិបាលថ្នាក់ក្រោមចេញមកសម្តែងភាពស្មោះត្រង់ដោយនិយាយសុំទោសឬសារភាពកំហុសជាសាធារណៈចំពោះមុខមហាជននោះជាទង្វើល្អមួយ ។ នេះបញ្ជាក់ថា ពួកគេហ៊ានបង្ហាញនិងទទួលស្គាល់នូវកំហុសឆ្គងរបស់ខ្លួនដែលបានប្រព្រឹត្តកាលពីសម័យនោះ នោះខ្ញុំអាចនឹងលើកលែងទោសចំពោះពួកគេ» ។

### ៥) សោ សន អាយុ ៦០ឆ្នាំ

បើរំឭកដល់របបខ្មែរក្រហម លោកពូ សន តែងតែនឹកដល់ម្តាយ កូន និងបងៗរបស់គាត់ ដែលបានស្លាប់កាលពីសម័យនោះ ។ អារម្មណ៍ឈឺចាប់បានមកយាយីពូ សន រាល់ពេលដែលគាត់នឹកឃើញរឿងដែលខ្មែរក្រហមវាយធ្វើបាបម្តាយរបស់គាត់ដោយសារតែម្តាយគាត់បានយកបបរមកឲ្យចៅហូប ។ គាត់និយាយទាំងអួលដើមកថាៈ «សូម្បីតែផ្នូរម្តាយរបស់ខ្ញុំ ក៏ខ្ញុំមិនបានឃើញដែរ ។ ខ្ញុំនឹកអាណិតម្តាយខ្ញុំណាស់ ប៉ុន្តែមកដល់ពេលបច្ចុប្បន្ននេះ ខ្ញុំមានតែខំព្យាយាមតាំងចិត្ត ។ ធម៌ហិង្សា និងអហិង្សាជាធម៌របស់ព្រះពុទ្ធ ពៀរំងាប់ដោយការមិនចងពៀរ ។ ព្រោះបើខ្ញុំមិនព្រមយកធម៌ព្រះពុទ្ធមកដាក់ក្នុងចិត្តនោះទេ នោះកំហឹងរបស់ខ្ញុំនឹងអាចកើតមានជារៀងរាល់ថ្ងៃ ដោយសារតែខ្មែរក្រហមដែលបានធ្វើបាបម្តាយខ្ញុំរស់នៅក្នុងភូមិរបស់ខ្ញុំរៀងរាល់ថ្ងៃ» ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ពូ សន នៅតែព្រមបើកទូលាយចិត្តរបស់គាត់ទទួលយកការសារភាពកំហុសពីសំណាក់ជនដៃដល់ជានិច្ច ។ ពូ សន យល់ព្រមលើកលែងទោសឲ្យជនដៃដល់បាន ពីព្រោះពេលវេលាបានកន្លងហួសទៅយូរហើយ ហើយកំហឹងរបស់ ពូ សន ក៏បានរសាយបន្តិចម្តងៗដែរ ។ ពូ សន បានបន្តថាៈ «ប្រសិនបើយើងនៅតែចងកំហឹងនឹងគ្នាបន្តទៀត តើកូនចៅយើងជំនាន់ក្រោយៗអាចរស់នៅប្រកបដោយសេចក្តីសុខបានដែរឬទេ?» ។

រឿងរ៉ាវកាលពីរបបខ្មែរក្រហម នៅតែដិតដាមជាប់ក្នុងចិត្តរបស់ជនរងគ្រោះរហូតមកដល់សព្វថ្ងៃ ។ ពួកគាត់នៅតែមិនអាចបំភ្លេចបាននូវបទពិសោធន៍នៃការនិរាស្តព្រាត់ប្រាសនិងជូរចត់របស់ពួកគាត់បាននៅឡើយ ។ ជាពិសេសទៅទៀតគឺកំហឹងឈឺចាប់ដែលខ្មែរក្រហមបានបន្សល់ទុកឲ្យពួកគាត់ ។ ពួកគាត់ត្រូវប្រឈមមុខនឹងអតីតកាលមួយដែលគួរឲ្យភ័យខ្លាច ប៉ុន្តែពួកគាត់បានជ្រើសរើសយកវិធីសាស្ត្រជាច្រើនមកព្យាបាលនិងកាត់បន្ថយភាពឈឺចាប់របស់ពួកគាត់ ។ ពួកគាត់មួយចំនួនជ្រើសរើសយកការអត់ឱនទោស ប្រសិនបើការសារភាពពីទោសកំហុសដែលកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមបានប្រព្រឹត្តត្រូវបានសម្តែងចេញមក ។ ស្របពេលជាមួយគ្នានោះដែរ ក៏មានជនរងគ្រោះមួយចំនួនផ្សេងទៀតនៅតែមិនអាចបំភ្លេចបាន ហើយសម្រេចចិត្តរស់នៅឲ្យឆ្ងាយពីជនដៃដល់ទាំងនោះ ។ ដូចនេះតើជនរងគ្រោះសម័យខ្មែរក្រហមទាំងអស់ពិតជាអាចអត់ឱនទោសដល់កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមបានដែរឬទេ? តើស្លាកស្នាមដែលកម្ពុជាប្រជាធិបតេយ្យបានបន្សល់ទុកពិតអាចផ្សះផ្សាបានដែរឬទេ?

**ម៉ែន ពិចិត្រ**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧ៈ៣០ ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# ទួលស្លែង និង មន្ទីរស-២១

ខ្ញុំបានចាប់ផ្តើមអានឯកសារដែលយកមកពីសារមន្ទីរទួលស្លែងស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍កាលពីដើមទសវត្សរ៍ ៩០ ហើយចាប់តាំងពីពេលនោះមកខ្ញុំបានអានឯកសាររាប់ពាន់ ហើយខ្ញុំក៏បានផ្តល់បឋកថានិងសិក្ខាសាលាជាច្រើនទាក់ទិននឹងសារមន្ទីរ និងគុករបស់របបកម្ពុជាប្រជាធិបតេយ្យដែលនៅក្នុងរបប ប៉ុល ពត ត្រូវបានគេស្គាល់ថាជា «មន្ទីរស-២១» និងត្រូវប្រើប្រាស់ដើម្បីគ្រប់គ្រងមូលដ្ឋានរបស់ខ្លួន ។ នៅក្នុងសៀវភៅរបស់ខ្ញុំ សំឡេងពីមន្ទីរស-២១ ខ្ញុំបានសង្ខេបការស្រាវជ្រាវរបស់ខ្ញុំ ដោយដកស្រង់ពីឯកសារទាំងនេះ និងពីបទសម្ភាសន៍ជាមួយនឹងជនរងគ្រោះរបស់គុកទួលស្លែង និងមនុស្សជាច្រើនដែលធ្លាប់ធ្វើការនៅទីនោះ ។

សៀវភៅនេះត្រូវបានបកប្រែពីមួយជំពូកទៅមួយជំពូកដែលមាននៅក្នុងទំព័ររបស់ទស្សនាវដ្តីស្វែងរកការពិត (ទស្សនាវដ្តីប្រចាំខែរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ក្នុងឱកាសខ្លះ ប្រជាជនកម្ពុជាបានធ្វើឲ្យខ្ញុំយល់ថា មន្ទីរស-២១ ត្រូវបានបង្កើតឡើងដោយវៀតណាមដើម្បីបន្ទុចកេរ្តិ៍ឈ្មោះប្រជាជនកម្ពុជា និងដើម្បីចោទប្រកាន់ប្រជាជនកម្ពុជាទាំងអស់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ គ្មានប្រជាជនកម្ពុជាណាម្នាក់ដែលនិយាយជាមួយខ្ញុំថាអាចជាស្នាដៃរបស់ «ខ្មែរក្រហម» ឡើយ ។

ខ្ញុំតែងតែឆ្លើយតបទៅកាន់ប្រជាជនកម្ពុជាទាំងនេះថា ខ្ញុំជឿថាការណែនាំរបស់ពួកគេគឺយល់ខុសហើយ ។ ខ្ញុំគិតថា ការ



ទិដ្ឋភាពនៅក្នុងអគារមន្ទីរស-២១

ខិតខំប្រឹងប្រែងក្នុងការបង្កើតមន្ទីរស-២១ អាចនឹងចំណាយទឹកប្រាក់ច្រើន និងមានសភាពស្មុគស្មាញសម្រាប់វៀតណាម ។ ឧទាហរណ៍ វៀតណាមមិនមានធនធានដើម្បីចងក្រងជាឯកសារដែលបានរកឃើញនៅបណ្ណសារដ្ឋានក្នុងមន្ទីរស-២១ និងឯកសាររាប់ពាន់ដែលជាប់ពាក់ព័ន្ធនឹងមន្ទីរស-២១ ដែលត្រូវបានរកឃើញនៅទីកន្លែងផ្សេងៗក្នុងទីក្រុងភ្នំពេញ (បន្ទាប់ពីវៀតណាមចាកចេញទៅ) និងមិនមានធនធានដើម្បីប្រឌិតឈ្មោះនិងប្រវត្តិរូបអ្នកធ្វើការនៅក្នុងគុក កែច្នៃបន្ទំភ័ស្តុតាងជារូបថត និងប្រឌិតប្រវត្តិរូបជនរងគ្រោះ និងអតីតអ្នកធ្វើការនៅតាមអគារឡើយ ។ បន្ថែមពីលើនេះ ប្រសិនបើវៀតណាមបានរៀបចំប្រតិបត្តិការបែបនេះមែននោះ វាអាចថាអ្នកដែលចូលរួមជាមួយនឹងប្រតិបត្តិការនេះប្រហែលនឹងនិយាយពីរឿងរ៉ាវនេះហើយ ជាពិសេសក្រោយពេលដែលវៀតណាមដកទ័ពរបស់ពួកគេចេញកាលពីឆ្នាំ១៩៨៩ ។

ដើម្បីឲ្យប្រាកដ ការជំរុញឲ្យប្រែក្លាយគុកទួលស្លែងមកជាសារមន្ទីរមួយនេះគឺជាគំនិតរបស់វៀតណាម ដែលស្ថិតនៅក្រោមការដឹកនាំរបស់វរសេនីយ៍ឯកវៀតណាម ម៉ៃ ឡាម បច្ចុប្បន្នកំពុងតែចូលនិវត្តន៍ និងរស់នៅក្នុងទីក្រុងហូជីមិញ ។ ម៉ៃ ឡាម ត្រូវបានសម្ភាសន៍ជាច្រើនលើក ។ គាត់បាននិយាយថា គាត់មានមោទកភាពសម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់គាត់ក្នុងការប្រែក្លាយបរិវេណមន្ទីរស-២១មកជាសារមន្ទីរមួយសម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ជាមួយគ្នានេះដែរ គាត់ក៏មានភាពរីករាយដែលបានប្រែក្លាយវាលពិឃាតនៅជើងឯកជាកន្លែងដែលអ្នកទោសលើសពី១០,០០០នាក់មកពីមន្ទីរស-២១ ត្រូវបានសម្លាប់នោះមកជាទិសដៅដំណើរទេសចរណ៍ដ៏គួរឲ្យភ័យខ្លាចមួយ ។

វៀតណាមស្ថាបនាសារមន្ទីរនៅឯទួលស្លែងក្នុងអំឡុងឆ្នាំ១៩៧៩-១៩៨០ ដោយសារមូលហេតុមួយចំនួន។ សម្រាប់មូលហេតុទីមួយ ខ្ញុំជឿថា វាពិតជាមានសារៈសំខាន់សម្រាប់វៀតណាមក្នុងការបន្សល់ទុកនូវកេរដំណែលសម្រាប់វត្តមានរបស់គេនៅក្នុងប្រទេសកម្ពុជា និងកេរដំណែលរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយហេតុផលថា វៀតណាមបានរំដោះប្រទេសកម្ពុជាឲ្យរួចផុតពី «បក្សពួកអំពើប្រល័យពូជសាសន៍» របស់ប៉ុល ពត និង អៀង សារី ដែលត្រូវបានកាត់ទោសនិងផ្តន្ទាទោសប្រហារជីវិតក្នុងខែសីហា ឆ្នាំ១៩៧៩ ។ ជាមួយគ្នានេះផងដែរ វាក៏មានសារៈសំខាន់សម្រាប់វៀតណាមនិងសហព័ន្ធរបស់គេនៅក្នុងក្រុមសូវៀតក្នុងការធ្វើឲ្យបក្សកុម្មុយនីស្តវៀតណាមនិងដៃគូកម្ពុជារបស់ខ្លួនឃ្លាតឆ្ងាយពីរបបកុម្មុយនីស្តរបស់កម្ពុជាប្រជាធិបតេយ្យ ។ វាពិតជាមានសារៈសំខាន់សម្រាប់វៀតណាមនិងសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងការដាក់ឈ្មោះឲ្យរបបកម្ពុជាប្រជាធិបតេយ្យថាជារបប «ហ្វាស៊ីស» ដូចរបបណាហ្ស៊ីរបស់ប្រទេសអាល្លឺម៉ង់ ជាជាងដាក់ឈ្មោះថាជារបបកុម្មុយនីស្តមួយដែលត្រូវបានទទួលស្គាល់ដោយប្រទេសកុម្មុយនីស្តជាច្រើនទៀត ។ ចុងក្រោយបង្អស់ វាពិតជាមានសារៈសំខាន់សម្រាប់វៀតណាមដើម្បីជំទាស់នឹងអ្វីដែលបានកើតឡើងក្នុងប្រទេសកម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងជាពិសេសនៅមន្ទីរស-២១ ជាកន្លែងសម្រាប់អំពើប្រល័យពូជសាសន៍ដែលប្រហាក់ប្រហែលនឹងសោកនាដកម្មក្នុងសង្គ្រាមលោកលើកទីពីរជាជាងកន្លែងសម្រាប់សម្លាប់ខ្មាំងនយោបាយដែលកើតឡើងក្នុងពេលខុសគ្នាបានដក់ជាប់នៅក្នុងប្រវត្តិសាស្ត្ររបស់សហភាពសូវៀត កុម្មុយនីស្តចិន និង កុម្មុយនីស្តវៀតណាមដែរ ។

វៀតណាមស្ថាបនាមន្ទីរស-២១ជាសារមន្ទីរដោយប្រើប្រាស់ឯកសារយ៉ាងច្រើនដែលបានបន្សល់ទុកនៅបរិវេណមន្ទីរស-២១ ។ ស្រដៀងគ្នានេះដែរ វៀតណាមបានប្រែក្លាយជើងឯកជាទិសដៅទេសចរណ៍ក្រោយពីបានជីកកកាយសាកសពរាប់ពាន់នៅទីនោះរួចមក ។ មិនមែនដោយសារតែករណីនេះទេដែលប្រទេសវៀតណាមបង្កើតស្ថាប័ន (មន្ទីរស-២១) នេះឡើង ។ ផ្ទុយទៅវិញ ឯកសារដែលមាននៅក្នុងបណ្ណសារដ្ឋានរបស់មន្ទីរស-២១ រូបថតរបស់អ្នកទោសនិងបទសម្ភាសន៍ដែលត្រូវបានធ្វើជាមួយនឹងជនរងគ្រោះ និងអតីតអ្នកធ្វើការនៅក្នុងគុកទាំងអស់នេះបានធ្វើឲ្យខ្ញុំជឿជាក់ថា មន្ទីរស-២១គឺជាស្ថាប័នរបស់កម្ពុជាដែលមានតួនាទីបម្រើដល់គោលដៅនៃរបបដ៏គួរឲ្យភ័យខ្លាចនិងគោលដៅរបស់មេដឹកនាំនៃរបបនោះ និងគោលដៅនៃរបបកម្ពុជាដ៏គួរឲ្យព្រឺរន្ធត់ ។

**ដេវីដ ឆេនដល័រ**

# ដេវីដ ឆេនដល័រ សាក្សីជំនាញបានផ្តល់សក្ខីកម្មពីមន្ទីរស-២១

## មន្ទីរស-២១ គឺជាមន្ទីរអមនុស្សធម៌និងស្វយ័ត

អ្នកជំនាញប្រវត្តិសាស្ត្រកម្ពុជាដ៏ល្បីល្បាញ លោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ អាយុ ៧៦ឆ្នាំ បានស្រាវជ្រាវយ៉ាងធំទូលាយពីប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៦០ ខណៈពេលដែលគាត់ធ្វើការជាអ្នកការទូត ។ ក្នុងតុលាការកាត់ទោស កាំង ហ្គេកអ៊ាវ ហៅ (ឌុច) ដេវីដ ឆេនដល័រ ភាគច្រើនបានផ្តល់សក្ខីកម្មទាក់ទិននឹងសៀវភៅរបស់គាត់គឺ សំឡេងពីមន្ទីរស-២១ ៖ ភាពភ័យខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត ។ ដើម្បីសរសេរសៀវភៅនេះបាន សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ បានចំណាយពេលស្រាវជ្រាវសរុបចំនួនបួនឆ្នាំកាលពីទសវត្សរ៍៩០ អានចម្លើយសារភាពរបស់អ្នកទោសចំនួនលើសពី១០០០នាក់និងសម្ភាសន៍ជនរងគ្រោះពីមន្ទីរស-២១ និងសន្តិសុខយាមគុកជាច្រើននាក់ ។

លោក ដេវីដ ឆេនដល័រ បានផ្តល់សក្ខីកម្មថា មន្ទីរស-២១ គឺជាគុកអមនុស្សធម៌និងជាគុកស្វយ័តមួយដែលបង្កើតឡើងសម្រាប់ស្វែងរកខ្មាំងដែលមានបំណងបំផ្លាញបដិវត្តន៍ និងដែលលាក់ខ្លួនក្នុងចំណោមកម្មាភិបាលនិងប្រជាជន ។ លោក ដេវីដ ឆេនដល័រ យល់ឃើញថា មន្ទីរស-២១ពោរពេញដោយភាពអមនុស្សធម៌ដោយសារតែអ្នកទោសទាំងអស់ត្រូវបានធ្វើទារុណកម្មនិងបង្ខំឲ្យសរសេរចម្លើយសារភាព ចំណែកឯសន្តិសុខយាមគុកមិនមានសេរីភាពទាល់តែសោះ ហើយគ្រប់គ្នារស់នៅក្នុងសភាពភាពភ័យខ្លាចជាបន្តបន្ទាប់ ។



សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ

លោក ដេវីដ ឆេនដល័រ បានចាត់ទុកមន្ទីរស-២១ ជាស្ថាប័នស្វយ័តមួយដោយសារតែមនុស្សនៅក្នុងមន្ទីរស-២១ នេះបានរស់នៅឯកោដាច់ដោយឡែកពីសហគមន៍ផ្សេងៗនិងគ្មានព័ត៌មានចេញពីមន្ទីរនេះត្រូវបានផ្សព្វផ្សាយទៅកាន់ពិភពលោកខាងក្រៅឡើយ ។ ដោយគាំទ្រការស្រាវជ្រាវទាក់ទិននឹងស្វ័យភាពនេះ លោក ដេវីដ ឆេនដល័រ បានកត់សម្គាល់ឃើញថា ការសម្ងាត់គឺជាលក្ខណៈដឹកនាំស្នូលរបស់ខ្មែរក្រហម ហើយមន្ទីរស-២១មិនត្រូវបានផ្សាយជាសាធារណៈឡើយ ។ ទំនាក់ទំនងមានតែរវាងមន្ទីរស-២១ ជាមួយនឹងរដ្ឋាភិបាលខ្មែរក្រហមប៉ុណ្ណោះ ។

ជាមួយគ្នានេះផងដែរ លោក ដេវីដ ឆេនដល័រ បានដកស្រង់ពាក្យសម្តីរបស់ នួន ជា ដែលបានប្រាប់គណៈប្រតិភូប្រទេសដេនម៉ាក កាលពីខែកក្កដា ឆ្នាំ១៩៧៨ ថា «ការសម្ងាត់ គឺជាកត្តាចម្បងបំផុតនៃការដឹកនាំរបស់ខ្មែរក្រហម» ។

## ការកសាងខ្លួនកម្មាភិបាលខ្មែរក្រហម

ក្នុងការឆ្លើយតបទៅកាន់សំណួមពររបស់ចៅក្រម ខាត ព្រ៊ាយត៍ សម្រាប់ទស្សនៈទូទៅអំពីមន្ទីរស-២១ លោក ដេវីដ ឆេនដល័រ បាននិយាយថា ខ្មែរក្រហមបានបង្កើតមន្ទីរស-២១ នេះឡើងដើម្បីធ្វើការគ្រប់គ្រងលើខ្មាំងផ្ទៃក្នុង ។ ភាពសង្ស័យថាមានខ្មាំងផ្ទៃក្នុងបានជំរុញឲ្យមេដឹកនាំខ្មែរក្រហមធ្វើការកសាងខ្លួនលើកម្មាភិបាលណាដែលប្រឆាំងនឹងគោលនយោបាយរបស់គេ ។ ដោយចោទប្រកាន់ថាជាអ្នកយកការណ៍ សេ អ៊ី អា និងភ្នាក់ងារ កា.ហ្សេ.បេ ឬថាមានជាប់ពាក់ព័ន្ធជាមួយនឹងវៀតណាម ខ្មែរក្រហមបានកសាងខ្លួនកម្មាភិបាលដែលមិនមានចិត្តស្មោះត្រង់កាលពីចុងឆ្នាំ១៩៧៦ នៅតាមភូមិភាគឧត្តរនិងបូព៌ា ។ ឧទាហរណ៍ក្នុងអំឡុងពេលនោះ កុយ ធួន លេខាភូមិភាគឧត្តរ ត្រូវបានយក

មកកសាងខ្លួននិងបញ្ជូនទៅមន្ទីរស-២១ សម្រាប់ចម្លើយសារភាព និងការសម្លាប់តាមលំដាប់ ។ បន្ថែមលើនេះ កម្មាភិបាលណាដែលស្មោះស្ម័គ្រនឹង កុយ ធួន ក៏ជួបនឹងវាសនាអាក្រក់ដូចគ្នាដែរ ។ ចំនួនអ្នកទោសនៅមន្ទីរស-២១ បានកើនខ្ពស់បំផុតនៅឆ្នាំ១៩៧៧ ខណៈពេលដែល «ខ្មាំង» ដែលមានចំនួនលើសពី៥០០០នាក់ត្រូវបាននាំមកកាន់ទីនេះ ។ នៅដំណាក់កាលបន្ទាប់មកទៀត កម្មាភិបាលដែលមកពីភូមិភាគបូព៌ា និងនិរតីក៏ត្រូវបានបញ្ជូនមកកាន់មន្ទីរស-២១ដែរ ។

## បញ្ជាឲ្យសម្លាប់

លោក ដេវីដ ឆេនដល័រ បាននិយាយថា សេចក្តីសម្រេចដែលសរសេរដោយគណៈកម្មាធិការមជ្ឈិមរបស់ខ្មែរក្រហមកាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ បានបណ្តាលឲ្យមានការសម្លាប់ដ៏ធំ ។ គណៈកម្មាធិការមជ្ឈិមជឿថា ខ្មាំងផ្ទៃក្នុងមាននៅគ្រប់ទីកន្លែងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយខ្មាំងទាំងអស់នោះត្រូវតែ «កម្ទេច» ចោល ។ ក្នុងការឆ្លើយតបរបស់ ឌុច កាលពីព្រឹក ឌុច ក៏បានកត់សម្គាល់ពីសារៈសំខាន់នៃសេចក្តីសម្រេចខែមីនា ឆ្នាំ១៩៧៦នេះថា ៖ «មុនសេចក្តីសម្រេចនេះ ការចាប់ខ្លួនសង្កត់ធ្ងន់តែទៅលើអតីតមន្ត្រីរដ្ឋាភិបាល លន់ នល់ ដូចជាទាហាន គ្រូបង្រៀន និងមន្ត្រីផ្សេងៗទៀតប៉ុណ្ណោះ ។ ក្រោយពីខែមីនា ឆ្នាំ១៩៧៦ ការចាប់ខ្លួនត្រូវដាក់គោលដៅលើខ្មាំងផ្ទៃក្នុង ឧទាហរណ៍ សមាជិកបក្ស និងមន្ត្រីជាន់ខ្ពស់ ។

## អ្នកគ្រប់គ្រងដ៏មានសមត្ថភាព និងអង់អាចក្លាហាន

ក្នុងអំឡុងសវនាការពេលរសៀល ដើមបណ្តឹងរដ្ឋប្បវេណីបានសួរទៅកាន់សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ទាក់ទិននឹងការគ្រប់គ្រងរបស់ ឌុច នៅមន្ទីរស-២១ ។ ដោយយោងតាមការស្រាវជ្រាវរយៈពេលច្រើនឆ្នាំ លោក លោក ដេវីដ ឆេនដល័រ បានចាត់ទុក ឌុច ថាជាអ្នកគ្រប់គ្រងដែលមានមោទកភាពនិងខិតខំម្នាក់ ។ ឌុច បានអនុវត្តវិធីសាស្ត្រគ្រប់គ្រងគុកដោយបាតដៃទទេ ពីព្រោះថាគ្មានការអនុវត្តប្រតិបត្តិការបែបនេះក្នុងរបបកម្ពុជាប្រជាធិប-តេយ្យពីមុនមកទេ ។ លោក ដេវីដ ឆេនដល័រ បានសម្គាល់ថា គំនិតច្នៃប្រឌិតដែលកើតឡើងជាបន្តបន្ទាប់និងការអភិវឌ្ឍក្នុងដំណើរការមន្ទីរស-២១របស់ ឌុច គួរតែកើតឡើងដោយគ្មានភាពភ្ញាក់ផ្អើលអ្វីឡើយ ។ ក្នុងជីវិតរបស់គាត់ ឌុច តែងតែសម្រេចចង់បាននូវឧត្តមភាពក្នុងនាមជាសិស្ស កូនជាង និងក្នុងជីវិតប្រកបដោយទេពកោសល្យរបស់គាត់នៅឯមន្ទីរស-២១ ។ ឌុច មិនចង់បម្រើបដិវត្តន៍ទេ ។ ឌុច ចង់បម្រើការងារដែលត្រូវនឹងជំនាញ និងភាពរីករាយដែលនឹងធ្វើឲ្យគាត់មានមោទកភាពចំពោះខ្លួនឯង ។

## អំពើអមនុស្សធម៌លើអ្នកទោសមន្ទីរស-២១

ខណៈពេលដែលត្រូវបានសួរទាក់ទិននឹងដំណើរការនៃអំពើអមនុស្សធម៌លើអ្នកទោស ភ្លាមៗនោះ លោក ដេវីដ ឆេនដល័រ សម្គាល់ឃើញថាអំពើអមនុស្សធម៌គឺជាបាតុភូតគោលមួយ ។ លោក ដេវីដ ឆេនដល័រ បានបង្ហាញឲ្យឃើញពីវិធីសាស្ត្រដែលសង្គមមួយចំនួនប្រើពាក្យប្រយោលដើម្បីបញ្ចៀសការពិតនៃសង្គ្រាម ឧទាហរណ៍ «ការរាប់ចំនួនសាកសព» «ការខូចខាតផ្នែករូបរាងកាយ» និង «ការកម្ទេច» ។ បន្ថែមពីលើនេះ ភាពឃោរឃៅមិនត្រូវប្រព្រឹត្តដោយមនុស្សប្រភេទខុសគេខ្លះនៅក្នុងទឹកដីដែលឆ្ងាយដាច់សង្វែងមួយនោះទេ ប៉ុន្តែផ្ទុយទៅវិញដោយមនុស្សធម្មតាដែលឋិតនៅក្រោមលក្ខខណ្ឌដ៏សាមញ្ញបំផុត ។ លក្ខខណ្ឌទាំងនេះបានកើតមានឡើងនៅឯមន្ទីរស-២១ ៖ ដោយរួមបញ្ចូលឥរិយាបថដើមនៃអំពើហិង្សាដោយគ្មានប្រព័ន្ធដាក់ទណ្ឌកម្មសម្រាប់អំពើដែលអាចទទួលទណ្ឌកម្មធម្មតាបាន បុគ្គលិកមន្ទីរស-២១ក៏ចាប់ផ្តើមធ្វើសកម្មភាពដោយភាពរីករាយពេញចិត្តនឹង «បដិវត្តន៍» លើ «ខ្មាំង» ដោយអមនុស្សធម៌ ។ លោក ដេវីដ ឆេនដល័រ បានប្រៀបធៀបខ្មែរក្រហមទៅនឹងទីកជ្រោះដែលមនុស្សគ្រប់គ្នាត្រូវបានទទួលទណ្ឌកម្ម ដោយសារតែពួកខ្មែរក្រហមប្រព្រឹត្តសកម្មភាពរបស់ខ្លួនដោយមានជំនឿទុកចិត្តដ៏ផ្តាច់ការក្នុងការអនុវត្តគោលនយោបាយរបស់គេ ។

អ្នកទោសខ្លះមិនត្រូវការភាពអមនុស្សធម៌ឡើយ ពីព្រោះខ្មែរក្រហមបានចាត់ទុកប្រជាជនវៀតណាមថាស្ថិតនៅក្រៅពូជសាសន៍មនុស្សទាំងស្រុងរួចទៅហើយ ។ លោក ដេវីដ ឆេនដល័រ បានសម្គាល់ថាស្ត្រីជនជាតិវៀតណាមអាស្រ័យលើមូលហេតុខាងលើ គឺជាក្រុមមនុស្សដែលងាយនឹងទទួលរងគ្រោះដោយអំពើហិង្សាផ្លូវភេទធ្ងន់ធ្ងរជាងគេបង្អស់ ។ បន្ថែមពីលើនេះ ភាពអមនុស្សធម៌បានចាប់ផ្តើមកើតឡើងលើរថយន្តតាមផ្លូវឆ្ពោះមកកាន់មន្ទីរ

ស-២១ ។ អ្នកទោសត្រូវបានចាត់ទុកនិងទទួលរងអំពើពីមនុស្ស ដូចសំរាម ។ មនោសញ្ចេតនាដូចជាការអត់ឱនមេត្តាករុណា ពិតជាមិនមានតម្លៃនៅក្នុងជញ្ជាំងមន្ទីរស-២១ឡើយ ។ គុកនេះ មានតួនាទីសួរចម្លើយនិងសម្លាប់អ្នកទោសតែមួយមុខគត់ ។ ខណៈ ពេលដែលស្ថិតនៅក្នុងជញ្ជាំងមន្ទីរស-២១ លក្ខខណ្ឌអមនុស្សធម៌ ត្រូវបានតាំងតែងឡើងដើម្បីបន្តបំបែកអ្នកទោស ។

## យើងមិនគួរសង្ឃឹងមើលឲ្យហួសពីខ្លួនយើងទេ

ស្របពេលដែលមេធាវីការពារក្ដី លោក ការ សាវុត្ថ មាន បំណងធ្វើឲ្យបាត់បង់ជំនឿលើលោក ដេវីដ ឆេនដល័រ ដោយសារ តែកង្វះខាតឯកសារទាក់ទិននឹងទស្សនៈខ្លះរបស់គាត់នោះ មេធាវី ការពារក្ដី លោក ហ្វ្រង់ស័រ រូហ្ស សប្បាយរីករាយនឹងអនុញ្ញាតឲ្យ អ្នកជំនាញការម្នាក់នេះពន្យល់ពីប្រធានបទទាំងនោះដូចជា ការទទួលស្គាល់កំហុស ខ្សែច្រវាក់នៃបទបញ្ជា និង «ឧក្រិដ្ឋកម្មនៃ ការស្លាប់ឱវាទ» ។ ខណៈពេលដែលត្រូវបានសួរពីការទទួលខុស ត្រូវរបស់ ឌុច សម្រាប់ឧក្រិដ្ឋកម្មនៅមន្ទីរស-២១ លោក ដេវីដ ឆេនដល័រ បានឆ្លើយតបថាការទទួលស្គាល់នេះវាធ្វើឲ្យគាត់មាន អារម្មណ៍កោតសរសើរនិងពេញចិត្ត ហើយការទទួលស្គាល់នេះ អាចនឹងមានប្រយោជន៍ដល់ប្រវត្តិសាស្ត្រ ។

ខណៈពេលដែលត្រូវបានសួរពីការនិយាយរៀបរាប់របស់ ឌុច ដែលថា «គាត់គឺជាឈ្លើយនិងជាអ្នកប្រព្រឹត្តនៅក្នុងរបប ឧក្រិដ្ឋកម្មមួយនេះ លោក ដេវីដ ឆេនដល័រ បានសម្គាល់ដោយ ភាពឆ្លាតវៃថា ភាពសោកស្ដាយរបស់ ឌុច បានកើតឡើងក្នុង អំឡុងប្រាំមួយខែចុងក្រោយនៃសម័យកម្ពុជាប្រជាធិបតេយ្យ ហើយការសោកស្ដាយនេះក៏មិនបានបណ្ដាលឲ្យគាត់ចាកចេញពី ចលនាក្នុងឆ្នាំ១៩៧៩ ឬ១៩៨០ដែរទេ។

ទាក់ទិនជាមួយនឹងអ្វីដែលហៅថា «ឧក្រិដ្ឋកម្មនៃការស្ដាប់ ឱវាទ» លោក ដេវីដ ឆេនដល័រ បានទទួលស្គាល់ថាក្នុងអំឡុងសម័យ កម្ពុជាប្រជាធិតេយ្យ អ្នកដែលមានមុខតំណែងកាន់អំណាចអាច ចេញបញ្ជា អ្នកដែលទទួលបញ្ជាត្រូវគោរពគេ ហើយសំណួរ ទាក់ទិននឹងអំណាចតិចតួចណាស់បានកើតឡើងនៅតាមថ្នាក់ ។ លោក ដេវីដ ឆេនដល័រ បានបន្តទៀតដោយកត់សម្គាល់ថា ខណៈ ពេលដែលការស្ដាប់ឱវាទមិនបានពន្យល់អ្វីគ្រប់យ៉ាងទាំងអស់ នោះ វាក៏អាចជួយពន្យល់ពីបរិបទនេះយ៉ាងច្បាស់ដែរ ។ ដោយ ទាញភ្ជាប់ភាពស្រដៀងគ្នានឹងអំពើសាហាវឃោរឃៅដទៃផ្សេង ទៀត លោក ដេវីដ ឆេនដល័រ បាននិយាយថាមេរៀនពីការ សម្លាប់ជនជាតិជ្វីហ្វដ៏គួរឲ្យខ្លាចជាងគេបំផុតនេះគឺថា វាអាចធ្វើមក លើយើងទាំងអស់គ្នាបាន យ៉ាងណាមិញ យើងក៏អាចធ្វើវាទៅ លើមនុស្សដទៃផ្សេងទៀតបានដែរ ។


មេធាវីការពារក្ដីអន្តរជាតិ ហ្វ្រង់ស័រ រូ

លោក ហ្វ្រង់ស័រ រូហ្ស បានបន្តលើសេចក្ដីអធិប្បាយរបស់ លោក ដេវីដ ឆេនដល័រ ដោយដកស្រង់ពាក្យមួយឃ្លាពីសៀវភៅ របស់គាត់ «យើងមិនគួរសម្លឹងមើលឲ្យហួសពីខ្លួនយើងទេ» ដោយ បញ្ជាក់ន័យថា ឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅមន្ទីរស-២១ អាចនឹង ត្រូវបានប្រព្រឹត្តដោយនរណាម្នាក់ក៏បានដែរនៅក្នុងកាលៈទេសៈ បែបនោះ។ លោក ដេវីដ ឆេនដល័រ បានបន្តជឿលើពាក្យសម្ដី ដកស្រង់នេះដោយបញ្ជាក់ពីជំនឿរបស់គាត់ថា ដាច់ខាតមនុស្ស គ្រប់គ្នាអាចនឹងក្លាយជាមនុស្សសាហាវបានបើពិចារណាទៅតាម កាលៈទេសៈ ។ យ៉ាងណាមិញ លោក ដេវីដ ឆេនដល័រ បាននិយាយ ថាតួនាទីរបស់មនុស្សសាហាវតែមួយមុខមិនដូចនឹងការសម្ដែង នូវភាពសាហាវទេ បើមិនដូច្នោះទេ យើងទាំងអស់គ្នាអាចនឹង ត្រូវជាប់គុកជាពុំខាន ។ ខណៈពេលដែលយើងទាំងអស់គ្នាអាចនឹង ក្លាយជាមនុស្សសាហាវបាននោះ តួនាទីតែមួយមុខដើម្បីប្រព្រឹត្ត ភាពសាហាវនោះមិនបានដាក់ពិរុទ្ធភាពលើបុគ្គលឡើយ ហើយជា ការឆ្លើយតប វាក៏មិនបានធ្វើឲ្យអ្នកអនុវត្តតួនាទីនោះរួចទោសបាន ដែរ ។ **ញាណ សុជាតិ**

# វេទិកាពិភាក្សាកម្រិតមូលដ្ឋាន : ភូមិស្វាយឃ្លាំង

ភូមិស្វាយឃ្លាំងដែលមានទីតាំងស្ថិតក្នុងខេត្តកំពង់ចាម គឺជាសហគមន៍ចាមដ៏ធំមួយដែលមានប្រវត្តិសាស្ត្រយ៉ាងសម្បូរបែបនិងកកើតជាយូរណាស់មកហើយ ។ ក្រុមដឹកនាំការបះបោរនិងអ្នកស្រាវជ្រាវជនជាតិចាមសំខាន់ៗជាច្រើនមានកំណើតនៅក្នុងភូមិនេះ ហើយទីនេះគឺជាទីតាំងមួយដែលជនជាតិចាមបានធ្វើការបះបោរប្រឆាំងនឹងការធ្វើទុក្ខបុកម្នេញពីសំណាក់ខ្មែរក្រហមកាលពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ទុក្ខវេទនារបស់ជនជាតិចាមទាំងនោះមានសភាពធំធេងណាស់នៅក្នុងរបបខ្មែរក្រហម ហើយជនជាតិចាមប្រមាណតែ៦០០នាក់ប៉ុណ្ណោះក្នុងចំណោម ២២០០នាក់ ដែលអាចរស់រានមានជីវិតពីរបបខ្មែរក្រហម ។ កាលពីថ្ងៃអាទិត្យទី២៥ ខែតុលា ឆ្នាំ២០០៩ កន្លងទៅ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកវេទិកាសាធារណៈមួយនៅក្នុងភូមិស្វាយឃ្លាំងនេះ ។ គោលបំណងនៃវេទិកានេះគឺដើម្បីជូនដំណឹងដល់អ្នកភូមិទាំងអស់អំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយនិងដើម្បីផ្តល់ឱកាសដល់អ្នកភូមិក្នុងការដាក់ពាក្យបណ្តឹងទៅអង្គជំនុំជម្រះនេះផង ។

វេទិកានេះបានចាប់ផ្តើមឡើងប្រកបទៅដោយភាពរស់រវើកនិងមានការចូលរួមយ៉ាងសស្រាក់សស្រាំពីសំណាក់អ្នកភូមិជាច្រើន ។ បើតាមគម្រោងកម្មវិធីដំបូងនៃវេទិកានេះគឺការបញ្ចាំងខ្សែភាពយន្តអំពីសន្តិសុខ ឌុច នៅក្នុងផ្ទះមួយ ហើយក្រោយមកកម្មវិធីនេះបានលុបចោលទៅវិញដោយសារតែប្រជាជនមកចូលរួមមានចំនួនច្រើនពេក ។ កូនចៅអ្នកភូមិមានសេចក្តីរីករាយជាពន្លឺកហើយបានរត់សំដៅមកក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលដែលក្រុមការងារចែកនំនិងស្ករគ្រាប់ដល់ក្មេងៗទាំងនោះ ។ សកម្មភាពនោះធ្វើឲ្យក្មេងៗមានការសប្បាយរីករាយឥតឧបមា ។ ក្រោយវេទិកាបានផ្លាស់ពីផ្ទះដែលគ្រោងទុកទៅកាន់ទីវាលមុខម៉ាស្ជិទ (វិហារអ៊ីស្លាម) វិញ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា កញ្ញា សើ សាយ្យាណា បានបើកកម្មវិធីស្វាគមន៍អ្នកភូមិក្នុងនាមមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្រោយមក លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ បាននិយាយទៅកាន់អ្នកភូមិដែលឈរស្តាប់យ៉ាងកកកុញនៅពេលដែលគាត់ធ្វើការណែនាំជាសង្ខេបអំពីសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ» ។ ក្រោយមកក៏មានការចែកជូនសៀវភៅប្រវត្តិសាស្ត្រនេះ ទស្សនាវដ្តីស្វែងរកការពិត និងកូនសៀវភៅតូចដែលមានចំណងជើងថា «ការកាត់ទោសមេដឹកនាំខ្មែរក្រហម» ព្រមទាំងឯកសារផ្សេងទៀតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៅកាន់អ្នកភូមិផងដែរ ។


កុមារឥស្លាមនៅភូមិស្វាយឃ្លាំងមើលសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ក្រោយពីចែកជូនសៀវភៅនិងឯកសារទាំងនោះរួច លោក ជី ទេរិទ្ធ ដែលជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានរៀបរាប់អំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម និងរៀបរាប់ដោយត្រួសៗអំពីជនជាប់ចោទទាំងប្រាំនាក់ដែលកំពុងតែត្រូវចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញ ។ លោក ជី ទេរិទ្ធ ក៏បានបកស្រាយប្រាប់អ្នកភូមិអំពីទុក្ខវេទនាដែលជនជាតិចាមទូទៅបានទទួលរងកាលពីជំនាន់ខ្មែរក្រហមដែរ ។ ទុក្ខវេទនាទាំងនោះរួមមានការហាមឃាត់ក្នុងការប្រណិប័តន៍សាសនា ការបង្ខំឲ្យហូបសាច់ជ្រូក ហើយស្ត្រីត្រូវបានបង្ខំឲ្យកាត់សក់ខ្លីនិងហាមមិនឲ្យទទូរកន្សែងលើក្បាល និងការបំផ្លិចបំផ្លាញផ្នូរចាម ដែលទង្វើទាំងនេះជាការប្រឆាំងនឹងសាសនាអ៊ីស្លាម ។ លោក ជី ទេរិទ្ធិ បានបញ្ជាក់ទៀតថាដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញធ្វើការពិចារណាចំពោះការធ្វើទុក្ខបុកម្នេញលើជនជាតិចាមជនរងគ្រោះត្រូវតែដាក់ពាក្យ

បណ្ដឹងទៅអង្គជំនុំជម្រះជាចាំបាច់ ហើយនេះជាឱកាសចុងក្រោយក្នុងការស្វែងរកយុត្តិធម៌ដល់សហគមន៍ទាំងមូល ។ ជាកិច្ចបញ្ចប់ លោក ដឺ ទេវិទ្ធិ បានជម្រាបដល់អ្នកភូមិថា ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងនៅជាមួយអ្នកភូមិដើម្បីជួយសម្រួលដល់អ្នកភូមិអំពីការដាក់ពាក្យបណ្ដឹងនេះ ។

ក្រោយមក លោក ឆាំង យុ ក៏បានបន្តការពិភាក្សាអំពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយលោកបានសួរអ្នកភូមិទាំងនោះអំពីនិយមន័យនៃពាក្យអំពើប្រល័យពូជសាសន៍ ។ ជនជាតិចាមដ៏ក្លាហានម្នាក់បាននិយាយថា អំពើប្រល័យពូជសាសន៍គឺជាការសម្លាប់ប្រជាជនមួយឲ្យផុតពូជ តែម្ដងដែលនេះជាចម្លើយមួយដ៏ខ្លីនិងស្ទើរតែត្រឹមត្រូវទាំងស្រុង ។ បន្ទាប់មក លោក ឆាំង យុ បានរៀបរាប់ពីនិយមន័យអនុសញ្ញាអំពើប្រល័យពូជសាសន៍នៃឧក្រិដ្ឋកម្មដល់អ្នកភូមិ ហើយលោកបានអះអាងថា ប្រវត្តិសាស្ត្ររបស់ជនជាតិចាមត្រូវតែរក្សាទុក បើមិនដូច្នោះទេការឈឺចាប់របស់ជនជាតិចាមនឹងត្រូវបានបំភ្លេចចោល ។ លោកក៏បានប្រាប់ទៅអ្នកភូមិថា ផលប៉ះពាល់នៃការឈឺចាប់នឹងមិនត្រូវបានដោះស្រាយទេ ដរាបណាយើងមិនហ៊ានប្រឈមមុខនឹងការឈឺចាប់នោះ ។

វាគ្មិនបន្ទាប់គឺហាកិម (មេដឹកនាំសាសនាក្នុងសហគមន៍ចាម) ដែលជាមនុស្សម្នាក់ជំរុញឲ្យមានការបះបោរ ក្នុងភូមិនៅឆ្នាំ១៩៧៥ ។ ខណៈពេលដែលហាកិមចាប់ផ្ដើមនិយាយជាភាសាចាម គាត់ទទួលបាននូវការគោរពយ៉ាងខ្លាំងពីអ្នកចូលរួម ។ អ្នកភូមិម្នាក់ៗចាប់ផ្ដើមរក្សាភាពស្ងប់ស្ងាត់ ហើយយកចិត្តទុកដាក់ជាខ្លាំងទៅលើពាក្យសម្ដីរបស់ហាកិម ។ គាត់បានប្រាប់អ្នកភូមិដែលបានចូលរួមយ៉ាងច្រើនកុះករអំពីការសម្លាប់និងការឈឺចាប់របស់ជនជាតិចាមនៅក្នុងភូមិនេះក្នុងអំឡុងរបបខ្មែរក្រហម ។ នៅក្នុងពាក្យសម្ដីរបស់គាត់ ការឈឺចាប់នោះមានសភាពធំធេងណាស់ «ដែលគ្មានពាក្យណាអាចឆ្លុះបញ្ចាំងបានពីការឈឺចាប់នោះបានឡើយ ដែលធ្វើឲ្យយុវជនខ្លះមិនជឿថា រឿងនោះធ្លាប់កើតមាន» ។ ហាកិមផ្ទាល់បានបាត់បង់សមាជិកគ្រួសារជាច្រើននាក់នៅក្នុងរបបនោះ ហើយគាត់ធ្លាប់បានធ្វើដំណើរទៅទីក្រុងភ្នំពេញដើម្បីចូលរួមតាមដានដំណើរការនីតិវិធីនៃអង្គជំនុំជម្រះបាន៧លើក ។ គាត់បានធ្វើសេចក្ដីសន្និដ្ឋានដោយស្នើឲ្យអ្នកភូមិពិចារណាទៅលើការបំពេញពាក្យបណ្ដឹងដើម្បីធានាថាការឈឺចាប់របស់ជនជាតិចាមនឹងមិនត្រូវបានបំភ្លេចទេដែលអាចបណ្ដាលឲ្យការឈឺចាប់នោះក្លាយជាគ្មានន័យ ។

ក្រោយពីស្ដាប់យ៉ាងយកចិត្តទុកដាក់រួចមក ដល់ពេលដែលអ្នកភូមិត្រូវទៅសំពះយ៉ាង (ថ្វាយបង្គំ) ហើយអ្នកភូមិទាំងអស់បានចាកចេញដើម្បីទៅថ្វាយបង្គំក្នុងវិហារ ។ ក្រុមការងារមជ្ឈ-មណ្ឌលឯកសារកម្ពុជាបានយកឱកាសនេះទៅរៀបចំទីកន្លែងដើម្បីបញ្ចាំងខ្សែភាពយន្តនៅទីវាលជិតវិហារអ៊ីស្លាមនោះ ។ ក្រោយពីកិច្ចការថ្វាយបង្គំចប់សព្វគ្រប់ អ្នកភូមិបានត្រឡប់មកកាន់ទីតាំងបញ្ចាំងកុនវិញ ។ ខ្សែភាពយន្តបានចាប់ផ្ដើមដោយការបញ្ចាំងពីសវនាការ ឌុច នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអំពីការផ្ដួលរំលំរបប លន់ នល់ ដោយខ្មែរក្រហម និងបទសម្ភាសន៍ជាមួយឆ្នាំគុកស-២១និងជនរងគ្រោះផងដែរ ។ ហើយទីបញ្ចប់នៃខ្សែភាពយន្តនោះបានបញ្ចាំងអំពីការសុំទោសរបស់ ឌុច ទៅកាន់ប្រជាជនទាំងអស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ អ្នកភូមិបានទស្សនាដោយយកចិត្តទុកដាក់ចំពោះខ្សែភាពយន្តនោះ ហើយអង្គុយទាំងអស់គ្នានៅលើដីទល់មុខវិហារអ៊ីស្លាម ។ ក្រោយខ្សែភាពយន្តចប់ លោក ឆាំង យុ បានសួរទៅកាន់អ្នកភូមិថាតើគាត់អាចលើកលែងទោសឲ្យ ឌុច បានដែរឬទេក្រោយពី ឌុច បានធ្វើការសុំទោសហើយ? បុរសម្នាក់បានងើបឈរហើយឆ្លើយថា «ទេ» ដោយបានពន្យល់ថាគាត់មិនអាចធ្វើការអត់ឱនទោសដល់ ឌុច បានទេព្រោះមនុស្សច្រើនណាស់បានទទួលរងនូវការឈឺចាប់និងស្លាប់ក្រោមស្នាដៃរបស់ ឌុច ។ ការបកស្រាយរបស់បុរសនោះបានបង្ហាញពីសេចក្ដីទុក្ខសោក ហើយបានឆ្លុះបញ្ចាំងអំពីសម័យកាលដ៏ខ្មៅងងឹតបំផុតរបស់អ្នកភូមិ ។ ពេលដែលនិយាយរឿងរ៉ាវពីអតីតកាល ភាពឈឺចាប់របស់ជនជាតិចាមត្រូវបានមើលឃើញ ខណៈពេលដែលប្រជាជនក្នុងសហគមន៍ទាំងមូលបានចុះថយមកត្រឹមតែ៦០០នាក់ប៉ុណ្ណោះក្នុងឆ្នាំ១៩៧៩ ។ ពេលនេះសហគមន៍ចាមបានក្លាយជាសហគមន៍មួយប្រកបទៅដោយភាពរីករាយម្ដងទៀតដែលពោរពេញទៅដោយក្មេងៗកំពុងរត់លេងសប្បាយនៅពេលនេះ ។ **វ៉ែនដល ឌឿហ្វាល់ក្ញ**

# ពិធីបើកវគ្គគ្រូបង្គោលថ្នាក់ខេត្ត ស្តីពីការបង្រៀន "ប្រវត្តិស
# អធិបតីដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួ







# ាស្ត្រកម្ពុជាប្រជាធិបតេយ្យ” នៅសាលាមធ្យមសិក្សាក្រោម ួងអប់រំ យុវជន និងកីឡា ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩










ឯកឧត្តម អ៊ឹម សិទ្ធី
រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

# កំហុសរបស់មេធាវីការពារក្តី

## ១) សេចក្តីផ្តើម

ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅមិនទាន់បានកាត់ទោសជនជាប់ចោទរូបណាក៏ដោយក៏ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះបានកំណត់នូវលក្ខណៈពីរដាច់ពីគ្នានៃការប្រព្រឹត្តខុសរបស់មេធាវី ។ ក្នុងករណីរបស់ អៀង សារី មេធាវីការពារក្តីបានបង្ហាញព័ត៌មានដែលមិនទាន់បានចុះផ្សាយពីមុនៗ នៅលើគេហទំព័រ ទោះបីជាខ្លួនទទួលលិខិតមួយពីសហចៅក្រមស៊ើបអង្កេតដែលបញ្ជាក់ថា ឯកសារទាំងអស់នោះត្រូវទុកជាការសម្ងាត់ ។ ការផ្សព្វផ្សាយព័ត៌មានដែលគ្មានការអនុញ្ញាតត្រូវចាត់ទុកថាប្រព្រឹត្តផ្ទុយនឹងវិធាន៣៨ ហើយមេធាវីទាំងនោះត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេតព្រមានថាបើនៅប្រព្រឹត្តផ្ទុយនឹងវិធានទៀតនោះនឹងត្រូវប្រឈមមុខតាមផ្លូវច្បាប់ ។ លើសពីនេះទៀត ការប្រព្រឹត្តខុសនេះគឺដោយយោងតាមគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីនៃសហរដ្ឋអាមេរិក គណៈមេធាវីនៃរដ្ឋអាឡាស្កា និង អង្គភាពគាំពារការការពារក្តី ។

ក្នុងករណី ខៀវ សំផន អង្គបុរេជំនុំជម្រះបានចេញសេចក្តីព្រមានមួយក្នុងចំណោមសេចក្តីព្រមាន២ទៅកាន់សហមេធាវីការពារក្តីអន្តរជាតិ ក្រោយពីមេធាវីរូបនេះបដិសេធមិនបន្តការពារក្តីឲ្យជនជាប់ចោទនៅក្នុងសវនាការដោយមិនបានជូនដំណឹងជាមុនដោយសារតែឯកសារទាំងអស់មិនមានជាភាសាបារាំង ។ ជាការឆ្លើយតបអង្គបុរេជំនុំជម្រះបានចេញសេចក្តីព្រមានមួយទៅមេធាវីនោះដោយយោងតាមវិធានផ្ទៃក្នុង ៣៨(១) «គឺមេធាវីនេះបានរំលោភលើដំណើរការនីតិវិធីនិងរបស់អង្គបុរេជំនុំជម្រះ និងសិទ្ធិរបស់ជនត្រូវចោទ» ។

មួយឆ្នាំក្រោយមក សវនាការអង្គបុរេត្រូវបានពន្យារពេលបន្ទាប់មកត្រូវគេលើកពេលដោយសារតែសហមេធាវីអន្តរជាតិបានអវត្តមានដោយមិនបានដឹងជាមុន ហើយសហមេធាវីជាតិបានអះអាងថា វាជាការចាំបាច់ត្រូវមានវត្តមានសហការីរបស់ខ្លួន ។ នៅពេលដែលសហមេធាវីអន្តរជាតិឡើងការពារក្តី នៅថ្ងៃសវនាការដែលបានរៀបចំសាជាថ្មីគាត់បាននិយាយបញ្ចិតបញ្ចៀងថាចៅក្រមមានជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ហើយបានហៅចៅក្រមថាជា «អ្នករស់នៅមិនស្របច្បាប់» និងជាមនុស្សឈ្លក់វង្វេងនឹងទឹកប្រាក់តែម្យ៉ាងប៉ុណ្ណោះ ។ គួរឲ្យកត់សម្គាល់ថាទោះបីជាសវនាការត្រូវបានលើកពេលដើម្បីទុកឱកាសឲ្យសហមេធាវីអន្តរជាតិមានវត្តមានការពារក្តីក៏ដោយក៏សហមេធាវីរូបនេះបែរជាមិននិយាយអ្វីដែលពាក់ព័ន្ធនឹងច្បាប់ហើយបែរជាទុកឲ្យសហមេធាវីជាតិជាអ្នកធ្វើការតែម្នាក់ឯងទៅវិញ ។

ជាការឆ្លើយតបអង្គជំនុំជម្រះបានចេញសេចក្តីព្រមានលើកទី២ដោយអះអាងថាអវត្តមានដោយគ្មានការពន្យល់ ការប្រើភាសាវាយប្រហារនិងការបដិសេធមិនចូលរួមឲ្យបានពេញលេញក្នុងអង្គសវនាការអាចត្រូវបានលើកលែងដោយអង្គបុរេជំនុំជម្រះដែលមានភារកិច្ចធានាឲ្យមានភាពសមរម្យនិងសេចក្តីថ្លៃថ្នូរនៅក្នុងដំណើរការនីតិវិធីរបស់អង្គសវនាការ ។ អាកប្បកិរិយារបស់មេធាវីបានធ្វើឲ្យដំណើរការមានភាពយឺតយ៉ាវ និងធ្វើឲ្យខ្ជះខ្ជាយធនធានទាំងឡាយរបស់តុលាការ ។ អង្គជំនុំជម្រះបានព្រមានមេធាវីអន្តរជាតិនោះថាអាកប្បកិរិយាបែបនេះជាការធ្វើឲ្យរាំងស្ទះនិងជាការរំលោភលើមាត្រា៣៨នៃច្បាប់វិធានផ្ទៃក្នុង ។ ម្យ៉ាងទៀតអង្គជំនុំជម្រះបានដាក់សេចក្តីព្រមានមួយច្បាប់ទៀតទៅគណៈមេធាវីក្រុងប៉ារីសនិងអង្គភាពគាំពារការការពារក្តី ។

## ២) សិទ្ធិដើម្បីជ្រើសរើសមេធាវីការពារក្តីរបស់ចុងចោទគឺជាការធានាកម្រិតអប្បបរមា ប៉ុន្តែអាកប្បកិរិយាមួយចំនួនអាចធ្វើឲ្យមានការដាក់កំហិតទៅលើសិទ្ធិនោះ

មាត្រា១៣នៃកិច្ចព្រមព្រៀងរវាងកម្ពុជានិងអង្គការសហប្រជាជាតិ(កិច្ចព្រមព្រៀងឆ្នាំ២០០៣) ធានានូវសិទ្ធិមួយចំនួនដែលមានកម្រិតអប្បបរមាដល់ចុងចោទនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សិទ្ធិទាំងឡាយដែលបានចែងឆ្លុះបញ្ចាំងឲ្យកាន់តែច្បាស់នូវសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ដែលមាននៅមាត្រា១៤និង១៥នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ស្តីពីសិទ្ធិ

ជាជនស៊ីវិលនិងនយោបាយ និងកិច្ចព្រមព្រៀងចម្បងៗដទៃទៀត ។ សិទ្ធិទាំងនេះរួមមានសិទ្ធិធ្វើការជ្រើសរើសមេធាវីការពារខ្លួន ។ សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌នេះបម្រើគោលដៅដើម្បីធានាថាជនជាប់ចោទដែលអាចជ្រើសរើស មេធាវីការពារខ្លួនដោយសេរីមានលទ្ធភាពស្វែងរកវិធីសាស្ត្រការពារក្តីដែលជ្រើសរើសដោយខ្លួនឯងផ្ទាល់ ដោយផ្អែកទៅលើអ្វីដែលជនជាប់ចោទជឿជាថាគឺជាវិធីសាស្ត្រល្អបំផុតក្នុងការការពារខ្លួននោះគេអាចជ្រើសរើសមេធាវីដែលមានជំនាញច្បាស់លាស់ខាងច្បាប់អន្តរជាតិ ឬជាអ្នកជំនាញការខាងបញ្ហានីតិវិធី ឬត្រឹមតែជាមេធាវីដែលមានកេរ្តិ៍ឈ្មោះល្បីខាងវែកញែកតតាំងពីច្បាប់នៅតុលាការ ។

ផ្ទុយទៅវិញតាមវិធានផ្ទៃក្នុង៣៨ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានសិទ្ធិកំណត់ថាតើមេធាវីណាដែលជនជាប់ចោទជ្រើសរើស និងរបៀបណាដែលមេធាវីរូបនោះសម្តែងចេញមក ។ វិធាន៣៨ចែងថា

១) សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចដាក់ទណ្ឌកម្មឬបដិសេធក្នុងការចូលរួមសវនាការចំពោះមេធាវីណាមួយប្រសិនបើយល់ឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនោះជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធីរំលោភទៅលើរឿងក្តីឬផ្ទុយទៅនឹងមាត្រា ២១(៣) នៃកិច្ចព្រមព្រៀង ។

២) សហចៅក្រមស៊ើបអង្កេតឬ អង្គជំនុំជម្រះអាចបញ្ជូនករណីកំហុសវិជ្ជាជីវៈនេះទៅអង្គភាពមានសមត្ថកិច្ច ។

អាស្រ័យហេតុនេះ សិទ្ធិរបស់ជនជាប់ចោទក្នុងការជ្រើសរើសមេធាវី និងវិធីសាស្ត្រការពារក្តីមិនមែនគ្មានការកំណត់នោះទេ ។ ប្រសិនបើទង្វើរបស់មេធាវីដែលគេបានជ្រើសរើសនោះត្រូវគេរកឃើញថាមានកំហុសវិជ្ជាជីវៈអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចសម្រេចចិត្តរឹតបន្តឹងការប្រព្រឹត្តរបស់មេធាវីនោះ ឬបដិសេធមិនឲ្យចូលរួមសវនាការទាំងឡាយដោយតម្រូវឲ្យជនជាប់ចោទជ្រើសរើសមេធាវីផ្សេងទៀត ។

ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏ត្រូវប្រុងប្រយ័ត្នមិនត្រូវធ្វើហួសហេតុនិងដាក់កំហិតនានាដែលមិនចាំបាច់ទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការជ្រើសរើសមេធាវីក៏ដូចជាវិធីសាស្ត្រការពារក្តីឡើយ ។ ទោះបីជាការកាត់ក្តីដោយយុត្តិធម៌នេះអាចត្រូវបានដាក់កំហិតនៅក្រោមកាលៈទេសមួយចំនួនក៏ដោយក៏តុលាការអន្តរជាតិបានដំណើរការនីតិវិធីដោយប្រយ័ត្នប្រយែងនិងដូចដែលបានបង្ហាញនៅខាងក្រោមគឺតែងតែទុកឲ្យជនជាប់ចោទនូវឱកាសមួយចំនួនមុនពេលធ្វើការរឹតបន្តឹងសិទ្ធិទៅតាមកម្រិតណាមួយនោះ ។ ការឃ្លាំមើលការអនុវត្តសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌រួមទាំងសិទ្ធិជ្រើសរើសមេធាវីគឺជាកត្តាសំខាន់តាមផ្លូវច្បាប់មួយរបស់តុលាការអន្តរជាតិ ហើយសកម្មភាពឆ្ពោះទៅមុខរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការដាក់កំហិតទៅលើសិទ្ធិទាំងអស់នេះ នឹងធ្វើឲ្យមានការសង្ស័យពីភាពមិនលម្អៀងរបស់ចៅក្រមនិងពីសមត្ថភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការវិនិច្ឆ័យប្រកបដោយភាពយុត្តិធម៌ ។ ហេតុដូចនេះហើយ សេចក្តីរំឭកនេះនឹងធ្វើការពិនិត្យមើលជុំវិញអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងនីតិក្រមអន្តរជាតិក្នុងគោលបំណងផ្តល់ការណែនាំដល់អង្គជំនុំជម្រះនៅពេលដែលមេធាវីប្រព្រឹត្តមិនគប្បី តើកត្តាអ្វីខ្លះដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគួរពិចារណានៅពេលសម្រេចចិត្តដាក់ទណ្ឌកម្មលើមេធាវី និងដំណោះស្រាយបែបណាដែលសមស្រប ។

ជាពិសេសនោះ សេចក្តីរំឭកនេះនឹងពិនិត្យមើលឧទាហរណ៍ទាំងឡាយនៅពេលដែលតុលាការអន្តរជាតិបានធ្វើការដាក់កំហិតទៅលើសិទ្ធិទទួលការតំណាងខាងផ្លូវច្បាប់របស់ជនជាប់ចោទ ។ នេះតែងតែកើតមានឡើងនៅពេលដែលជនជាប់ចោទបានជ្រើសរើសមេធាវីការពារដើម្បីតំណាងឲ្យខ្លួន ។ ពេលណាដែលជនជាប់ចោទអនុវត្តសិទ្ធិតំណាងខ្លួនឯងគេក៏កំពុងតែអនុវត្តសិទ្ធិទទួលមេធាវីការពារខ្លួនដែរ ។ ដូច្នេះហើយ ការពិនិត្យមើលនៅពេលដែលតុលាការយល់ថាជាការសមគួរក្នុងការដាក់កំហិតលើសិទ្ធិតំណាងខ្លួនឯងនោះនឹងផ្តល់សេចក្តីណែនាំបន្ថែមក្នុងការដាក់កំហិតដ៏សមរម្យដែលអាចនឹងដាក់លើមេធាវីការពារក្តី ។ ដោយពិចារណាទៅលើយុត្តិសាស្ត្រមុនពេលដាក់ពិន័យមេធាវីរបស់ជនជាប់ចោទអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចជួយធានាឲ្យប្រាកដថាសេចក្តីសម្រេចណាមួយនៅពេលខាងមុខនឹងត្រូវគេមើលឃើញថាមិនលម្អៀងគ្រប់ជ្រុងជ្រោយនិងមានលក្ខណៈស្របច្បាប់ ។

## ៣) នៅពេលណាទើបមេធាវីមានកំហុសវិជ្ជាជីវៈ?

នៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិធាន៣៨(១) ចែងច្បាស់អំពីប្រភេទកំហុសទាំងឡាយដែលត្រូវចាត់ទុកជាកំហុសវិជ្ជាជីវៈ ហើយត្រូវទទួលខុសត្រូវតាមវិធានរបស់តុលាការដែលរួមមានអំពើដូចជា ការរំលោភបំពានការរាំងស្ទះដល់ដំណើរការនីតិវិធី រំលោភទៅលើដំណើរការ ឬការប្រព្រឹត្តមិនស្របទៅតាមបទដ្ឋានរបស់តុលាការ ឬតាមវិជ្ជាជីវៈច្បាប់ ។ ទោះបីប្រភេទទាំងនេះមិនត្រូវបានកំណត់ដោយច្បាប់នៅក្នុងវិធានផ្ទៃក្នុងក៏ដោយក៏អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការអន្តរជាតិបានរកឃើញថាមានអាកប្បកិរិយាខ្លះមានលក្ខណៈដូចប្រភេទខាងលើឬស្រដៀងគ្នាពេលដែលមេធាវី ក) មិនមានវត្តមានក្នុងសាលសវនាការ ខ) ប្រើសម្តីមិនសមរម្យដាក់តុលាការ គ) ជារូបភាពបង្អាក់កិច្ចដំណើរការនីតិវិធី ឃ) វាយប្រហារខ្លាំងៗដល់ដំណើរការនិងនីតិវិធីរបស់សាលសវនាការនិងឬមួយក៏រំលោភលក្ខន្តិកៈ ឬវិធានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ទោះបីជាប្រភេទទាំងអស់នេះវាមានលក្ខណៈប្រហាក់ប្រហែលគ្នានៅក្នុងការអនុវត្តក៏ដោយ ប៉ុន្តែដោយធ្វើការបំបែកទង្វើនីមួយៗទៅជាការប្រព្រឹត្តផ្សេងៗ សេចក្តីវិភាគនេះនឹងអាចត្រូវបានយកមកកំណត់នៅពេលមានវិធានការរបស់តុលាការ ។

### ក) អវត្តមានពីតុលាការ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានយល់ឃើញថាអវត្តមាននៅក្នុងសវនាការគឺជាកំហុសវិជ្ជាជីវៈ យោងតាមវិធាន៣៨ ។ ក្នុងករណី ខៀវ សំផន សហមេធាវីអន្តរជាតិរបស់ជនជាប់ចោទអវត្តមានដោយមិនបានដឹងជាមុននៅក្នុងសវនាការមួយចំនួនដោយសារជាប់មានភារៈមើលអ្នកជំងឺនៅប្រទេសបារាំង ។ សហមេធាវីជាតិបានស្នើសុំពន្យារពេលការពារក្តីដោយបានលើកឡើងថាវត្តមានរបស់សហមេធាវីអន្តរជាតិ ជាករណីចាំបាច់សម្រាប់សវនាការនៅថ្ងៃនោះ ។ អវត្តមានរួមទាំងអាកប្បកិរិយាមិនគួរគប្បីដែលសម្តែងឡើងដោយសហមេធាវីអន្តរជាតិនៅឯសវនាការដែលបានគ្រោងទុកនាំឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញសេចក្តីព្រមានថា អាកប្បកិរិយានោះជាការរំលោភហើយមានកំហុសតាមវិធាន៣៨ ។

តុលាការអន្តរជាតិពិចារណាឃើញថាអវត្តមាន គឺជាការមានចេតនាដើម្បីកក្កូរកកាយទង្វើរបស់តុលាការ ។ នៅក្នុងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនករណី ណរមែន ជនជាប់ចោទដែលត្រូវតំណាងឲ្យខ្លួនឯងបានអវត្តមានក្នុងសវនាការហើយបានបន្តអះអាងប្រាប់ពីចេតនាមិនបង្ហាញខ្លួនរហូតដល់បញ្ហាមួយចំនួនត្រូវបានដោះស្រាយជាមុនសិន ។ តុលាការក៏បានអះអាងថាអាកប្បកិរិយាបែបនេះជាការរំខានហើយអនុវត្តក្នុងអំឡុងពេល១០ថ្ងៃ បន្ទាប់ពីអវត្តមានដំបូងដោយសម្រេចដកសិទ្ធិរបស់ចុងចោទក្នុងការតំណាងឲ្យខ្លួនឯង ។ ដូចគ្នានេះដែរតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ករណីបារ៉ាយ៉ាកវីហ្សាជនជាប់ចោទបានធ្វើពហិការមិនចូលរួមក្នុងសវនាការហើយបានទាំងព្យាយាមរារាំងមេធាវីរបស់គាត់មិនឲ្យការពារក្តីនេះនៅក្នុងតុលាការថែមទៀត ។ ក្នុងពេលមិនចូលរួម២-៣ថ្ងៃដំបូងតុលាការបានប្រកាសអវត្តមានរបស់ជនជាប់ចោទហើយប្រកាសបដិសេធមិនឲ្យមេធាវីឡើងតំណាងឲ្យជនជាប់ចោទដែលជាការរារាំងដល់ដំណើរការយុត្តិធម៌ ។ តុលាការមើលឃើញថាអវត្តមានរបស់ជនជាប់ចោទគឺជាចេតនាហើយបានសម្រេចបដិសេធមិនឲ្យមេធាវីដកខ្លួនដោយដាក់កំហិតទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការប្រឹក្សារកវិធីសាស្ត្រការពារជាមួយមេធាវីរបស់ខ្លួន ។

ប្រសិនបើអវត្តមានមិនមែន ជាចេតនាហើយកើតឡើងដដែលៗយុត្តិសាស្ត្រអន្តរជាតិនឹងយល់ស្របគាំទ្រ ទស្សនៈដែលថាឥរិយាបថបែបនេះអាចសមល្មមដល់ការដាក់ចេញវិធានការរបស់តុលាការ ។ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងករណីមីឡូសេវិកបញ្ហាសុខភាពរបស់ជនជាប់ចោទបានធ្វើឲ្យគាត់អវត្តមានជារឿយៗក្នុងសវនាការ ។ ដោយសារតែគាត់បានជ្រើសរើសប្រើប្រាស់សិទ្ធិរបស់គាត់ក្នុងការតំណាងឲ្យខ្លួនឯង បញ្ហាសុខភាពទាំងឡាយណាដែលធ្វើឲ្យគាត់អវត្តមានក្នុងសវនាការ ក៏បានរារាំងដំណើរការរបស់តុលាការដែរ ។ ជាទូទៅបញ្ហាសុខភាពរបស់ជនជាប់ចោទបានបង្ខំឲ្យតុលាការពន្យារពេលសវនាការជាច្រើនលើកច្រើនសាដែលមានចំនួនដល់ទៅ៦៦ថ្ងៃ ។ វេជ្ជបណ្ឌិតជាច្រើនបានរំពឹងទុកថា ប្រសិនបើជនជនជាប់ចោទបន្តការពារក្តីដោយខ្លួនឯងទៀត នឹងនាំឲ្យមានការពន្យារពេលថែមទៀត ។ សាលាឧទ្ធរណ៍បានអះអាងថាការរំខានដោយចេតនាមិន

មែនតែជា «ការរំខានតែមួយប្រភេទដែលទទួលស្គាល់តាមផ្លូវច្បាប់ដោយតុលាការទេ» ។ ចំពោះជនជាប់ចោទដែលមានសុខភាពមិនសូវល្អហើយប្រកាន់សិទ្ធិតំណាងខ្លួនឯងអាចរំខានដល់ដំណើរការរបស់តុលាការ ទោះជាដោយមានឬគ្មានចេតនាក៏ដោយ ។ តុលាការមិនអាចជ្រើសរើសរវាង «ការដោះលែងជនជាប់ចោទ ឬទុកឲ្យសំណុំរឿងនៅគាំងមិនដំណើរការទៅមុខបានទេ» ។ តុលាការដែលកាត់សេចក្ដីករណីហេរូលហ្ស៊ី បានយល់ស្របនឹងតុលាការដែលកាត់សេចក្ដី មីឡូសេវិក ដែរ ដោយអះអាងថា «វាមិនមែនជាការកំណត់ដាច់ខាតដែលថាការរំខាននោះធ្វើឡើងដោយចេតនា ឬដោយអចេតនានោះទេនៅក្នុងករណីទាំងពីរនេះ ការរំខានដែលបានបន្តឡើងអាចធ្វើជាមូលដ្ឋានមួយសម្រាប់ដកសិទ្ធិតំណាងឲ្យខ្លួនឯងបាន» ។

ករណីដែលលំបាកបំផុតនោះគឺពេលដែលចេតនាមិនច្បាស់លាស់ ។ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិដែលកាត់សេចក្ដីករណី មូសេម៉ា មេធាវីការពារក្ដីបានអវត្តមាន ប៉ុន្តែវាមិនច្បាស់ថា តើអវត្តមាននោះមានចេតនាពន្យារដំណើរការនីតិវិធីឬមួយធ្វើដោយមានហេតុផលស្របច្បាប់ ។ មេធាវីបានបដិសេធមិនបង្ហាញខ្លួននៅមុខតុលាការ រហូតទាល់តែជនជាប់ចោទទូទាត់ប្រាក់ឲ្យគាត់សម្រាប់ការងារក្នុងសវនាការលើកមុន ។ តុលាការមិនបានចាត់វិធានការតបភ្លាមៗ ប៉ុន្តែបានព្យាយាមសម្រួលស្ថានការណ៍ទូទាត់ប្រាក់វិញ ។ ទោះបីក្រោយពីការទូទាត់ត្រូវបានសម្រេចរួចហើយក៏ដោយ ក៏មេធាវីរូបនោះនៅតែមិនបង្ហាញមុខក្នុងសវនាការដដែល ដោយបាននិយាយថាគាត់ជាប់រវល់ហើយមិនអាចមកបានក្នុងអំឡុង២ទៅ៣ខែទៀត ។ ជាចុងក្រោយតុលាការបានពិចារណាឥរិយាបថនេះថាកំពុងរារាំងដល់ដំណើរការនីតិវិធីហើយផ្ទុយពីបុព្វហេតុយុត្តិធម៌ដែលបានចេញដីកាតុលាការ ។ ទោះបីឥរិយាបថនេះមិនមានចេតនាច្បាស់លាស់ដើម្បីរំខានដល់ដំណើរនីតិវិធីក៏ដោយតែក្រោយឆ្លងកាត់រយៈកាលមួយឥរិយាបថដដែលៗនេះទោះបីមានឬមិនមានចេតនាវាជាការគ្រប់គ្រាន់ណាស់សម្រាប់ឲ្យតុលាការចាត់វិធានការហើយ ។

គួរកត់សម្គាល់ដែរថាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានចៀសវាងនូវការគិតទុកមុនអំពីលទ្ធភាពអវត្តមានដែលនឹងបង្កជាឧបសគ្គដល់ដំណើរការនីតិវិធី ។ នៅដំណាក់កាលដំបូងនៃករណី មីឡូសេវិក សាលាក្ដីបានស្នើតែងតាំងមេធាវីឲ្យជនជាប់ចោទ ព្រោះតុលាការបានប្រមើលមើលថាការចង់ឡើងការពារក្ដីដោយខ្លួនឯងរបស់ជនជាប់ចោទនឹង «បង្កើនបន្ទុកលំបាកទៅលើសុខភាពរបស់ជនជាប់ចោទនោះ» និងអាចបង្កការយឺតយ៉ាវនៅពេលខាងមុខ ។ ទោះបីជាការរំពឹងទុកនោះជាការត្រឹមត្រូវក៏ដោយ ក៏សាលាដំបូងមិនបានរឹបអូសយកសិទ្ធិឡើងការពារខ្លួនពីជនជាប់ចោទដែរ ។ ហើយទោះបីជាអង្គជំនុំជម្រះជឿជាក់ «ជនជាប់ចោទនឹងទទួលបានផលប្រយោជន៍ច្រើនបំផុតក្នុងការទទួលយកជំនួយពីមេធាវី» ក៏ដោយក៏នៅពេលនោះមិនមានឱកាសណាដើម្បីកែតម្រូវការដាក់កំហិតលើសិទ្ធិរបស់ចុងចោទដែរ ។

ដោយធ្វើការប្រៀបធៀបតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានចាប់ផ្ដើមជំហានដែលអាចសម្រួលដល់ការពន្យារពេលដែលបានរំពឹងទុកមុនដោយមិនធ្វើការដាក់កំហិតទៅលើសិទ្ធិរបស់ចុងចោទឡើយ ។ ក្នុងករណី ណរមែន នៅពេលពាក់កណ្ដាលសវនាការចុងចោទសម្រេចដកមេធាវីរបស់ខ្លួនចេញហើយដឹកនាំការពារក្ដីដោយខ្លួនឯង ។ តុលាការយល់ថាការមិនយល់ដឹងពីបញ្ហាច្បាប់របស់ចុងចោទអាចបណ្ដាលឲ្យមានការពន្យារពេលយូរនិងអាចរំលោភទៅលើសិទ្ធិទទួលបានការកាត់ក្ដីរបស់ចុងចោទផ្សេងៗ ។ តុលាការមិនបានបំបិទសិទ្ធិរបស់ចុងចោទមិនឲ្យប្រើប្រាស់សិទ្ធិរបស់ខ្លួនឯងទាំងស្រុងនោះទេ ប៉ុន្តែតុលាការយល់ឃើញថាចុងចោទមានសិទ្ធិតំណាងឲ្យខ្លួនឯង ប៉ុន្តែដោយមានជំនួយពីមេធាវីដោយមានកំណត់ និងនៅពេលដែលវាមិនរំខានដល់ «ផលប្រយោជន៍នៃយុត្តិធម៌» ។ សេចក្ដីសម្រេចនឹងស្នើថាតុលាការមានសុឆន្ទៈសម្រួលនិងរៀបចំឥរិយាបថដែលអាចប៉ះពាល់ដល់សកម្មភាព ប៉ុន្តែរហូតដល់ឥរិយាបថនោះកើតមានពិតប្រាកដចុងចោទត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់សិទ្ធិរបស់ខ្លួនដោយមានលក្ខខណ្ឌ ។

យុត្តិសាស្ត្រអន្តរជាតិបានបង្ហាញថាធ្លាប់មានអវត្តមានស្រដៀងគ្នានេះដែលកើតឡើងជាច្រើនលើកច្រើនសាដែលអាចយកមកអះអាងនៅតុលាការបាន ។ តុលាការហាក់បីដូចជាមានកំហុសក្នុងការផ្ដល់ពេលវេលាឲ្យកែតម្រូវឥរិយាបថ ប្រសិនបើឥរិយាបថនោះមិនមានចេតនាក្នុងការរំខានដល់តុលាការ ។ នៅ

ក្នុងករណី មីឡូសេវិក តុលាការបានបង្ហាញពីកម្រិតនៃការយល់ស្របមួយចំនួនដោយសារនោះជាអវត្តមានដែលបណ្ដាលមកពីបញ្ហាសុខភាពដែលមិនអាចចៀសរួច ។ នៅក្នុងករណី ណរមែន និង ប៉ារ៉ាយ៉ាករីហ្សាចុងចោទបានបង្ហាញយ៉ាងច្បាស់អំពីអវត្តមានដោយចេតនាដោយសារតែការមិនយល់ស្របនឹងដំណើរការរបស់តុលាការ ។ ករណីដែលលំបាកគឺករណីដូចជា នៅម្ហូរីម៉ាដែលមេធាវីហាក់ដូចជាមានការដោះសារតាមផ្លូវច្បាប់នៅពេលដំបូងហើយបន្ទាប់មកបន្តបង្កើតការដោះសាទៀត ។ ជាទូទៅតុលាការមិនអនុញ្ញាតឲ្យឥរិយាបថបែបនេះបន្តមានរហូតទេ ប៉ុន្តែឥរិយាបថបែបនេះនៅពេលដំបូងពិតជាបានផ្ដល់ផលប្រយោជន៍ដល់បញ្ហា ។ នៅទីបញ្ចប់វាហាក់បីដូចជាថាតុលាការបានចៀសវាងមិនរំពឹងទុកអំពីអវត្តមានទោះបីជាអវត្តមាននោះអាចកើតមានពិតក៏ដោយ ។ រហូតដល់ឥរិយាបថនោះកើតឡើងពិតហើយសវនាការត្រូវបានរំខានដោយការអវត្តមានតុលាការមិនគួរប្រើប្រាស់ការអវត្តមានដែលបានរំពឹងទុកមកធ្វើជាការអះអាងដើម្បីដាក់កំហិតលើសិទ្ធិទទួលបានការកាត់ក្ដីដ៏យុត្តិធម៌ទេ ។

## ១) ការរំលោភបំពានទៅលើតុលាការដោយពាក្យសម្ដី

ការប្រព្រឹត្តដែលរួមបញ្ចូលការរំលោភបំពានទៅលើតុលាការដោយសារពាក្យសម្ដីក៏អាចត្រូវបានរកឃើញដើម្បីយកមកអះអាងអំពីសកម្មភាពរបស់តុលាការដែរ ។ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ករណី ខៀវសំផន សហមេធាវីការពារក្ដីអន្តរជាតិបានចោទប្រកាន់ចៅក្រមអំពីអំពើពុករលួយហើយបានហៅចៅក្រមទាំងនោះថាជា «មនុស្សរស់នៅមិនស្របច្បាប់» ពីព្រោះ នាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បានមានប្រសាសន៍ជាសាធារណៈថា «លោកចង់ឲ្យចៅក្រមទាំងនោះចាកចេញ» ។ អង្គបុរេជំនុំជម្រះយល់ឃើញថាកំណត់សម្គាល់របស់មេធាវីដែលនិយាយដាក់ចៅក្រមគឺជា «ការរំលោភបំពាននិងការរាំងស្ទះ»ដល់តុលាការដោយអនុលោមទៅតាមវិធាន៣៨នៃកំហុស ។ តុលា



អ្នកភូមិ សិស្សានុសិស្ស និង ដូនជី កំពុងតម្រង់ជួរចូលមើលសវនាការកាត់ទោសឌុច

ការអន្តរជាតិបានចាត់ទុកសម្តីមិនសមរម្យដោយចេតនានៅក្នុងតុលាការថាជាការរំលោភច្បាប់ ហើយត្រូវប្រឈមមុខនឹងសកម្មភាពតុលាការ ។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីករណីហ្សង់កូវីកចុងចោទបានប្រើភាសារំលោភបំពាននិងមិនសមរម្យជាច្រើនលើកច្រើនសានិងបន្តៗគ្នា ។ នៅរាល់សវនាការនិងសារណាលាយលក្ខណ៍អក្សរចុងចោទប្រើប្រាស់សិទ្ធិតំណាងឲ្យខ្លួនឯងដើម្បីនិយាយ ហើយបានរំលោភទៅលើតុលាការនិងអ្នកដែលជាប់ពាក់ព័ន្ធនឹងដំណើរការនីតិវិធី ។ ការប្រើប្រាស់ពាក្យសម្តីមិនសមរម្យរបស់ចុងចោទនោះរួមមានការហៅមេធាវីរបស់ខ្លួនថាជា«មនុស្សមិនល្អគ្មានសីលធម៌ដែលធ្វើការឲ្យតុលាការហាគីដែលចម្លែក» ហើយបានហៅមេធាវីនិងប្រធានព្រះរាជអាជ្ញានៃតុលាការថាជា «ឈ្លបផ្តាច់ការនិងជាមនុស្សមិនល្អ» ។ តុលាការយល់ឃើញថាឥរិយាបថរបស់ចុងចោទនេះជា«ការមិនគោរពនិងមិនសមរម្យដែលធ្វើឡើងដោយចេតនា» ។ តុលាការបានសម្រេចថាឥរិយាបថបែបនេះគឺជាការរំខាន ហើយសន្និដ្ឋានថាវានឹងប៉ះពាល់ដល់ការការពារដ៏យុត្តិធម៌និងប្រសិទ្ធភាពរបស់ជនត្រូវចោទប្រសិនបើជនត្រូវចោទការពារក្តីដោយខ្លួនឯង» ។ អាស្រ័យហេតុនេះសកម្មភាពរបស់ចុងចោទបែបនេះត្រូវប្រឈមមុខនឹងសកម្មភាពតុលាការដែលគឺជាការដាក់កំហិតទៅលើសិទ្ធិរបស់ចុងចោទក្នុងការតំណាងឲ្យខ្លួនឯង ។



ជាទូទៅតុលាការតែងតែព្យាយាមបែងចែករវាងភាសារិះគន់ដល់តុលាការនិងភាសារំលោភបំពានតុលាការ ។ នៅតុលាការសិទ្ធិមនុស្សនៅអឺរ៉ុបករណីសាដេប្តីងប្រទេសទួគី ចុងចោទបានវាយប្រហារដោយពាក្យសម្តីទៅលើតុលាការទួគី ។ ចុងចោទបានរិះគន់ចៅក្រមថាជា «ពេជ្ឈឃាតដែលស្លៀកសម្លៀកបំពាក់ជាចៅក្រម» ហើយប្រើភាសារំលោភទៅលើមន្ត្រីតុលាការ ។ នៅក្នុងសេចក្តីសម្រេចរបស់តុលាការទួគី តុលាការសិទ្ធិមនុស្សនៅអឺរ៉ុបបានអះអាងថាខណៈពេលដែល «ធាតុនិងមុខងាររបស់តុលាការអាចត្រូវបានរិះគន់ហើយការវាយប្រហារដោយពាក្យសម្តីទៅលើចៅក្រមដែលអាចបង្កើតឲ្យមានបរិយាកាសរំខានដល់ការគ្រប់គ្រងយុត្តិធម៌អាចត្រូវទទួលទណ្ឌកម្ម ។ តុលាការសិទ្ធិមនុស្សនៅអឺរ៉ុបសន្និដ្ឋានថាកំណត់សម្គាល់របស់ចុងចោទដែលធ្វើឡើងដោយពាក្យសម្តីគឺជាការ«រិះគន់» ហើយដោយសារតែកំណត់សម្គាល់នោះគឺជាការរំលោភបំពានហើយត្រូវប្រឈមមុខនឹងសកម្មភាពតុលាការ ។ ស្រដៀងគ្នានេះដែរនៅបារ៉ាយ៉ាកវីហ្សា នៅក្នុងតុលាការចុងចោទសុំឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉វ៉ាន់ដាឲ្យ «ផ្តល់ឯករាជ្យនិងយុត្តិធម៌មិនលម្អៀងដោយសារតែតុលាការនោះពឹងផ្អែកទៅលើរបបប្រឆាំងនឹងជនជាតិហ៊ូទូរបស់គីហ្គាលី» ដូច្នេះទើបមិនអាចគោរពទៅតាមសិទ្ធិមនុស្សមូលដ្ឋាន ។ តុលាការសម្រេចចិត្តមិនអើពើនឹងសំណូមពរនេះហើយមិនប្រព្រឹត្តអ្វីរហូតដល់ចុងចោទឈប់ចូលរួមក្នុងសវនាការ ។

នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ករណីខៀវ សំផន សហមេធាវីការពារក្តីអន្តរជាតិអាចនឹងទទួលពិន័យនៅអំឡុងនិយាយការពារក្តីនៅតុលាការ ។ ដោយនិយាយបញ្ចិតបញ្ចៀងមេធាវីការពារក្តីបានចោទជាសំណួរទៅលើភាពស្របច្បាប់របស់តុលាការដោយនិយាយប្រមាថពីឥរិយាបថរបស់ចៅក្រម ។ អង្គបុរេជំនុំជម្រះយល់ឃើញថាកំណត់សម្គាល់របស់មេធាវីនេះគឺជាការប្រមាថមើលងាយនិងរំលោភបំពានចៅក្រម» ដូច្នេះគឺជាការប្រព្រឹត្តមិនត្រឹមត្រូវ ។ ទោះបីជាមេធាវីអាចអះអាងថាអ្វីដែលខ្លួនបាននិយាយគឺមិនមានចេតនាប្រមាថមើលងាយដោយចៅក្រមក៏ដោយ ប៉ុន្តែវាគឺជាការវាយប្រហារទៅលើភាពស្របច្បាប់របស់តុលាការដែរ ។ ដូច្នេះ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនឹងយោងទៅតាមយុត្តិសាស្ត្រអន្តរជាតិ ។

### ក) ឥរិយាបថដែលរំខានដល់ដំណើរការនីតិវិធី

សកម្មភាពខ្វះរបស់ចៅក្រមនៅក្នុងសវនាការអាចត្រូវបានចាត់ទុកថាជាការប្រមាថមើលងាយនិងរាំងស្ទះដល់យុត្តិធម៌ដែលអាចបណ្តាលឲ្យមានការដាក់កំហិតទៅលើសិទ្ធិរបស់ចុងចោទ ។ នៅ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ករណីដូមូកូវស្គីចុងចោទបានបដិសេធនឹងតុលាការចចជៀប្រឆាំងនឹងអ្នក

យាមរត់ចេញពីបន្ទប់សវនាការហើយហួចនិងឲ្យមាន (ចុងចោទម្នាក់) លោតរំលងរបាំងទៅបន្ទប់សវនាការហើយលួចអាវុធរបស់អ្នកយាម ។ តុលាការចចដៀ យល់ឃើញថាចុងចោទ «តែងតែរំខានដល់ដំណើរការនីតិវិធីនៅអំឡុងពេលសវនាការដោយមិនគោរពតុលាការមិនអើពើនឹងសេចក្តីណែនាំរបស់ប្រធានតុលាការនិងរារាំងមិនឲ្យតុលាការដំណើរការតាមប្រក្រតី» ។ តុលាការចចដៀ បានប្រើការប្រព្រឹត្តជាហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនដើម្បីដាក់កំហិតទៅលើសិទ្ធិរបស់ចុងចោទនិងសិទ្ធិក្នុងការជ្រើសរើសមេធាវី ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានផ្លាស់ប្តូរសេចក្តីសម្រេចរបស់តុលាការចចដៀ ដោយសម្រេចថា ចុងចោទគួរតែត្រូវបានអនុញ្ញាតឲ្យដឹកនាំការពារក្តីដោយខ្លួនឯងនិងត្រូវបានតំណាងដោយមេធាវីដែលខ្លួនជ្រើសរើស ។ ករណីនេះមានលក្ខណៈពិសេស ពីព្រោះចុងចោទត្រូវប្រឈមមុខនឹងទោសប្រហារជីវិតហើយគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិយល់ឃើញថាសិទ្ធិរបស់ចុងចោទក្នុងការការពារក្តីដោយខ្លួនឯងមិនគួរត្រូវបានដាក់កំហិតទេនៅពេលដែលចុងចោទអាចនឹងទទួលទោសប្រហារជីវិត ។ ដោយសារតែទោសប្រហារជីវិតមិនមាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសកម្មភាពរំខានអាចត្រូវបានយកមកប្រៀបធៀបជាមួយនឹងការប្រើពាក្យសម្តីមិនសមរម្យ ។ អាស្រ័យហេតុនេះសកម្មភាពរំខានបែបនេះប្រសិនបើនៅតែបន្តកើតមាននិងមានលក្ខណៈប្រមាថមើលងាយអាចបង្កឲ្យមានការដាក់កំហិតទៅលើសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ ។

## ឃ) ការរំលោភទៅលើដំណើរការ

ឥរិយាបថដែលរំលោភទៅលើដំណើរការអាចប្រឈមមុខនឹងសកម្មភាពរបស់តុលាការ ។ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ករណី ខៀវ សំផន សហមេធាវីការពារក្តីអន្តរជាតិបដិសេធមិនចូលរួមក្នុងសវនាការអង្គបុរេ ដោយសារតែឯកសារទាំងអស់ដែលទាក់ទងនឹងសំណុំរឿងមិនទាន់បកប្រែជាភាសាបារាំង ។ មេធាវីនេះមិនធ្លាប់ទទួលបានការព្រមានពីអង្គបុរេជំនុំជម្រះឡើយ ។ ដូច្នេះអង្គជំនុំជម្រះត្រូវផ្អាកសវនាការដោយមិនបានរំពឹងទុកមុន ។ អង្គជំនុំជម្រះយល់ឃើញថាការប្រព្រឹត្តរបស់មេធាវីគឺជាការរំលោភទៅលើដំណើរការហើយត្រូវប្រឈមមុខនឹងសកម្មភាពរបស់តុលាការ ។ ក្រោយមក សហមេធាវីឲ្យពន្យារពេលសវនាការពីព្រោះសហមេធាវីអន្តរជាតិត្រូវទទួលខុសត្រូវក្នុងការការពារក្តីឲ្យចុងចោទនៅថ្ងៃនោះ ។ នៅក្នុងសវនាការបន្ទាប់សហមេធាវីអន្តរជាតិបានបង្ហាញខ្លួនលោកបានបដិសេធមិន «ចូលរួមការពារក្តីនៅសវនាការ» ហើយ «ខកខានមិនបានជួយការពារក្តី» ។ អង្គជំនុំជម្រះសម្រេចថាឥរិយាបថនេះអាចពន្យារពេលដំណើរការនីតិវិធីនិងការប្រើប្រាស់មិនត្រឹមត្រូវនូវធនធានរបស់តុលាការដែលអាចរារាំងដល់ដំណើរការនិងរំលោភទៅលើដំណើរការទៅតាមវិធានផ្ទៃក្នុង៣៨ ។

## ស្ថានភាពទាំងអស់ដែលធ្លាប់កើតមាន

យោងទៅតាមវចនានុក្រមច្បាប់ក្របពណ៌ខ្មៅពាក្យ«ការរំលោភទៅលើដំណើរការ» គឺជាការ «ប្រើប្រាស់ដំណើរការតុលាការដែលចេញដោយច្បាប់ដោយមិនត្រឹមត្រូវនិងស្មុគស្មាញដើម្បីទទួលបានលទ្ធផលដែលមានលក្ខណៈខុសច្បាប់ឬក៏ហួសពីវិសាលភាពរបស់ដំណើរការ» ។ ឥរិយាបថដែលអាចបង្កឲ្យមានការរំលោភទៅលើដំណើរការអាចនឹងត្រូវបានយល់ស្របនៅពេលដំបូង ។

ជាឧទាហរណ៍ សារណារបស់តុលាការអាចនឹងក្លាយទៅជាគ្មានប្រយោជន៍ប្រសិនបើការបដិសេធមិនយកចិត្តទុកដាក់នឹងដីការបស់តុលាការត្រូវបានទទួលស្គាល់ ។ ចំពោះករណីខ្លះ ឥរិយាបថដែលប្រើប្រាស់ដំណើរការតុលាការដែលស្របច្បាប់និងប្រើប្រាស់នីតិវិធីដែលត្រូវបានអនុញ្ញាតដើម្បីពន្យារពេលដំណើរការនឹងត្រូវតែប្រឈមមុខនឹងសកម្មភាពរបស់តុលាការ ។ ទោះបីជាយ៉ាងណាក៏ដោយតុលាការអន្តរជាតិតែងតែមានការលំបាកក្នុងការពន្យល់នៅពេលដែលមានភាពមួម៉ៅ ប៉ុន្តែឥរិយាបថដែលទទួលស្គាល់ដោយច្បាប់ក្លាយទៅជាការព្រួយបារម្ភជាងមុនដែលត្រូវប្រឈមមុខនឹងសកម្មភាពរបស់តុលាការ ។ ដើម្បីធ្វើការកំណត់នៅពេលដែលឥរិយាបថនេះហួសពីកម្រិតដែលតុលាការអាចទទួលយកបានតុលាការនឹងប្រើប្រាស់ស្ថានភាពទាំងអស់ដើម្បីយកមកអះអាងនៅពេលដែលមានឥរិយាបថជាក់ស្តែងមួយចំនួនដែលតុលាការមិនអាចអត់ឱនឲ្យបានដូច្នេះនាំឲ្យមានការដាក់កំហិតទៅលើសិទ្ធិរបស់ចុងចោទ ។

នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ការប្រព្រឹត្តដែលរារាំង «យ៉ាងខ្លាំងនិងម្តងហើយម្តងទៀត» ដល់ដំណើរការរបស់តុលាការត្រូវបានយល់ឃើញថាជាការរំលោភទៅលើដំណើរការ ។ ដើម្បីសម្រេចថានៅពេលណាដែលការប្រព្រឹត្តរារាំងដល់ដំណើរការកាត់ក្តី «យ៉ាងខ្លាំងនិងម្តងហើយម្តងទៀត» តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ចំពោះករណី ហេរូលហ្ស៊ី តុលាការបានប្រើ...។ នៅអំឡុងពេលចាប់ផ្តើមដំណើរការនីតិវិធីតុលាការបានបដិសេធមិនដាក់កំហិតទៅលើសិទ្ធិរបស់ចុងចោទក្នុងការតំណាងឲ្យខ្លួនឯងទោះបីជាចុងចោទ «តែងតែបង្ហាញពីនិន្នាការក្នុងការរារាំងដល់ដំណើរការ» ក្តី ។ ចំពោះចំណុចនោះចុងចោទបានប្រើយុត្តិសាស្ត្ររំខានជាច្រើនលើកច្រើនសាដោយឆ្លើយតបនឹងតុលាការ «ដោយប្រើរយៈពេលយូរនិងផ្តល់កំណត់សម្គាល់ជាលាយល័ក្ខណ៍អក្សរដែលមិនពាក់ព័ន្ធ» បដិសេធមិនប្រើប្រាស់កុំព្យូទ័រផ្ទាល់ខ្លួនដោយសារខ្លាចឆក់ខ្សែភ្លើងនិងដាក់ញ្ញាតិជាលាយល័ក្ខណ៍អក្សរដល់សាលាឧទ្ធរណ៍ ទោះបីជាចុងចោទបានដឹងថាវិធាននមិនបានអនុញ្ញាតឲ្យធ្វើបែបនេះក៏ដោយ ។ តុលាការបានសម្រេចថា «ឥរិយាបថនិងសកម្មភាព» របស់ចុងចោទគឺជាឥរិយាបថរំខាន» ។ ទោះបីជាយ៉ាងក៏ដោយ តុលាការគ្រាន់តែតាំងមេធាវីស្តីទីមួយរូបដោយអះអាងថាសិទ្ធិរបស់ចុងចោទក្នុងការការពារក្តីដោយខ្លួនឯង «មិនត្រូវបានរំលោភ» ។ មេធាវីស្តីទីត្រូវបានតាំងដើម្បី «ការពារឲ្យការកាត់ក្តីដ៏យុត្តិធម៌និងមានប្រសិទ្ធភាព» និងធ្វើជាជំនួយការរបស់ចុងចោទ ។

បីឆ្នាំក្រោយមកឥរិយាបថដែលរំលោភទៅលើដំណើរការរបស់ចុងចោទនៅតែបន្តមាន ដោយរួមមានការប្រមាថមើលងាយនិងរំខាន ។ ចុងចោទកម្រអនុវត្តតាមវិធាននីតិវិធីរបស់តុលាការដាក់សារណាដែលមិនសូវមានប្រសិទ្ធភាព១៩១ មិនគោរពភាពថ្លៃថ្នូររបស់តុលាការបង្ហាញពីគោលបំណងក្នុងការរំខានដល់តុលាការនៅក្រុងឡាអេដែលសូម្បីតែម្ចាស់ក្សត្រីនៃប្រទេសហូឡង់ក៏មិននៅស្ងៀមដែរ ដោយបោះពុម្ពសៀវភៅជាច្រើនក្បាលមានចំណងជើងប្រមាថទៅលើសាក្សីប្រើប្រាស់ភាសាមិនសមរម្យនិងតែងតែលើកឡើងពីការអះអាងដែលមិនជាប់ពាក់ព័ន្ធនៅតុលាការ ។ តុលាការចេញសេចក្តីសម្រេច ហើយសាលាឧទ្ធរណ៍យល់ស្របក្នុងករណីមីឡូសេវិក តុលាការបានសម្រេចថាការដាក់កំហិតលើសិទ្ធិចុងចោទក្នុងការតំណាងឲ្យខ្លួនឯងនឹងត្រូវយកមកប្រើប្រសិនបើចុងចោទរារាំង«យ៉ាងខ្លាំងនិងម្តងហើយម្តងទៀត» ដល់ដំណើរការកាត់ក្តីដ៏យុត្តិធម៌និងត្រឹមត្រូវរបស់តុលាការ ។ ករណីហេរូលហ្ស៊ី តុលាការមិនបានបកស្រាយថា ហេតុអ្វីបានជាឥរិយាបថបែបនោះនៅបីឆ្នាំមុនមិនមែនជាការរារាំង «យ៉ាងខ្លាំងនិងម្តងហើយម្តងទៀត» ដែលឥរិយាបថនៅពេលបច្ចុប្បន្នត្រូវបានចាត់ទុកថាដូច្នោះ ។ យើងអាចសន្និដ្ឋានថា តុលាការធ្វើសេចក្តីសម្រេចមិនមែនផ្តោតលើតែសកម្មភាពរបស់បុគ្គលតែមួយទេគឺផ្តោតទៅលើផលប៉ះពាល់ពាល់នៃឥរិយាបថរួមដ៏រំខានដោយគិតជារួម ។ តុលាការអត់ទ្រាំនឹងឥរិយាបថរបស់ចុងចោទបីឆ្នាំមកហើយ ប៉ុន្តែការប្រព្រឹត្តនោះបានមកដល់កម្រិតដែលតុលាការអាចដាក់កំហិតទៅលើសិទ្ធិរបស់ចុងចោទក្នុងការតំណាងឲ្យខ្លួនឯង ។ កត្តាមួយទៀតដែលតុលាការអាចពិចារណាគឺថាតើការរំលោភដល់ដំណើរការអាចបញ្ឈប់ការកាត់ក្តីឬអត់ឬក៏គ្រាន់តែធ្វើឲ្យដំណើការដើរយឺត ។ នៅក្នុងករណីហេរូលហ្ស៊ី សាលឧទ្ធរណ៍បានយល់ស្របនឹងតុលាការថា«វាមិនតម្រូវឲ្យយកករណីមីឡូសេវិកមកបង្ហាញថាឥរិយាបថចុងចោទគឺជាការរំខានដល់ដំណើរការនីតិវិធីដែលមិនអាចយកមកប្រើដើម្បីដាក់កំហិតលើសិទ្ធិក្នុងការតំណាងឲ្យខ្លួនទេ» ។ ទោះបីជាសកម្មភាពរបស់ចុងចោទមិនបានកើតមានដំណើរការនីតិវីធីក៏ដោយក៏សាលាឧទ្ធរណ៍យល់ស្របនឹងសេចក្តីសម្រេចរបស់តុលាការដែលថាការប្រព្រឹត្តនោះត្រូវប្រឈមមុខនឹងសកម្មភាពរបស់តុលាការ ។

ទោះបីជាការរំលោភរបស់ចុងចោទទៅលើដំណើរការតុលាការពិបាកនឹងកំណត់ តុលាការអន្តរជាតិហាក់ដូចជាពិនិត្យទៅលើស្ថានភាពទាំងអស់ដែលធ្លាប់កើតមានដោយឲ្យទម្ងន់ទៅលើផលប្រយោជន៍របស់តុលាការនិងជនជាប់ចោទនិងសម្រេចថាតើការដាក់កំហិតទៅលើសិទ្ធិនឹងត្រូវបានយកមកប្រើទៅតាមកម្រិតនៃការរំខានដែលធ្វើឡើងដោយចុងចោទដែរឬទេ ។

**(នៅមានត)**

**អាដាម ខូឌី**

# ការសម្តែងល្ខោនរឿង "ទម្លាយភាពស្ង
## ថ្ងៃទី២៣ ខែវិច្ឆិ







# ប់ស្មាត់” នៅវិទ្យាស្ថានរាជបណ្ឌិតសភា
## ច្ឆិកា ឆ្នាំ២០០៩









# ការចោទប្រកាន់អំពើពុករលួយដែលពុំមានភស្តុតាងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា : ការជាប់ពាក់ព័ន្ធនឹងការកាត់ទោសដោយយុត្តិធម៌

ការចោទប្រកាន់អំពីអំពើពុករលួយបានបន្តឲ្យមានការព្រួយបារម្ភនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាំងពីដើមឆ្នាំ២០០៧ម៉្លេះ ។ របាយការណ៍ស្តីពីអំពើពុករលួយបានលេចឡើងក្នុងអត្ថបទកាសែតជាតិនិងអន្តរជាតិនិងក្នុងរបាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាលដែលមានការអះអាងគាំទ្រដោយសក្ខីកម្មរបស់បុគ្គលិកនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ របាយការណ៍ទាំងនេះបានផ្តល់នូវព័ត៌មានច្បាស់លាស់ជាច្រើនទាក់ទិននឹងប្រព័ន្ធស៊ីសំណូកដែលបុគ្គលិកបានបង់ប្រាក់មួយចំណែកនៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់គេជូនទៅមន្ត្រីរាជរដ្ឋាភិបាលជាការប្តូរជាមួយនឹងការងារ ។ កាលពីចុងរដូវក្តៅឆ្នាំ២០០៨ បុគ្គលិកកម្ពុជាជាច្រើនបានជួបចរចាជាមួយនឹងមន្ត្រីជាន់ខ្ពស់ទាក់ទិននឹងការចោទប្រកាន់ពីអំពើពុករលួយដែលមិនមានភស្តុតាងដែលបន្តឲ្យមានជាប់ពាក់ព័ន្ធនឹងមន្ត្រីនៅក្នុងតុលាការ ។ ការចោទប្រកាន់ដែលមិនមានភស្តុតាងទាំងនេះត្រូវបានសរសេរទៅកាន់ការិយាល័យអង្គការសហប្រជាជាតិផ្នែកសេវាកម្មត្រួតត្រារបស់អន្តរជាតិ ដែលបានបើកការត្រួតពិនិត្យសាឡើងវិញដោយសម្ងាត់មួយកាលពីដើមខែសីហា ឆ្នាំ២០០៨ ។ ខណៈពេលដែលលទ្ធផលរបស់ការិយាល័យអង្គការសហប្រជាជាតិផ្នែកសេវាកម្មត្រួតត្រាអន្តរជាតិនៅតែលាក់ជាការសម្ងាត់នៅឡើយនោះ លទ្ធផលនេះត្រូវបានជឿថាបានរកឃើញការចោទប្រកាន់ពីអំពើពុករលួយដែលរួមមានជាប់ពាក់ព័ន្ធនឹងមន្ត្រីឋានៈខ្ពស់ដែលត្រូវបានគេជឿដូច្នេះ ។

ជាកិច្ចឆ្លើយតប ទាំងភាគីជាតិនិងអន្តរជាតិរបស់តុលាការបានអនុម័តវិធានការប្រឆាំងនឹងអំពើពុករលួយដែលបានសម្រេចដោយជោគជ័យរួម ។ ក្នុងខែកក្កដា ឆ្នាំ២០០៨ អ្នកជំនាញការពិសេសរបស់អង្គការសហប្រជាជាតិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបង្ហាញពីវិធានការប្រឆាំងនឹងអំពើពុករលួយថ្មីសម្រាប់បុគ្គលិកអន្តរជាតិដែលរួមមានប្រព័ន្ធរាយការណ៍ដែលត្រួតពិនិត្យសាឡើងវិញដោយការិយាល័យអង្គការសហប្រជាជាតិផ្នែកសេវាកម្មត្រួតត្រាអន្តរជាតិស្តីពីការតែងតាំងមន្ត្រីផ្នែកចរិយាមារយាទម្នាក់ដើម្បីទទួលយកបណ្តឹងតវ៉ាជាសម្ងាត់និងផ្តល់ការប្រឹក្សា និងវគ្គបំពាក់បំប៉ន និងការពិនិត្យសើរើឡើងវិញពីក្រមករណីយកិច្ចរបស់បុគ្គលិក ។ រដ្ឋបាលតុលាការកម្ពុជាក៏បានអនុវត្តវិធានការប្រហាក់ប្រហែលគ្នានេះដែរ ។ កាលពីខែសីហា ឆ្នាំ២០០៨ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុម័តក្រមករណីយកិច្ច និងបង្កើតគណៈកម្មការមួយសម្រាប់ដោះស្រាយការរំលោភច្បាប់នេះ ។ ស្របពេលជាមួយគ្នានេះដែរការិយាល័យរដ្ឋបាលបានប្រកាសពីការបង្កើតគណៈកម្មការប្រឆាំងអំពើពុករលួយថ្មីមួយដើម្បីដោះស្រាយការអះអាងដែលជាប់ពាក់ព័ន្ធនឹងបុគ្គលិកកម្ពុជា ចាត់តាំងអ្នកត្រួតពិនិត្យចរិយាមារយាទពីររូបដើម្បីទទួលយកបណ្តឹងតវ៉ា ហើយក៏បានបង្កើតនូវនីតិវិធីដែលការចោទប្រកាន់ត្រូវបានរាយការណ៍ដោយផ្ទាល់ទៅកាន់ឧបនាយករដ្ឋមន្ត្រី សុខ អាន ។ ថ្មីៗនេះ កាលពីខែសីហា ឆ្នាំ២០០៩ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាលើការបង្កើតអ្នកផ្តល់ប្រឹក្សាឯករាជ្យមួយដើម្បីដោះស្រាយបញ្ហាអំពើពុករលួយ ។ អ្នកផ្តល់ប្រឹក្សាដោយឯករាជ្យនឹងទទួលដឹងឮការចោទប្រកាន់ពីអំពើពុករលួយដោយសម្ងាត់ប្រឹក្សាជាមួយនឹងបុគ្គលិកដែលចោទប្រកាន់ថាមានជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ហើយប្រសិនបើបញ្ហានៅតែបន្តកើតមាននោះអ្នកផ្តល់ប្រឹក្សានឹងរាយការណ៍បណ្តឹងតវ៉ាទៅកាន់អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ ទោះបីជាការវិវត្តទៅមុខបានបង្ហាញពីដំណើរឆ្ពោះទៅមុខដ៏សំខាន់ក៏ដោយ ក៏ការអភិវឌ្ឍទាំងនេះមិនទាន់គ្រប់គ្រាន់ដើម្បីដោះស្រាយការចោទប្រកាន់ដោយគ្មានភស្តុតាងកាលពីមុន ឬដើម្បីការពារអំពើពុករលួយ

កុំឲ្យកើតមាននៅពេលអនាគតបានដែរ ។ នីតិវិធីបច្ចុប្បន្នមិនបានរួមបញ្ចូលយន្តការមួយដើម្បីដោះស្រាយបណ្តឹងតវ៉ាកាលពីមុន ឬការពារបុគ្គលិកដែលត្រូវបានរាយការណ៍ទាក់ទិននឹងអំពើពុករលួយឡើយ ។ ជាមួយគ្នានេះ នីតិវិធីទាំងនេះមានកង្វះខាតតម្រូវការរបាយការណ៍ជាសាធារណៈមួយ និងបន្តបដិសេធមិនទទួលស្គាល់អាជ្ញាធររបស់ការិយាល័យអង្គការសហប្រជាជាតិផ្នែកសេវាកម្មត្រួតត្រាអន្តរជាតិដើម្បីរៀបចំការស៊ើបអង្កេតមួយក្នុងការចោទប្រកាន់ពីអំពើពុករលួយ ។ ការចោទប្រកាន់ទាំងនេះត្រូវបានធ្វើឲ្យមានការព្រួយបារម្ភពីសំណាក់ភាគីជាតិនិងអន្តរជាតិ និងបានធ្វើឲ្យមានភាពមិនទុកចិត្តរវាងទំនាក់ទំនងរបស់តុលាការជាមួយនឹងសហគមន៍ប្រជាជាតិដែលផ្តល់ជំនួយ ។ ប្រសិនបើអំពើពុករលួយរបស់ការិយាល័យរដ្ឋបាលឬចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅតែបន្តកើតមានដោយគ្មានការដាក់ទោសទេនោះ វានឹងបំផ្លាញភាពដែលអាចជឿជាក់បានរបស់តុលាការ និងគំរាមកំហែងដល់ភាពមិនលម្អៀង និងឯករាជ្យភាពរបស់តុលាការកាត់ទោសជាពុំខាន ។ អត្ថបទនេះនឹងពិភាក្សាពីការជាប់ពាក់ព័ន្ធនឹងការកាត់ទោសដោយយុត្តិធម៌ទាក់ទិននឹងអំពើពុករលួយរបស់បុគ្គលិករដ្ឋបាល និងចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយនឹងបង្ហាញពីសេចក្តីណែនាំមួយចំនួនផងដែរ ។

## អំពើពុករលួយរបស់ការិយាល័យរដ្ឋបាលក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បុគ្គលិកការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបំពេញតួនាទីមួយចំនួនធំ ។ ការិយាល័យរដ្ឋបាលធ្វើការផ្គត់ផ្គង់លើចៅក្រម ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត និងកិច្ចប្រជុំពេញអង្គក្នុងការបំពេញតួនាទីរបស់គេ ។ ដូច្នេះ ការិយាល័យរដ្ឋបាលទទួលខុសត្រូវក្នុងការបំពេញការការពារសុវត្ថិភាពតម្រូវការផ្នែករដ្ឋបាល និងផ្នែកសម្ភារៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើរតួជាបណ្តាញផ្លូវការសម្រាប់ទំនាក់ទំនងអន្តរជាតិ និងទំនាក់ទំនងផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រក្សាទិន្នន័យសំណុំរឿងទាំងអស់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធានាការការពារការរក្សាទុក និងសុវត្ថិភាពរបស់ភ័ស្តុតាងនិងរៀបចំសម្រួលវគ្គបំពាក់បំប៉នរបស់បុគ្គលិកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

អំពើពុករលួយមួយចំនួនតូចរបស់បុគ្គលិករដ្ឋបាលផ្ទាល់នឹងមិនអាចរារាំងដល់ដំណើរការតុលាការដែលប្រកបដោយឯករាជ្យភាពនិងភាពមិនលម្អៀងមួយនេះបានទេ ។ ឯកសារស្ថាបនារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងច្បាប់អន្តរជាតិមិនបានតម្រូវឲ្យមានឯករាជ្យភាព ភាពមិនលម្អៀង ឬសូម្បីតែកិនភាគគុណភាពនៃបុគ្គលិករដ្ឋបាលផង ។ ក្នុងមាត្រា៣១របស់ច្បាប់បង្កើតអង្គជំនុំជម្រះសាលាដំបូងតម្រូវឲ្យនាយកការិយាល័យរដ្ឋបាល «ជាបុគ្គលដែលប្រកបដោយក្រមសីលធម៌ខ្ពស់ និងសេចក្តីថ្លៃថ្នូរ» ។ ផ្ទុយទៅវិញ មាត្រាទី១០តម្រូវឲ្យចៅក្រម «ជាបុគ្គលឯករាជ្យក្នុងការបំពេញមុខងាររបស់គេ» និងប្រកាន់ខ្ជាប់នូវ «ស្មារតីឥតលម្អៀង» ។ ប្រហាក់ប្រហែលគ្នានេះដែរ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានដាក់បញ្ចូលនីតិវិធីសម្រាប់ភាពមិនពេញលក្ខណៈរបស់បុគ្គលិករដ្ឋបាលសម្រាប់អាកប្បកិរិយាក្នុងការរំលោភបទដ្ឋានរបស់តុលាការកាត់ទោសដោយយុត្តិធម៌ឡើយ ។

ខណៈពេលដែលតុលាការមិនទាន់បានធ្វើសេចក្តីសម្រេចលើបញ្ហានេះដោយផ្ទាល់នោះ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា លក្ខន្តិកៈទាក់ទិននឹងឯករាជ្យភាព និងភាពមិនលម្អៀង «ជាចំខាតត្រូវអនុវត្តដោយចៅក្រមតែប៉ុណ្ណោះ មិនមែនសហព្រះរាជអាជ្ញាទេ» ។

១) ដោយសារតែអ្នកស៊ើបអង្កេតមិនត្រឹមតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យរដ្ឋបាលប៉ុណ្ណោះទេ ថែមទាំងត្រូវបានផ្ទេរសិទ្ធិ «ទៅឲ្យអាជ្ញាធរតុលាការស៊ើរតែទាំងស្រុង» ផង ២) វាមិនអាចទេដែលថាសហព្រះរាជអាជ្ញាស៊ើបអង្កេតអាចបង្កើតលក្ខន្តិកៈស្រដៀងគ្នាមួយសម្រាប់ការិយាល័យរដ្ឋបាលទាំងស្រុងនោះ ទោះបីជាបានបដិសេធនឹងលក្ខន្តិកៈទាក់ទិននឹងឯករាជ្យភាពនិងភាពមិនលម្អៀងសម្រាប់អ្នកស៊ើបអង្កេតក៏ដោយ ។ មុខងារនេះមានភាពស៊ីចង្វាក់គ្នានឹងបទដ្ឋានសម្រាប់បុគ្គលិករដ្ឋបាល

ក្នុងតុលាការព្រហ្មទណ្ឌពិសេសណាមួយផ្សេងទៀត ។

យ៉ាងណាមិញ ទោះបីជាភាពលម្អៀងមួយផ្នែករបស់បុគ្គលិករដ្ឋបាលមួយចំនួនតូចមិនអាចនឹងធ្វើឲ្យប៉ះពាល់ដល់ដំណើរការធ្វើសេចក្តីសម្រេចរបស់តុលាការក៏ដោយ ក៏អំពើពុករលួយផ្នែករដ្ឋបាលទូទៅនេះអាចនឹងធ្វើឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់តុលាការកាត់ទោសដោយយុត្តិធម៌ដែរ ។ ដោយសារតែព័ត៌មានសំណុំរឿងទាំងអស់ដែលចៅក្រមទទួលបានត្រូវបានរៀបចំទុកជាមុនដោយបុគ្គលិករដ្ឋបាល នោះបុគ្គលិកអាចមានសមត្ថភាពផ្លាស់ប្តូរព័ត៌មានសំណុំរឿងដើម្បីផ្តល់ជាគុណប្រយោជន៍មិនស្មើភាពមួយឲ្យភាគីម្ខាងលើភាគីដទៃផ្សេងទៀត ។ ទង្វើបែបនេះអាចធ្វើឲ្យមានការផ្លាស់ប្តូរដល់តុល្យការនៃភាពចម្រូងចម្រាស និងរារាំងដល់ភាពស្មើគ្នារបស់អង្គភាពឬភាពស្មើគ្នានៃនីតិវិធីរបស់ភាគីទាំងអស់ ។ ប្រសិនបើអំពើពុករលួយផ្នែករដ្ឋបាលទូទៅបណ្តាលឲ្យសេចក្តីសម្រេចរបស់តុលាការអាស្រ័យលើភស្តុតាងដែលត្រូវបានផ្លាស់ប្តូររួចហើយនោះ វាអាចនឹងធ្វើឲ្យខូចទម្រង់យុត្តិធម៌និងអាចរារាំងដល់តុលាការកាត់ទោសដោយឯករាជ្យនិងដោយឥតលម្អៀងនេះបាន ។

បន្ថែមលើតុលាការកាត់ទោសប្រកបដោយសក្តានុភាពយុត្តិធម៌ អំពើពុករលួយផ្នែករដ្ឋបាលទូទៅអាចនឹងបន្ទុចធម្មានុរូបភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាមួយនឹងសាធារណជនក្នុងស្រុកនិងក្រៅស្រុក ហើយនឹងអាចដំណើរការខុសពីគោលដៅក្នុងការធ្វើជាឧទាហរណ៍នៃការអនុវត្តដ៏ល្អបំផុតមួយសម្រាប់តុលាការផ្សេងទៀតបាន ។ ក្នុងនាមជាតុលាការកូនកាត់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានបន្ទុកក្នុងការធ្វើជាឧទាហរណ៍នៃការអនុវត្តដ៏ល្អបំផុតសម្រាប់តុលាការក្នុងស្រុក ។ បន្ទុកនេះជាប់ពាក់ព័ន្ធជាពិសេសនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពីព្រោះថាប្រព័ន្ធច្បាប់កម្ពុជាត្រូវបានទទួលស្គាល់ជាសកលថាមានភាពទន់ខ្សោយ ខ្វះឯករាជ្យភាព និងពោរពេញដោយអំពើពុករលួយ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុញ្ញាតឲ្យអំពើពុករលួយផ្នែករដ្ឋបាលទូទៅបន្តកើតឡើងទៀតដោយគ្មានការដាក់ទោសទេនោះ វានឹងបង្ហាញឲ្យឃើញនូវឥរិយាបថទទួលស្គាល់ឬការទទួលស្គាល់អំពើពុករលួយតែម្តង ។ ការធ្វើបែបនេះអាចធ្វើឲ្យខាតបង់នូវឱកាសក្នុងការផ្តល់ជាគំរូនៃតុលាការកាត់ទោសដោយយុត្តិធម៌សម្រាប់ប្រព័ន្ធច្បាប់កម្ពុជា សហគមន៍ផ្នែកច្បាប់ និងសាធារណជនទូទៅ ហើយនេះក៏អាចធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងកិត្តិយសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) ដែរ ។

ការឆ្លើយតបប្រកបដោយជោគជ័យសម្រាប់អំពើពុករលួយផ្នែករដ្ឋបាលទូទៅ ទាមទារនូវដំណោះស្រាយសម្រាប់យន្តការប្រឆាំងនឹងអំពើពុករលួយក្នុងពេលបច្ចុប្បន្នដូចជា ការអនុម័តយន្តការការពារសម្រាប់សាក្សី និងអ្នកផ្តល់ព័ត៌មានខុសច្បាប់ដល់សមត្ថកិច្ច ការបង្កើនការត្រួតពិនិត្យលក្ខណៈអន្តរជាតិ និងការផ្តល់នូវដំណោះស្រាយរបស់តុលាការ ។ ខណៈពេលដែលការបង្កើតតំណែងអ្នកផ្តល់ប្រឹក្សាឯករាជ្យបង្ហាញនូវការបរាជ័យដ៏សំខាន់សម្រាប់យន្តការប្រឆាំងនឹងអំពើពុករលួយកាលពីមុន លក្ខណៈសម្បត្តិដែលបុគ្គលិកកម្ពុជាត្រូវរាយការណ៍ពីការចោទប្រកាន់អំពើពុករលួយទៅកាន់អ្នកត្រួតពិនិត្យផ្នែកចរិយាមារយាទរបស់កម្ពុជាជំនួសឲ្យការរាយការណ៍ដោយផ្ទាល់ទៅកាន់មន្ត្រីអង្គការសហប្រជាជាតិវិញ នោះនឹងមិនត្រូវបានធ្វើឡើងដោយអមជាមួយនឹងយន្តការការពារខ្លួនសម្រាប់បុគ្គលិកដែលរាយការណ៍ពីអំពើពុករលួយឡើយ ។ ប្រព័ន្ធស៊ីសំណូកត្រូវបានចាត់ទុកថាមាន



ម៉ាទីន ហ្សាកាំង ហ្វីលីព កាណុន គង់

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ និងអន្តរជាតិ

ភាពធំទូលាយ និងមានមន្ត្រីជាន់ខ្ពស់កម្ពុជានៅក្នុងនោះ ហើយថា បុគ្គលិកដែលបានដាក់ពាក្យបណ្តឹងពីអំពើពុករលួយកាលពីមុនត្រូវបានរាយការណ៍ថាត្រូវបានគំរាមកំហែងនិងធ្វើទុក្ខបុកម្នេញ ។ ការបន្ថែមនូវអ្នកផ្តល់ប្រឹក្សាមិនអាចនឹងជំរុញឲ្យបុគ្គលិករាយការណ៍ករណីមានអំពើពុករលួយទេ ប្រសិនបើគ្មានប្រព័ន្ធរួចជាស្រេចមួយដើម្បីធានាការការពារខ្លួនរបស់គេក៏ដូចជាគ្រួសាររបស់គេនោះ ។ ដើម្បីដោះស្រាយបញ្ហាអំពើពុករលួយផ្នែករដ្ឋបាលទូទៅនេះឲ្យបានជោគជ័យ យន្តការប្រឆាំងនឹងអំពើពុករលួយត្រូវតែដាក់បញ្ចូលយន្តការការពារខ្លួនរួមជាមួយផង ។

ជាមួយគ្នានេះផងដែរ អ.វ.ត.ក គួរតែពិចារណាទៅលើភាពដែលអាចកើតមានឡើងនៃការត្រួតពិនិត្យជាលក្ខណៈអន្តរជាតិបន្ថែមទៀតដើម្បីដោះស្រាយនូវបញ្ហាអំពើពុករលួយផ្នែករដ្ឋបាលទូទៅនេះ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិធ្លាប់បានជួបប្រទះនឹងបញ្ហាស្រដៀងគ្នានេះទាក់ទិននឹងអំពើពុករលួយរបស់បុគ្គលិក និងផលវិបាកជាមួយនឹងមន្ត្រីផ្នែករដ្ឋបាលថ្នាក់លើដែរ ប៉ុន្តែតុលាការព្រហ្មទណ្ឌអន្តរជាតិទាំងនេះបានទាញយកប្រយោជន៍ពីការត្រួតពិនិត្យជាលក្ខណៈអន្តរជាតិក្នុងកម្រិតខ្ពស់ជាងអ.វ.ត.ក ។ ការិយាល័យអង្គសហប្រជាជាតិផ្នែកសេវាកម្មត្រួតពិនិត្យជាលក្ខណៈអន្តរជាតិបានធ្វើការយ៉ាងមានប្រសិទ្ធភាពក្នុងការរៀបចំដំណើរការស៊ើបអង្កេតនិងផ្តល់នូវសេចក្តីណែនាំជាពិសេសដល់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ ផ្ទុយទៅវិញ រាជរដ្ឋាភិបាលកម្ពុជាប្រកាន់ខ្ជាប់នូវសិទ្ធិដាច់ដោយឡែកក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់ពីអំពើពុករលួយដែលជាប់ពាក់ព័ន្ធនឹងមន្ត្រីកម្ពុជាដោយបដិសេធមិនទទួលយកជំនួយពីមជ្ឈដ្ឋានអន្តរជាតិ ។ ឧទាហរណ៍ ការិយាល័យអង្គការសហប្រជាជាតិផ្នែកសេវាកម្មត្រួតពិនិត្យជាលក្ខណៈអន្តរជាតិមិនត្រូវបានអនុញ្ញាតឲ្យរៀបចំ «ដំណើរការស៊ើបអង្កេត» ក្នុងបញ្ហាចោទប្រកាន់អំពើពុករលួយនៅអ.វ.ត.កឡើយ ផ្ទុយទៅវិញបែរជាអនុញ្ញាតឲ្យរៀបចំ «ការត្រួតពិនិត្យសាឡើងវិញ» ដើម្បីសម្រេចថាតើការចោទប្រកាន់ទាំងនេះអាចនឹងជឿជាក់បានគ្រប់គ្រាន់ដែរឬទេ ដើម្បីធ្វើឲ្យការស៊ើបអង្កេតរបស់កម្ពុជាមានភាពយុត្តិធម៌ ។ ដោយពិចារណាទៅលើកំណត់ត្រាប្រកបដោយជោគជ័យនៃដំណើរការស៊ើបអង្កេតរបស់ការិយាល័យអង្គការសហប្រជាជាតិផ្នែកសេវាកម្មត្រួតពិនិត្យជាលក្ខណៈអន្តរជាតិ និងអសមត្ថភាពរបស់ការិយាល័យរដ្ឋបាលក្នុងការការពារខ្លួនប្រកបដោយប្រសិទ្ធភាពនិងភាពសត្យានុម័ត ប្រសិនបើត្រូវបានសម្របសម្រួលដោយអំពើពុករលួយជាទូទៅនោះ អ.វ.ត.ក គួរតែពិចារណាឲ្យមានការត្រួតពិនិត្យជាលក្ខណៈអន្តរជាតិបន្ថែមទៀត ដូចជាការត្រួតពិនិត្យពីសំណាក់មន្ត្រីស៊ើបអង្កេតរបស់ការិយាល័យអង្គការសហប្រជាជាតិផ្នែកសេវាកម្មត្រួតពិនិត្យជាលក្ខណៈអន្តរជាតិនិងដំណើរការស៊ើបអង្កេតជារួមរបស់កម្ពុជានិងមជ្ឈដ្ឋានអន្តរជាតិលើបុគ្គលិកជាតិកម្ពុជា ។ ជាចុងក្រោយបង្អស់នេះ អ.វ.ត.ក គួរតែបេញលទ្ធផលនៃការត្រួតពិនិត្យសាឡើងវិញរបស់ការិយាល័យអង្គសហប្រជាជាតិផ្នែកសេវាកម្មត្រួតពិនិត្យជាលក្ខណៈអន្តរជាតិកាលពីឆ្នាំ២០០៨ ទៅកាន់ភាគីពាក់ព័ន្ធដូចដែលបានស្នើសុំដោយមេធាវីការពារក្តី និងភាគីដើមបណ្តឹងរដ្ឋប្បវេណី ហើយដូចដែលបានគាំទ្រនៅក្នុងគោលការណ៍ដោយព្រះរាជអាជ្ញា ។




ប្រសិនបើដំណោះស្រាយផ្នែករដ្ឋបាលពុំគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាអំពើពុករលួយផ្នែករដ្ឋបាលទូទៅទេ នោះដំណោះស្រាយរបស់តុលាការនឹងអាចមានលក្ខណៈសមហេតុផល ។ ដូចដែលបាននិយាយម្តងរួចហើយនោះ អំពើពុករលួយជាទូទៅអាចនឹងប៉ះពាល់ផ្ទាល់ដល់សេចក្តីសម្រេចរបស់តុលាការប្រសិនបើអំពើពុករលួយនេះមានសភាពធ្ងន់ធ្ងរដែលនាំឲ្យមានការផ្លាស់ប្តូរផ្នែកភស្តុតាងសំខាន់ដើម្បីជួយឲ្យភាគីម្ខាងទទួលបានប្រយោជន៍លើភាគីដទៃទៀត ឬប្រសិនបើអំពើពុករលួយនេះ

អាចប៉ះពាល់ដល់គោលជំនឿរបស់អ.វ.ត.ក ក្នុងនាមជាស្ថាប័នឥតលម្អៀងនិងឯករាជ្យមួយ ។ ក្នុងករណីផ្សេងទៀត ដំណោះស្រាយរបស់តុលាការអាចនឹងតម្រូវឲ្យធ្វើការថែរក្សាការពារលក្ខណៈដើមរបស់ដំណើរការនីតិវិធី ។ នៅក្នុងវិធានផ្ទៃក្នុង វិធានការតុលាការឬវិធានការស៊ើបអង្កេតអាចនឹងធ្វើឲ្យបញ្ហានីតិវិធីទុកជាមោឃៈក្នុងករណីដែលបញ្ហានេះរំលោភលើសិទ្ធិរបស់ភាគីក្នុងការបង្កើតការអនុវត្តវិធាននេះ ។ ប្រសិនបើបញ្ហាអំពើពុករលួយផ្នែករដ្ឋបាលទូទៅក្លាយជាបញ្ហាធ្ងន់ធ្ងរដែលនាំធ្វើឲ្យរារាំងដល់តុលាការកាត់ទោសដោយយុត្តិធម៌ នោះចៅក្រមអាចនឹងត្រូវតម្រូវឲ្យលុបចោលដំណើរការនីតិវិធីសម្រាប់បញ្ហានីតិវិធី ។

## អំពើពុករលួយរបស់ចៅក្រមនៅអ.វ.ត.ក

អំពើពុករលួយរបស់ចៅក្រមនៅអ.វ.ត.ក អាចនឹងរារាំងដល់ដំណើរការតុលាការកាត់ទោសដ៏ឯករាជ្យ និងឥតលម្អៀងបានជាពិសេសប្រសិនបើអំពើពុករលួយនេះប៉ះពាល់ដល់សេចក្តីសម្រេចឬការជ្រើសតាំងរបស់តុលាការ ។ ខុសពីបុគ្គលិកផ្នែករដ្ឋបាល ឯកសារស្នូលរបស់ អ.វ.ត.ក តម្រូវយ៉ាងច្បាស់លាស់ឲ្យចៅក្រមអនុវត្តនូវភាពមិនលម្អៀងនិងឯករាជ្យភាព ។ ឯករាជ្យភាពសំដៅទៅលើសមត្ថភាពរបស់អ្នកចេញសេចក្តីសម្រេចរបស់តុលាការក្នុងការសម្រេចដោះស្រាយបញ្ហាដោយគ្មានឥទ្ធិពលមិនសមរម្យណាមួយពីសំណាក់ខ្សែបណ្តាញរាជរដ្ឋាភិបាល ភាគីឬពីប្រភពផ្សេងទៀតឡើយ ។ ចំណែកភាពមិនលម្អៀងវិញគឺទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងអព្យាក្រឹតភាពនិងតម្រូវឲ្យអ្នកចេញសេចក្តីសម្រេចរបស់តុលាការដោះស្រាយករណីឬបញ្ហាពិសេសណាមួយដោយគ្មានភាពរើសអើងឡើយ ។ ភាពមិនលម្អៀងមានទាំងទស្សនៈអត្តនោម័តដែលសំដៅទៅលើភាពលម្អៀងជាក់លាក់ណាមួយនិងរួមទាំងទស្សនៈសត្យានុម័តដែលសំដៅទៅលើលក្ខណៈនៃភាពលម្អៀង ។ គុណភាពទាំងពីនេះត្រូវបានគំរាមកំហែងដោយអំពើពុករលួយរបស់តុលាការ ។

អំពើពុករលួយរបស់ចៅក្រមនៅ អ.វ.ត.ក អាចនឹងប៉ះពាល់ដល់ភាពមិនលម្អៀង ប្រសិនបើវាប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការក្នុងករណីពិសេសណាមួយដែលទាក់ទិននឹងការចោទសួរចៅក្រមពីការដកសិទ្ធិធ្វើជាចៅក្រម ។ ច្បាប់អ.វ.ត.ក បានចែងសម្រាប់ការដកសិទ្ធិធ្វើជាចៅក្រមក្នុងករណីណាដែលចៅក្រមទទួលបាននូវផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុឬផ្ទាល់ខ្លួន ឬទាក់ទងនិងនឹងករណីដែលចៅក្រមមានឬបានមានការសហការណាមួយដែលអាចប៉ះពាល់ដល់ភាពមិនលម្អៀងរបស់គេដោយអត្តនោម័តឬអាចនឹងធ្វើឲ្យលក្ខណៈនៃភាពលម្អៀងកើនឡើងដោយអត្តនោម័ត ។ ដើម្បីតម្រូវទៅតាមការសាកល្បងនេះ ភាគីដែលព្យាយាមបង្ហាញនូវការដកសិទ្ធិធ្វើជាចៅក្រមត្រូវតែមានលក្ខណៈសម្បត្តិខ្ពស់មួយដើម្បីព្យាយាមទទួលបាននូវការសន្មតថាបានប្រកាន់នូវភាពមិនលម្អៀងដែលត្រូវប្រកាន់ខ្ជាប់ជាមួយនឹងចៅក្រមដោយផ្អែកទៅលើការសច្ចាប្រណិធាននិងលក្ខណៈសម្បត្តិសម្រាប់មុខតំណែងរបស់គេ ។ ដើម្បីជម្នះបន្ទុកភារៈនេះ ភាគីដែលព្យាយាមបង្ហាញថាមានលក្ខណៈសម្បត្តិនោះត្រូវតែបង្ហាញឲ្យឃើញនូវភាពលម្អៀងដែលត្រូវបានយល់ឃើញឬដែលត្រូវបានមើលឃើញច្បាស់តែម្តង ។ ភាពលម្អៀងដែលត្រូវបានយល់ឃើញអាចនឹងបង្ហាញបានដោយស្ថិតនៅក្រោមការសាកល្បងដែលមានអ្នកសង្កេតប្រកបដោយលក្ខណៈវិនិច្ឆ័យខ្ពស់ដែលអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានបង្កើតឡើងនៅក្នុងសេចក្តីសម្រេចករណី ហ្វ៊ុរុនឌីហ្សា និងដែលអង្គបុរេជំនុំជម្រះ អ.វ.ត.ក បានអនុម័តនៅក្នុងសេចក្តីសម្រេចរបស់ចៅក្រម នៃ ថុល ។ ដោយស្ថិតនៅក្រោមការសាកល្បងប្រកបដោយអ្នកសង្កេតដែលមានលក្ខណៈវិនិច្ឆ័យខ្ពស់ វានឹងមានលក្ខណៈនៃភាពលម្អៀងដែលមិនសមហេតុផលមួយ ប្រសិនបើកាលៈទេសៈអាចជំរុញឲ្យអ្នកសង្កេតប្រកបដោយលក្ខណៈវិនិច្ឆ័យខ្ពស់ប្រាប់នូវភាពលម្អៀងដែលអាចយល់បានដោយសមហេតុផល ។ ការសាកល្បងដែលមានអ្នកសង្កេតប្រកបដោយលក្ខណៈវិនិច្ឆ័យខ្ពស់នេះមានភាពស៊ីចង្វាក់គ្នានឹងការសាកល្បងពីភាពលម្អៀងប្រហាក់ប្រហែលគ្នាជាច្រើននៅក្នុងប្រព័ន្ធច្បាប់ជាតិនិងអន្តរជាតិ ។

ខណៈពេលដែលការសាកល្បងដែលមានអ្នកសង្កេតប្រកបដោយលក្ខណៈវិនិច្ឆ័យខ្ពស់នេះមិនបានតម្រូវឲ្យមានការបង្ហាញនូវភាពលម្អៀងដែលអាចមើលឃើញច្បាស់ នោះភាពលម្អៀងដែលយល់ច្បាស់ត្រូវតែមានភាពទាក់ទិនគ្នាមួយទៅនឹងករណីនោះមិនអាចនឹងគួរឲ្យជឿជាក់នឹងអាចក្លាយជាសេចក្តីអះអាង

ដ៏ពិបាក ។ ដោយស្ថិតនៅក្រោមបទដ្ឋានអន្តរជាតិបច្ចុប្បន្ន ដើម្បីសម្រេចឲ្យបានទៅតាមការអនុវត្តមួយសម្រាប់ការដកសិទ្ធិធ្វើជាចៅក្រមនោះ ញត្តិត្រូវតែបង្ហាញថា វាអាចធ្វើទៅបានសម្រាប់អ្នកសង្កេតដែលប្រកបដោយលក្ខណៈវិនិច្ឆ័យខ្ពស់ក្នុងការប្រាប់ឲ្យត្រឹមត្រូវ យល់ឲ្យសមហេតុផលថា ការចូលរួមនៅក្នុងប្រព័ន្ធស៊ីសំណូកដើម្បីប្តូរយកការងារនេះអាចនឹងបង្កើតនូវការប៉ុនប៉ងផ្នែកហិរញ្ញវត្ថុដ៏សំខាន់ ឬដែលអាចកើតឡើងដើម្បីសម្រេចចោទប្រកាន់ ឬផ្តន្ទាទោសអ្នកអនុវត្តឬជនជាប់ចោទទាំងអស់ពីបក្សពួករបស់គេ ឬជនជាប់ចោទទាំងអស់ ។ យោងទៅតាមការចោទប្រកាន់បច្ចុប្បន្ន ចៅក្រមដែលជាប់ពាក់ព័ន្ធនឹងប្រព័ន្ធស៊ីសំណូកដើម្បីប្តូរយកការងារ ប៉ុន្តែដោយគ្មានការគាបសង្កត់ដើម្បីទាញយកប្រយោជន៍ពីភាគីម្ខាងលើភាគីដទៃទៀតនៅក្នុងករណីពិសេសណាមួយនោះ គឺទំនងជាមិនអាចប្រឈមមុខនឹងការដកសិទ្ធិធ្វើជាចៅក្រមឡើយ ។

ខណៈពេលដែលអំពើពុករលួយរបស់តុលាការទំនងជាមិនអាចរារាំងដល់ភាពមិនលម្អៀង ប្រសិនបើវាមិនប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការដោយផ្ទាល់ នោះអំពើពុករលួយរបស់តុលាការទំនងជាធ្វើឲ្យឯករាជ្យភាពមានភាពចុះខ្សោយដោយសារតែការសម្របសម្រួលដំណើរការជ្រើសរើសរបស់តុលាការឬដោយសារតែការរារាំងមិនឲ្យចៅក្រមអនុវត្តឯករាជ្យភាពក្នុងការបំពេញមុខងាររបស់ខ្លួន ។ ចៅក្រមកម្ពុជារបស់ អ.វ.ត.ក ត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានសមាជិកចំនួន៩រូបតែងតាំងដោយព្រះមហាក្សត្រ ហើយកាលពីមុនត្រូវបានរិះគន់សម្រាប់ការបំពេញមុខងារក្នុងនាមជាអ្នកជំនួយការរបស់គណបក្សដឹកនាំ ។

មាត្រាដំបូងបង្អស់របស់អាជ្ញាធរសម្រាប់ជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិនៅក្នុងក្រុមរបស់ប្រទេសកម្ពុជាបានដាក់បញ្ចូលគោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ «គោលការណ៍ជាមូលដ្ឋាន» ដែលតម្រូវថាវិធីសាស្ត្រនៃការជ្រើសតាំងរបស់តុលាការណាមួយត្រូវតែការពារប្រឆាំងនឹងការតែងតាំងតំណែងរបស់តុលាការសម្រាប់ហេតុផលមិនសមរម្យ ។ ប្រសិនបើការជ្រើសតាំងរបស់តុលាការត្រូវបានទទួលឥទ្ធិផលដោយប្រព័ន្ធស៊ីសំណូក នោះការតែងតាំងតំណែងរបស់តុលាការអាចនឹងធ្វើឡើងដោយផ្អែកនឹងហេតុផលមិនសមរម្យនិងអាចរើសអើងលើចៅក្រមដែលគ្មានទ្រព្យសម្បត្តិផ្នែកហិរញ្ញវត្ថុ ឬគ្មានទំនាក់ទំនងនឹងនយោបាយដែលមានសារៈសំខាន់ដើម្បីចូលរួមនៅក្នុងប្រព័ន្ធស៊ីសំណូកនេះ ។ ទង្វើបែបនេះអាចនឹងក្លាយជាការរំលោភបំពានលើគោលការណ៍ជាមូលដ្ឋាន ។ បន្ថែមទៅលើការសម្របសម្រួល រក្សាលក្ខណៈដើមនៃដំណើរការជ្រើសតាំងរបស់តុលាការនេះ ប្រព័ន្ធស៊ីសំណូកអាចនឹងគំរាមគំហែងដល់ឯករាជ្យភាពរបស់តុលាការដោយទាញយកប្រយោជន៍ពីរាជរដ្ឋាភិបាល ដោយឥទ្ធិពលគ្មានដែនកំណត់លើសេចក្តីសម្រេចរបស់តុលាការ ។ ប្រសិនបើចៅក្រមចូលរួមក្នុងប្រព័ន្ធស៊ីសំណូកដើម្បីទទួលបានការតែងតាំងតំណែងរបស់តុលាការនោះពួកគេអាចមានអារម្មណ៍ជំពាក់គុណរាជរដ្ឋាភិបាលរបស់គេដោយមិនរើសអើងថាតើប្រាក់បៀវត្សរ៍អាចនឹងបន្តកើនឡើងក្រោយពីការតែងតាំងឲ្យចូលបម្រើការងារនៅក្នុងអ.វ.ត.កឡើយ ។ ប្រសិនបើសេចក្តីសម្រេចរបស់តុលាការទទួលរងផលប៉ះពាល់ នោះវាអាចនឹងធ្វើឲ្យសមត្ថភាពរបស់ចៅក្រមក្នុងការបំពេញមុខងារខ្លួនដោយឯករាជ្យភាពនោះមានភាពចុះខ្សោយ ។ បន្ថែមលើនេះ វាអាចធ្វើឲ្យប៉ះពាល់ដល់តុល្យភាពដ៏ល្អរវាងឯករាជ្យភាពរបស់តុលាការនិងលក្ខខណ្ឌគ្រប់គ្រងលើការតែងតាំងបាន ។ ខណៈពេលដែលតុលាការទាំងអស់បានជួបប្រទះនឹងបញ្ហាតុល្យការនេះដោយគ្មានការលើកលែង នោះតុលាការទាំងអស់តម្រូវឲ្យចៅក្រមអនុវត្តនិងប្រកាន់គោលជំហរឯករាជ្យភាពក្នុងការបំពេញមុខងារតាមមុខតំណែងរបស់ខ្លួន ។

ជាមួយនឹងបញ្ហាអំពើពុករលួយផ្នែករដ្ឋបាលទូទៅ ប្រសិនបើអំពើពុករលួយរបស់តុលាការរារាំងដល់ឯករាជ្យភាពរបស់តុលាការ នោះតុលាការនឹងបរាជ័យក្នុងការបង្កើតជាឧទាហរណ៍ការអនុវត្តដ៏ល្អបំផុតសម្រាប់តុលាការក្នុងស្រុកបាន ។ កេរដំណែលអ្នកកាន់អំណាចរបស់ប្រទេសកម្ពុជាបានបង្កើតប្រព័ន្ធច្បាប់ក្នុងស្រុកមួយដែលតុលាការទាំងអស់បានដើរតួជាឧបករណ៍របស់រដ្ឋ ។ សព្វថ្ងៃ កាលៈទេសៈនេះត្រូវបូករួមបញ្ចូលគ្នាដោយកង្វះខាតធនធាននិងវគ្គបំពាក់បំប៉នផ្នែកច្បាប់ទូទាំងប្រទេស ដូច្នេះហើយ

ទើបតុលាការកម្ពុជាទទួលរងនូវផលវិបាកមិនត្រឹមតែពីបញ្ហាសមត្ថភាពប៉ុណ្ណោះ ប៉ុន្តែថែមទាំងពីឥរិយាបថអវិជ្ជមានទៅលើឯករាជ្យភាពនិងភាពមិនលម្អៀងរបស់តុលាការទៀតផង ។ អ.វ.ត.កបានផ្តល់នូវវិធីសាស្ត្រមួយដើម្បីបង្ហាញពីសារៈសំខាន់របស់តុលាការកាត់ទោសដោយឥតលម្អៀងនិងដោយឯករាជ្យភាព ស្របពេលដែលបានផ្តល់នូវវគ្គបំពាក់បំប៉នផ្នែកច្បាប់ និងបទពិសោធន៍របស់តុលាការដោយផ្ទាល់ទៅកាន់បុគ្គលិកតុលាការកម្ពុជាដែលបានចូលរួម ។ ប្រសិនបើអំពើពុករលួយរបស់តុលាការនឹងធ្វើឲ្យបទដ្ឋាននៃឯករាជ្យភាពរបស់តុលាការមានភាពចុះថយ នោះវាអាចធ្វើឲ្យខាតបង់នូវឱកាសដើម្បីបង្កើតជាឧទាហរណ៍អនុវត្តដ៏ល្អបំផុតសម្រាប់តុលាការក្នុងស្រុក ។ ប្រសិនបើអំពើពុករលួយរបស់តុលាការបន្តកើតមានឡើងដោយគ្មានការផ្តន្ទាទោស នោះវាអាចនឹងបន្តធ្វើឲ្យការខិតខំប្រឹងប្រែងអភិវឌ្ឍច្បាប់ចុះខ្សោយបានដោយការធ្វើជាសារមួយដែលប្រាប់ថា អ.វ.ត.ក ទទួលយកអំពើពុករលួយ ។

ដោយសារតែអំពើពុករលួយរបស់តុលាការអាចនឹងរារាំងដល់ឯករាជ្យភាពរបស់តុលាការកាត់ទោសដោយសារមានការសម្របសម្រួលការជ្រើសតាំងរបស់តុលាការ និងការទាញយកប្រយោជន៍ពីរាជរដ្ឋាភិបាលដោយឥទ្ធិពលគ្មានដែនកំណត់លើដំណើរការនីតិវិធី និងអាចបរាជ័យក្នុងការបង្កើតជាឧទាហរណ៍អនុវត្តដ៏ល្អបំផុត នោះការខិតខំប្រឹងប្រែងគួរតែត្រូវបានបង្កើតឡើងដើម្បីដោះស្រាយនិងការពារអំពើពុករលួយរបស់តុលាការ ។ ខណៈពេលដែលឯកសារស្នូលរបស់អ.វ.ត.ក មិនបានចែងឲ្យមាននីតិវិធីដកហូតតំណែងចៅក្រមជាជាងនីតិវិធីតាមរយៈការដកហូតសិទ្ធិធ្វើជាចៅក្រម នោះភាគីទាំងអស់ដែលតែងតាំងចៅក្រមនេះអាចនឹងព្យាយាមដកហូតតំណែងរបស់ចៅក្រមទាំងនេះបាន ។

រដ្ឋធម្មនុញ្ញកម្ពុជាចែងថា ព្រះមហាក្សត្រត្រូវតែក្លាយជា «អ្នកធានានៃឯករាជ្យភាពរបស់តុលាការ» និងក្រោយពីសំណើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនោះ ព្រះមហាក្សត្រត្រូវតែឡាយព្រះហស្តលេខាលើការតែងតាំងការបញ្ជូននិងការដកហូតចៅក្រមចេញពីតំណែង ។ ប្រសិនបើដំណើរជ្រើសរើសរបស់តុលាការស្ថិតនៅក្នុងការរំលោភបំពានលើគោលការណ៍ជាមូលដ្ឋាន ឬប្រសិនបើចៅក្រមមិនមានឯករាជ្យភាពក្នុងការបំពេញមុខងារ នោះព្រះមហាក្សត្រត្រូវតែដកហូតតំណែងរបស់ចៅក្រមទាំងនោះ ។ ប្រទេសដែលផ្តល់ជំនួយអាចជំរុញឲ្យមានវិធានការបែបនេះបានដោយបដិសេធមិនផ្តល់ជំនួយ ឬដោយដាក់គំនាបជាសាធារណៈជាមួយនឹងការយកចិត្តទុកដាក់ពីមជ្ឈដ្ឋានជាតិនិងអន្តរជាតិចំពោះបញ្ហានោះ ។

បន្ថែមលើនេះ ប្រសិនបើអំពើពុករលួយរបស់តុលាការនឹងបន្តកើតមាននិងពុំទាន់មានភាពគ្រប់គ្រាន់ដើម្បីសម្របសម្រួលបញ្ហាឯករាជ្យភាពរបស់តុលាការ នោះដំណោះស្រាយរបស់តុលាការអាចនឹងតម្រូវឲ្យធ្វើឡើងដើម្បីរក្សានូវលក្ខណៈដើមនៃដំណើរការនីតិវិធី ។ តាមវិធានផ្ទៃក្នុង «វិធានការតុលាការ ឬវិធានការស៊ើបអង្កេតអាចនឹងធ្វើឲ្យបញ្ហានីតិវិធីទុកជាមោឃៈក្នុងករណីដែលបញ្ហានេះរំលោភលើសិទ្ធិរបស់ភាគីក្នុងការបង្កើតការអនុវត្តវិធាន ។ ប្រសិនបើអំពើពុករលួយរបស់តុលាការក្លាយជាបញ្ហាធ្ងន់ធ្ងរដែលនាំធ្វើឲ្យរារាំងដល់តុលាការកាត់ទោសប្រកបដោយឯករាជ្យភាព នោះចៅក្រមអាចនឹងត្រូវតម្រូវឲ្យលុបចោលដំណើរការនីតិវិធីសម្រាប់បញ្ហានីតិវិធីនេះ ។

គោលដៅរបស់ អ.វ.ត.ក គឺពោរពេញដោយមហិច្ឆតា មិនត្រឹមតែស្វែងរកនូវយុត្តិធម៌សម្រាប់ជនរងគ្រោះនិងប្រជាជនកម្ពុជាទាំងអស់ និងការពារមិនឲ្យមានអំពើប្រល័យពូជសាសន៍កើតឡើងម្តងទៀតប៉ុណ្ណោះទេ តែថែមទាំងជួយដល់ដំណើរការកែប្រែប្រព័ន្ធតុលាការនិងប្រព័ន្ធច្បាប់ក្នុងប្រទេសកម្ពុជាឲ្យកាន់តែរីកសុសសាយឡើងថែមទៀតផង ។ ប្រសិនបើអំពើពុករលួយរបស់បុគ្គលិកការិយាល័យរដ្ឋបាល ឬរបស់ចៅក្រមនៅ អ.វ.ត.ក ត្រូវបានអនុញ្ញាតឲ្យបន្តកើតមានឡើងដោយគ្មានការផ្តន្ទាទោសទេ នោះវានឹងធ្វើឲ្យមានភាពអន្តរាយដល់គោលដៅទាំងនេះ និងគំរាមគំហែងដល់ឯករាជ្យភាពនិងភាពមិនលម្អៀងរបស់តុលាការ ។ ការចោទប្រកាន់ពីអំពើពុករលួយបានធ្វើឲ្យជោគជ័យផ្នែកច្បាប់ដ៏សំខាន់របស់តុលាការមិនមានសារៈសំខាន់ឡើយ ហើយដើម្បីអនុញ្ញាតឲ្យជោគជ័យទាំងនេះបន្តទៅមុខ វាអាចនឹងនាំមកនូវផលអាក្រក់ដល់ប្រទេសកម្ពុជានិងប្រជាជនកម្ពុជាទៀតផង ។

**អេលីហ្សាបែត នៀលសែន**

# ការសម្រេចយកនូវការកាត់ទោសដ៏សមរម្យមួយសម្រាប់ ឌុច

កាំង ហ្កេកអ៊ាវ ហៅ (ឌុច) បានទទួលស្គាល់ថាគាត់នឹងទទួលខុសត្រូវចំពោះបទឧក្រិដ្ឋធ្វើទារុណកម្ម ការយកមនុស្សធ្វើជាទាសករ ការធ្វើទុក្ខបុកម្នេញ និងការសម្លាប់បំផុតពូជក្នុងអំឡុងពេលបំពេញតួនាទីជាប្រធានគុកទួលស្លែងដែលត្រូវគេស្គាល់ថាជាមន្ទីរស-២១ ។ ក្នុងអំឡុងរបបខ្មែរក្រហមចាប់ពីឆ្នាំ ១៩៧៥-១៩៧៩ ឌុច គឺជាប្រធានប៉ុស្តិប៉ូលិសសម្ងាត់ដែលមានឈ្មោះថា ស-២១ ជាសាខាពិសេសរបស់បក្សកុម្មុយនីសកម្ពុជា ។ មុនអំឡុងពេលនេះ ឌុច គឺជាប្រធានមន្ទីរ១៣ (ម-១៣) ដែលជាមន្ទីរសន្តិសុខស្ថិតនៅខេត្តកំពង់ស្ពឺ ។

មន្ទីរស-២១ មានទីតាំងស្ថិតនៅទីក្រុងភ្នំពេញ និងត្រូវបានដំណើរការដាច់ដោយឡែកតែមួយគត់នៅក្នុងបណ្តាញរបស់មជ្ឈមណ្ឌលសន្តិសុខខ្មែរក្រហមទូទាំងប្រទេសកម្ពុជា ។ នេះដោយសារតែមន្ទីរស-២១ គឺជាមន្ទីរតែមួយគត់ដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងគណៈកម្មាធិការមជ្ឈិម (រដ្ឋាភិបាលរបស់ខ្មែរក្រហម) និងត្រូវបានប្រើជាកន្លែងសម្រាប់ឃុំឃាំង និងសម្លាប់កម្មាភិបាលខ្មែរក្រហម ។

ក្នុងអំឡុងពេលបំពេញតួនាទីជាប្រធានមន្ទីរស-២១ ឌុច បានបែងចែកមន្ទីរសន្តិសុខនេះជាពីរអង្គភាព គឺៈ អង្គភាពការពារ និងអង្គភាពសួរចម្លើយ ។ ឌុច បានផ្ទេរការគ្រប់គ្រងនៃអង្គភាពការពារទៅឲ្យអ្នកនៅក្រោមបង្គាប់ម្នាក់ ហើយ ឌុច បានគ្រប់គ្រងការត្រួតត្រាក្នុងអង្គភាពសួរចម្លើយដោយខ្លួនឯងផ្ទាល់ ។ អង្គភាពសួរចម្លើយត្រូវបានបែងចែងជាបន្តទៀតទៅជាអង្គភាពឯកសារ អង្គភាពពិសេស និងក្រុមផ្សេងៗទៀតរួមមាន ក្រុមរូបថតមើលម៉ាស៊ីន ចម្អិនអាហារ និងក្រុមតក្កវិជ្ជា ។ ឌុច បានដំណើរការមន្ទីរស-២១ ទៅតាមលំដាប់ថ្នាក់ដោយធ្វើការអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមប្រព័ន្ធរាយការណ៍ដើម្បីធានាថា បញ្ជារបស់គាត់នឹងត្រូវបានអនុវត្តតាមទាំងស្រុង ។ ឌុច ត្រូវបានរៀបរាប់ដោយសាក្សីយ៉ាងតិចណាស់ម្នាក់ថាជាបុគ្គលដែលអ្នកគ្រប់គ្នាខ្លាច ។ ខណៈពេលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ឌុច អ្នកទោសនៅមន្ទីរស-២១ ត្រូវបានទទួលរងនូវភាពអត់ឃ្លាន ទារុណកម្មដែលមានលក្ខណៈពិសោធន៍បែបវេជ្ជសាស្ត្រ និងជាញឹកញាប់អ្នកទោសទាំងនេះស្ទើរតែនឹងត្រូវបានសម្លាប់ ។ ជាសរុប អ្នកទោសលើសពី ១២,៣៨០ នាក់ត្រូវបានសម្លាប់នៅមន្ទីរស-២១ ។

ឧក្រិដ្ឋកម្មដែលទទួលស្គាល់ដោយ ឌុច ក្នុងរបបខ្មែរក្រហមនឹងត្រូវបានស្វែងយល់ថា ជាឧក្រិដ្ឋកម្មរួមប្រឆាំងនឹងមនុស្សជាតិ និងរំលោភយ៉ាងធ្ងន់ធ្ងរលើសន្ធិសញ្ញាហ្សឺណែវឆ្នាំ១៩៤៩ ហេតុដូច្នេះ ការផ្តន្ទាទោសបទព្រហ្មទណ្ឌដែលប្រកបដោយយុត្តិធម៌នឹងត្រូវបានចេញសេចក្តីសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ខណៈពេលដែលកំពុងតែផ្តន្ទាទោស បទឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានកំណត់ឲ្យយកការកាត់ទោសជាប់ពន្ធនាគារតូចបំផុតប្រាំឆ្នាំ និងធំបំផុតអស់មួយជីវិត ។ គម្លាតដ៏ធំនៃការផ្តន្ទាទោសដែលអាចកើតមានឡើងនេះបានបង្កឲ្យមនុស្សជាច្រើនឆ្ងល់ថាតើតុលាការនឹងធ្វើយ៉ាងណាដើម្បីចេញសាលក្រមកាត់ទោសដ៏សមរម្យមួយសម្រាប់ ឌុច ។

សេចក្តីណែនាំសម្រាប់ការកាត់ទោសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់សំណួរផ្នែកច្បាប់ដែលត្រូវបានចោទសួរអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្គាប់ជាដំបូងឲ្យពិចារណាលើការអនុវត្តច្បាប់កម្ពុជា ហើយបន្ទាប់មកពឹងផ្អែកលើយុត្តាធិការអន្តរជាតិក្នុងករណីដែលប្រព័ន្ធច្បាប់កម្ពុជាមិនអាចផ្តល់ចម្លើយដល់សំណួរ ឬក្នុងករណីដែលការអនុវត្តច្បាប់កម្ពុជាមិនអាចតម្រូវតាមបទដ្ឋានអន្តរជាតិបាន ។ ទាក់ទិនជាមួយនឹងសេចក្តីណែនាំសម្រាប់ការកាត់ទោសព្រហ្មទណ្ឌវិញ ច្បាប់កម្ពុជាហាក់បីដូចជាមិនបានដោះស្រាយថាតើត្រូវសម្រេចយកការកាត់ទោសដ៏សមរម្យសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាហ្សឺណែវដោយរបៀបណាឡើយ ។ ដូច្នេះ វាហាក់បីដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងពឹងផ្អែកលើយុត្តាធិការអន្តរជាតិសម្រាប់

ការផ្តល់ចម្លើយទៅកាន់សំណួរទាំងនោះ ។

ការអនុវត្តច្បាប់កាត់ទោសអន្តរជាតិត្រូវបានវិវត្តន៍តាមរយៈសេចក្តីណែនាំដែលសរសេរឡើងដោយឥតលម្អៀង និងក្នុងករណីខ្លះតាមរយៈច្បាប់ករណីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗមួយចំនួនរួមមាន តុលាការខុក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការខុក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា តុលាការខុក្រិដ្ឋកម្មអន្តរជាតិ តុលាការពិសេសសម្រាប់សេរ៉ាឡេអន និងគណៈវិនិច្ឆ័យពិសេសសម្រាប់ខុក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើត ។

យោងតាមការអនុវត្តច្បាប់របស់តុលាការអន្តរជាតិទាំងនេះ តុលាការដែលធ្វើការកាត់ទោសលើខុក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរបានសម្រេចការកាត់ទោសព្រហ្មទណ្ឌដ៏សមរម្យដោយពិនិត្យពិចារណាពីភាពធ្ងន់ធ្ងរនៃខុក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង និងកាលៈទេសៈផ្ទាល់ខ្លួនរបស់ជនដែលត្រូវផ្តន្ទាទោសដែលកំពុងត្រូវបានកាត់ទោស ។

ការពិចារណាសំខាន់បំផុតសម្រាប់ការកាត់ទោសនោះគឺភាពធ្ងន់ធ្ងរនៃបទល្មើសដែលជនដែលត្រូវផ្តន្ទាទោសបានប្រព្រឹត្ត ។ ការវិភាគ្សាវែកញែកនេះ រួមបញ្ចូលការពិនិត្យពីប្រភពដើម និងកម្រិតនៃខុក្រិដ្ឋកម្មដែលចោទសួរយ៉ាងសំខាន់ថាៈ តើខុក្រិដ្ឋកម្មអ្វីខ្លះដែលត្រូវបានប្រព្រឹត្ត និងអ្វីខ្លះជាផលប៉ះពាល់នៃខុក្រិដ្ឋកម្មទាំងនោះ ។ តុលាការទាំងនេះក៏បានពិចារណាពីតួនាទីរបស់ជនដែលត្រូវផ្តន្ទាទោសបានបំពេញក្នុងការប្រព្រឹត្តខុក្រិដ្ឋកម្មទាំងនោះ ។ ក្រោយពីការពិចារណាពីភាពធ្ងន់ធ្ងរនៃបទល្មើស បន្ទាប់មកទៀតតុលាការនឹងសម្លឹងពិចារណាលើកាលៈទេសៈផ្ទាល់ជុំវិញជនដែលត្រូវផ្តន្ទាទោស ។ ជាទូទៅ កាលៈទេសៈទាំងអស់នេះ រួមមាន កត្តាសម្រាលនិងទម្ងន់ទោសណាដែលតុលាការគិតថាអាចនឹងធ្វើឲ្យទណ្ឌកម្មដែលមានកម្រិតកាន់តែធ្ងន់ឬស្រាលប្រកបដោយយុត្តិធម៌សម្រាប់អ្នកប្រព្រឹត្តខុស ។ ទោះបីជាតុលាការត្រូវបានផ្តល់នូវឆន្ទានុសិទ្ធិទៅតាមកត្តាដែលតុលាការធ្វើការពិចារណាក៏ដោយក៏សេចក្តីណែនាំសរសេរឡើងដោយឥតលម្អៀងដែលបានផ្តល់ឲ្យតុលាការខុក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការខុក្រិដ្ឋកម្មអន្តរជាតិរ៉្វាន់ដា តុលាការខុក្រិដ្ឋកម្មអន្តរជាតិ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និង គណៈវិនិច្ឆ័យពិសេសសម្រាប់ខុក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើតបានបង្ហាប់ឲ្យតុលាការទាំងនេះធ្វើការសម្រាលទោសសម្រាប់ខុក្រិដ្ឋកម្មដែលប្រព្រឹត្តតាមបញ្ជាថ្នាក់លើ និងសម្រាប់ជនត្រូវផ្តន្ទាទោសណាដែលបានសហការយ៉ាងជិតស្និទ្ធជាមួយនឹងតុលាការ ។ បន្ថែមលើនេះ តាមរយៈច្បាប់ករណីដែលបានវិវត្តន៍នៅក្នុងតុលាការទាំងអស់នេះ វាគឺជាការអនុវត្តច្បាប់ដ៏ទូទៅក្នុងការសម្រាលទោសសម្រាប់ជនណាដែលបានសម្តែងនូវវិប្បដិសារីចំពោះខុក្រិដ្ឋកម្មរបស់គេ ឬសម្រាប់ជនដែលទទួលខុសត្រូវចំពោះខុក្រិដ្ឋកម្មរបស់គេ ។ ខណៈពេលដែលពិចារណាពីកត្តាទម្ងន់ទោស ជារួមតុលាការទាំងនេះបានធ្វើឲ្យការដាក់ទណ្ឌកម្មដែលមានកម្រិតកាន់តែធ្ងន់ប្រកបដោយយុត្តិធម៌ក្នុងករណីដែលខុក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តលើជនរងគ្រោះជាក់លាក់ណាមួយ ដែលងាយនឹងរងគ្រោះនិងក្នុងករណីដែលខុក្រិដ្ឋកម្មនោះមានជាប់ពាក់ព័ន្ធនឹងភាពយង់ឃ្នងប៉ះពាល់ដល់ជនរងគ្រោះច្រើនឬខុក្រិដ្ឋកម្មដែលជំរុញឲ្យធ្វើឡើងដោយភាពរើសអើង ។

## សេចក្តីណែនាំសម្រាប់ការកាត់ទោសព្រហ្មទណ្ឌដែលបានដាក់ជូនសម្រាប់តុលាការកាត់ទោស ឌុច

ដូចដែលបានលើកឡើងពីមុន ជាដំបូង តុលាការអន្តរជាតិនឹងពិចារណាលើភាពធ្ងន់ធ្ងរនៃបទល្មើសដែលរួមមាន ប្រភពដើមកម្រិតនៃខុក្រិដ្ឋកម្មនិងតួនាទីរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តខុក្រិដ្ឋកម្មទាំងនោះ ។ ខណៈពេលដែលកំពុងប៉ាន់ស្មានមើលពីប្រភពដើមនិងកម្រិតនៃខុក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះ តុលាការទាំងនេះបានស្វែងយល់ឃើញ ថាខុក្រិដ្ឋកម្មធ្វើទារុណកម្មសម្លាប់ និងការធ្វើទុក្ខបុកម្នេញពិតជាពោរពេញដោយភាពសាហាវយង់ឃ្នង និងមានតម្លៃសម្រាប់ទណ្ឌកម្មដែលមានកម្រិតកាន់តែធ្ងន់ៗ សម្រាប់ករណីរបស់ ឌុច វាហាក់បីដូចជាខុក្រិដ្ឋកម្មដែលប្រព្រឹត្តទាំងនោះកើតចេញពីប្រភពដើមនៃភាពសាហាវយង់ឃ្នងបំផុត និងបានធ្វើឲ្យមានផលប៉ះពាល់ដល់ប្រជាជនដប់ពាន់នាក់ ។ ឌុច បានប្រកាសទទួលខុសត្រូវសម្រាប់ខុក្រិដ្ឋកម្មធ្វើទារុណកម្មការសម្លាប់បំផុតពូជ ការធ្វើទុក្ខបុកម្នេញ និងការយកមនុស្សធ្វើជាទាសករក្នុងអំឡុងពេលដែលខ្លួនបំពេញតួនាទីជាប្រធានមន្ទីរ

ស-២១ ។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តលើអ្នកជាប់ឃុំយ៉ាងហោចណាស់១២,៣៨០នាក់ យ៉ាងណាមិញ ចំនួននេះអាចនឹងខ្ពស់ជាងនេះពីព្រោះថា សាក្សីជាច្រើនបានផ្តល់សក្ខីកម្មថា កូនៗរបស់គេជាញឹកញាប់ត្រូវបានសម្លាប់ក្រោយពីការទៅដល់មន្ទីរស-២១ មុននឹងត្រូវបានកត់ត្រាទុកជាឯកសារ ។ ផលប៉ះពាល់នៃឧក្រិដ្ឋកម្មរបស់ ឌុច អាចកើតឡើងលើសពីចំនួនមនុស្សដែលត្រូវបានធ្វើទារុណកម្មនិងសម្លាប់នៅមន្ទីរស-២១ ឬនៅជើងឯកជាវាលពិឃាតរបស់មន្ទីរស-២១ ទៅទៀត ដោយវាបានប៉ះពាល់ដល់សមាជិកគ្រួសារ និងមិត្តភក្តិរបស់អ្នកទោសទាំងនោះដែលទទួលរងនូវភាពឈឺចាប់ក្នុងការបាត់បង់សមាជិកជាទីស្រឡាញ់របស់គេនិងទទួលរងនូវភាពភ័យខ្លាចដែលថាពួកគេក៏អាចនឹងចាប់ខ្លួនធ្វើទារុណកម្មនិងសម្លាប់ដែរ ។ សម្រាប់តួនាទីរបស់ ឌុច ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលគាត់បានទទួលស្គាល់នោះ ក្នុងនាមជាប្រធានមន្ទីរស-២១ ឌុច មានអំណាចយ៉ាងដាច់ខាតលើបុគ្គលិក និងអ្នកជាប់ឃុំនៅមន្ទីរស-២១ ។ តាមពិតសាក្សីជាច្រើនបានផ្តល់សក្ខីកម្មថាអ្វីទាំងអស់ដែលកើតមានឡើងនៅមន្ទីរស-២១ សុទ្ធតែអនុវត្តទៅតាមបញ្ជារបស់ ឌុច ។ ដូច្នេះ វាហាក់បីដូចជា ឌុច បានបំពេញតួនាទីដ៏សំខាន់ដែលអាចជាផ្នែកដ៏ធំមួយក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មសាហាវយង់ឃ្នងដែលប្រព្រឹត្តឡើងនៅមន្ទីរស-២១ និងនៅជើងឯក ។

អាស្រ័យលើតួនាទីដ៏សំខាន់ដែល ឌុច បានបំពេញក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ក៏ដូចជាប្រភពដើមដ៏សាហាវយង់ឃ្នងនៃឧក្រិដ្ឋកម្មរបស់គាត់ និងផលប៉ះពាល់យ៉ាងធំទូលាយនៃឧក្រិដ្ឋកម្មទាំងនេះ វាហាក់បីដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចនឹងពិចារណាឃើញថា វាពិតជាសមរម្យក្នុងការបង្គាប់ឲ្យមានទណ្ឌកម្មកម្រិតធ្ងន់ក្នុងការជាប់ពន្ធនាគារអស់មួយជីវិត ។ យ៉ាងណាមិញ មុននឹងចេញសាលក្រមកាត់ទោសចុងក្រោយបង្អស់នេះ តុលាការអាចនឹងពិចារណាមើលកត្តាផ្សេងៗទៀតដែលអាចបង្ហាញពីតម្រូវការចាំបាច់សម្រាប់ទណ្ឌកម្មដែលមានកម្រិតកាន់តែធ្ងន់និងស្រាលដោយអាស្រ័យលើកាលៈទេសៈផ្ទាល់របស់ ឌុច និងឧក្រិដ្ឋកម្មរបស់គាត់ ។

ខណៈពេលដែលកំពុងពិនិត្យពីកាលៈទេសៈផ្ទាល់ជុំវិញឧក្រិដ្ឋកម្មរបស់ ឌុច នោះវាពិតជាមានសារៈសំខាន់ក្នុងការកត់សម្គាល់ជាដំបូងថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិពេញលេញដើម្បីសម្រេចថាតើកត្តាណាមួយនឹងត្រូវយកមកពិចារណា និងថាតើជំនឿទុកចិត្តប៉ុន្មាននឹងត្រូវផ្តល់ទៅឲ្យកត្តាទាំងនោះ ។

បើពិចារណាពីកត្តាដែលអាចបង្ហាញនូវតម្រូវការសម្រាប់ទណ្ឌកម្មដែលមានកម្រិតកាន់តែធ្ងន់ នោះវាហាក់បីដូចជាថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងដាក់ទម្ងន់ក្នុងការកាត់ទោសដោយយោងតាមការស្រាវជ្រាវដែលសិក្សាឃើញថា ឧក្រិដ្ឋកម្មរបស់ ឌុច បានប្រព្រឹត្តលើមនុស្សដែលងាយនឹងរងគ្រោះមួយចំនួនដ៏ជាក់លាក់ និងដោយអាស្រ័យលើការពិតដែលថា ឌុច មានតួនាទីជាអ្នកដឹកនាំម្នាក់លើក្រុមមនុស្សដែលជួយប្រព្រឹត្តឧក្រិដ្ឋកម្មធ្វើទារុណកម្ម ការយកមនុស្សធ្វើជាទាសករ និងការសម្លាប់ ។

ជាទូទៅ តុលាការអន្តរជាតិបានស្វែងយល់ឃើញថា ខណៈពេលដែលជនដែលត្រូវផ្តន្ទាទោសមានតួនាទីកាន់អំណាចតាមក្របខ័ណ្ឌមួយដោយគ្រប់គ្រងលើមនុស្សមួយក្រុមដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជារួមនោះ វាពិតជាទាមទារឲ្យធ្វើការពិចារណាលើកត្តាដាក់ទម្ងន់ទោសដែលមានភាពចាំបាច់សម្រាប់ទណ្ឌកម្មមួយធ្ងន់ធ្ងរជាងនេះ ។ សម្រាប់ករណីរបស់ ឌុច ជនជាប់ចោទរូបនេះ គឺជាប្រធានមន្ទីរស-២១ និងបានរាយការណ៍ដោយផ្ទាល់ទៅកាន់គណៈកម្មាធិការមជ្ឈិម ។ លើសពីនេះ ឌុច បានទទួលស្គាល់ក្នុងតុលាការថា គាត់មានតួនាទីកាន់អំណាចមួយដោយគ្រប់គ្រងបុគ្គលិកនៅមន្ទីរស-២១ ដែលអ្នកទាំងនេះភាគច្រើនបានប្រព្រឹត្តការធ្វើទារុណកម្ម និងការសម្លាប់ ។ ចុងក្រោយបង្អស់ ដោយសារតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានតែយុត្តាធិការសម្រាប់មេដឹកនាំជាន់ខ្ពស់ និងអ្នកទាំងឡាយណាដែលមានទំនួលខុសត្រូវខ្ពស់សម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ តាមនិយមន័យ ឌុច ត្រូវបានសម្រេចដោយតុលាការថាមានតួនាទីដ៏សំខាន់មួយ ។ អាស្រ័យលើភស្តុតាងទាំងនេះ វាហាក់បីដូចជាអង្គជំនុំជម្រះសាលាដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចនឹងចង់ពិចារណាពីការដាក់ទណ្ឌកម្មដែលមាន

កម្រិតកាន់តែធ្ងន់សម្រាប់ ឌុច ។

ជាមួយគ្នានេះផងដែរ តុលាការអន្តរជាតិជាទូទៅបានប្រកាន់នូវគោលជំហរថា ការកាត់ទោសនឹងត្រូវដាក់ទម្ងន់ដោយយោងទៅតាមការស្រាវជ្រាវពីជនរងគ្រោះនៃបទល្មើសរួមមានជាពិសេស មនុស្សដែលងាយនឹងទទួលរងគ្រោះមួយចំនួនធំដូចជាស្ត្រី កុមារ មនុស្សចាស់ ឬអ្នកទោសនៅក្នុងគុក ។ ខណៈពេលដែលពិចារណាពីជនរងគ្រោះនៃឧក្រិដ្ឋកម្មរបស់ ឌុច វាហាក់បីដូចជា ជនរងគ្រោះទាំងនេះក៏អាចនឹងស្គាល់ថាជាមនុស្សដែលងាយនឹងទទួលរងគ្រោះក្នុងពេលដែលឧក្រិដ្ឋកម្មនោះត្រូវបានវិនិច្ឆ័យប្រឆាំងលើបទដ្ឋានអន្តរជាតិទាំងនេះ ។ តាមពិត ជនរងគ្រោះរបស់ ឌុច ដែលរួមមានជនស៊ីវិលបុរស ស្ត្រី និង កុមារ ត្រូវបានឃុំឃាំងនៅមន្ទីរស-២១ ក្រោមការគ្រប់គ្រងរបស់ ឌុច ។ ដូច្នេះ វាហាក់បីដូចជា តុលាការអាចនឹងស្វែងយល់ពីឋានៈរបស់ជនរងគ្រោះដើម្បីធ្វើឲ្យការដាក់ទណ្ឌកម្មដែលមានកម្រិតកាន់តែធ្ងន់មួយនេះប្រកបដោយយុត្តិធម៌ ។

ដោយហេតុថា ឌុច បានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតខ្លះដែលអាចប្រមើលឃើញ និងដោយហេតុដែលថានឹងមានកត្តាដាក់ទម្ងន់ទោសដែលអាចធ្វើឲ្យការដាក់ទណ្ឌកម្មដែលមានកម្រិតកាន់តែធ្ងន់នោះ ក៏កត្តាសម្រាលទោសអាចកើតមានបានបង្ហាញឲ្យឃើញថា វាពិតជាសមរម្យសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់នូវការបន្ធូរបន្ថយទោសក្នុងការកាត់ទោស ឌុច ឲ្យស្ថិតនៅក្រោមការកាត់ទោសកម្រិតធ្ងន់បំផុតគឺជាប់ពន្ធនាគារអស់មួយជីវិត ។

យោងតាមយុត្តាធិការអន្តរជាតិ ការកាត់ទោស ឌុច អាចនឹងត្រូវសម្រាលទោសបាន ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្វែងយល់ឃើញថា ឌុច បានសម្តែងនូវសកម្មភាពមួយ ឬលើសពីនេះដែលមានចែងដូចខាងក្រោមៈ

១) សហការយ៉ាងជិតស្និទ្ធជាមួយនឹងតុលាការ

២) ប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ខ្លួនតាមបញ្ជារបស់ថ្នាក់លើណាម្នាក់

៣) ទទួលស្គាល់កំហុស និងទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មរបស់ខ្លួន

៤) សម្តែងនូវវិប្បដិសារីដ៏ពិតប្រាកដសម្រាប់ឧក្រិដ្ឋកម្មទាំងនោះ ។

វាពិតជាសំខាន់ក្នុងការកត់សម្គាល់ថា ដើម្បីសម្តែងនូវអ្វីដែលមានចែងក្នុងកត្តាខាងលើក្នុងតុលាការបាន ឌុច ត្រូវតែបង្ហាញឲ្យឃើញថា ការសម្តែងនេះអាចមើលឃើញថាលើសពីភាពមិនពិត (ជាអ្វីដែលពិត) ។

យុត្តាធិការអន្តរជាតិបានជឿជាក់ថា កិច្ចសហការអាចក្លាយជាកត្តាសម្រាលទោសបានលុះត្រាតែការសហការនេះត្រូវបានធ្វើឡើងជារៀងរហូត ។ ដើម្បីវិនិច្ឆ័យថាតើកិច្ចសហការអាចជួបប្រទះនឹងឧបសគ្គបែបនេះដែរឬទេនោះតុលាការត្រូវតែពិចារណាពីកម្រិតនិងគុណភាពព័ត៌មានដែលបានផ្តល់ឲ្យតុលាការតាមរយៈជនដែលត្រូវផ្តន្ទាទោស ។ បន្ថែមលើនេះ តុលាការខ្លះបានសិក្សាឃើញថា ឥរិយាបថរបស់ជនដែលត្រូវផ្តន្ទាទោសខណៈពេលនៅក្នុងតុលាការក៏អាចនឹងត្រូវយកមកប្រើប្រាស់ដើម្បីសម្រេចថាតើជនទាំងនោះបាន «សហការ» ដែរឬទេ ។ សម្រាប់ករណីរបស់ ឌុច ភស្តុតាងទាំងអស់ហាក់បីដូចជាបានបង្ហាញថា ជនជាប់ចោទរូបនេះបានសហការ និងគោរពតុលាការរហូត ។ ឧទាហរណ៍ ក្នុងថ្ងៃទីពីរនៃតុលាការកាត់ទោសរបស់គាត់ ឌុច បានសម្តែងនូវឆន្ទៈក្នុងការឆ្លើយសំណួរទាំងអស់ដែលត្រូវបានសួរដោយតុលាការនិងភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ ក្នុងពេលនោះ វាហាក់បីដូចជា ឌុច បានរក្សាពាក្យសន្យានេះដោយផ្តល់ព័ត៌មានលម្អិតនៃឧក្រិដ្ឋកម្មរបស់ខ្លួន ឧក្រិដ្ឋកម្មទូទៅរបស់ខ្មែរក្រហមនឹងបកស្រាយពីរចនាសម្ព័ន្ធនយោបាយ និងប្រតិបត្តិការរបស់គណៈកម្មាធិការមជ្ឈិមជាដើម ។ តាមពិត ចៅក្រមស៊ើបអង្កេតហាក់បីដូចជាបានស្វែងយល់ឃើញថា ឌុច បានសហការតាំងពីមុនមានតុលាការ ចាប់តាំងពីដំណាក់កាលដំណោះស្រាយចោទជនជាប់ចោទថា «ឌុច បានសហការយ៉ាងជិតស្និទ្ធក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការ ។

កត្តាទីពីរដែលអាចឲ្យអង្គជំនុំជម្រះវិសាមញ្ញរបស់តុលាការកម្ពុជាសម្រាលការកាត់ទោសរបស់ ឌុច បានគឺដោយសារថា ឌុច បានប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ខ្លួនតាមបញ្ជារបស់រដ្ឋាភិបាល ។

យោងតាមវិធានរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការឧក្រិដ្ឋកម្មអន្តរជាតិរបស់ រ៉្វាន់ដា និងតុលាការពិសេសប្រទេសសេរ៉ាឡេអូន ឧក្រិដ្ឋកម្ម «ដែលធ្វើតាមបញ្ជារបស់រដ្ឋាភិបាល ឬថ្នាក់លើមិនអាចសម្រាលការទទួលខុសត្រូវខាងព្រហ្មទណ្ឌឡើយ ប៉ុន្តែអាចត្រូវបានចាត់ទុកថាជាការសម្រាលទណ្ឌកម្ម ប្រសិនបើតុលាការអន្តរជាតិសម្រេចយកយុត្តិធម៌ទៅតាមការទាមទារដូច្នោះ ។ សម្រាប់ករណីរបស់ ឌុច ខណៈពេលដែលជនជាប់ចោទរូបនេះហាក់បីដូចជាបានបំពេញតួនាទីយ៉ាងសកម្មក្នុងការអភិវឌ្ឍនិងអនុវត្តនយោបាយខ្មែរក្រហម វាក៏អាចថា ឌុច បានអនុវត្តបញ្ជាដែលខ្លួនបានទទួលពីថ្នាក់លើដែរ ។ ដីកាដំណោះស្រាយដែលចោទ ឌុច ហាក់បីដូចជាបង្ហាញថា ឌុច បានគាំទ្រសេចក្តីអះអាងនេះដែលរៀបរាប់ថា ឌុច បានធ្វើតាមបញ្ជារបស់ សុន សេន និងគណៈកម្មាធិការមជ្ឈិម ។ ខណៈពេលផ្តល់សក្ខីកម្ម ឌុច បានជំទាស់ម្តងហើយម្តងទៀតដោយនិយាយថា គាត់ប្រព្រឹត្តឧក្រិដ្ឋកម្ម ដោយសារតែគាត់ខ្លាចស្លាប់ប្រសិនបើគាត់មិនធ្វើតាមបញ្ជាថ្នាក់លើរបស់គាត់ទេនោះ ។ ផ្ទុយពីនេះ សាក្សីខ្លះបានជំទាស់ថា ឌុច ត្រូវបានទទួលបញ្ជាស្រាលពីគណៈកម្មាធិការមជ្ឈិម ប៉ុន្តែ ឌុច បានអនុវត្តហួសទៅតាមការទាមទារនៃបញ្ជារបស់ខ្លួន ពីព្រោះថា ឌុច បានបង្កើត និងអនុវត្តនយោបាយធ្វើទារុណកម្មនិងសម្លាប់ក្រុមមនុស្សនៅមន្ទីរស-២១ ។ យ៉ាងណាមិញ វាក៏អាចអះអាងបានដែលថា តុលាការនឹងស្វែងយល់ថាវាពិតជាមានសារៈសំខាន់ក្នុងការផ្តល់ការសម្រាលទោសខ្លះៗសម្រាប់ទណ្ឌកម្មចំពោះ ឌុច ដើម្បីជាការទទួលស្គាល់ការពិតថា ឌុច បានធ្វើតាមបញ្ជាគេមែន ។

កត្តាទីបីដែលតុលាការនឹងអាចពិចារណានោះ គឺថាតើការទទួលស្គាល់កំហុសរបស់ ឌុច អាចបំពេញទៅតាមគោលដៅសម្រាលទោសបានដែរឬទេ ។ ដើម្បីពិចារណាពីកត្តាសម្រាលទោសនេះ ជាដំបូងអង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាថាតើការទទួលស្គាល់កំហុសរបស់ ឌុច «មិនអាចបំពេញតាមលក្ខខណ្ឌបានឬយ៉ាងណា ។ ដោយសារតែ ឌុច ត្រូវបានទទួលស្គាល់ដោយចៅក្រមស៊ើបអង្កេតថាបានទទួលស្គាល់កំហុសនោះ វាហាក់បីដូចថាជនជាប់ចោទរូបនេះអាចមិនមានភាពច្បាស់លាស់ពីការទទួលស្គាល់កំហុសរបស់ខ្លួនដោយបែរទៅទម្លាក់កំហុសទាំងអស់ដល់ថ្នាក់លើរបស់ខ្លួនទាំងស្រុងពេញលេញទៅវិញ ។ នៅក្នុងការថ្លែងសុំទោសរបស់ខ្លួនដែលធ្វើឡើងនៅថ្ងៃទីពីរក្នុងតុលាការកាត់ទោសរបស់ខ្លួន ឌុច បានពន្យល់មូលហេតុដែលធ្វើឲ្យគាត់មានកំហុសសម្រាប់ឧក្រិដ្ឋកម្មនៅមន្ទីរស-២១ ប៉ុន្តែ ឌុច ក៏បាននិយាយផងដែរថា «ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ បក្សកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកយ៉ាងធំធេងសម្រាប់ឧក្រិដ្ឋកម្មក្នុងប្រទេសកម្ពុជា» ។

បន្ថែមពីលើនេះ ទោះបីជា ឌុច បានទទួលស្គាល់កំហុសយ៉ាងពេញលេញសម្រាប់ឧក្រិដ្ឋកម្មរបស់ខ្លួនក៏ដោយ ក៏គោលដៅសម្រាប់ការសម្រាលការកាត់ទោសព្រហ្មទណ្ឌសម្រាប់ជនជាប់ចោទដែលទទួលស្គាល់កំហុសអាចនឹងមានអវត្តមាននៅក្នុងករណីមួយនេះ ។ តុលាការហាក់បីដូចជាមានបំណងបន្ធូរបន្ថយការកាត់ទោសសម្រាប់កំហុសដែលទទួលស្គាល់នោះ ដោយសារតែវាអាចជួយកាត់បន្ថយឧបសគ្គទាក់ទិននឹងបញ្ហាភ័ស្តុតាងសម្រាប់ការកាត់ទោសនិងជួយបង្កើតឲ្យមានតុលាការដែលមានដំណើរការលឿននិងប្រកបដោយប្រសិទ្ធភាព ។ ប៉ុន្តែសម្រាប់ករណីនេះវិញ ឌុច បាននិយាយយ៉ាងច្បាស់លាស់ថា ឌុច នឹងមិនទទួលស្គាល់កំហុសណាមួយដែលការកាត់ទោសមិនបានបង្ហាញភ័ស្តុតាងឲ្យឃើញច្បាស់នៅក្នុងតុលាការ ។ ដូច្នេះ មូលហេតុសំខាន់សម្រាប់ការសម្រាលទោសនឹងមិនមានវត្តមានក្នុងករណីនេះឡើយ ទោះបីជា ឌុច បានឬមិនបានទទួលស្គាល់កំហុសដោយពេញលេញសម្រាប់ឧក្រិដ្ឋកម្មដែលតុលាការកាត់ទោសអាចបង្ហាញភ័ស្តុតាងឲ្យឃើញច្បាស់ក៏ដោយ ។

កត្តាចុងក្រោយដែលតុលាការនឹងអាចពិចារណា គឺការសម្តែងនូវវិប្បដិសារីដែល ឌុច បានធ្វើឡើងក្នុងថ្ងៃទីពីរ នៅតុលាការកាត់ទោសរបស់ខ្លួន ។ ច្បាប់អន្តរជាតិបានទទួលស្គាល់ថាវិប្បដិសារីអាចក្លាយកត្តាសម្រាលការកាត់ទោសព្រហ្មទណ្ឌបានលុះត្រាតែវិប្បដិសារីនោះមានភាព «ស្មោះត្រង់» ។ ការវិភាគក្បាវែកញែកពីភាពស្មោះត្រង់នៃសេចក្តីថ្លែងការណ៍ពីវិប្បដិសារីរបស់ជនជាប់ចោទ តុលាការបានប្រើប្រាស់បទដ្ឋានសត្យានុម័តដែលសម្ងឹងពិចារណាមើលលើការរៀបរាប់និងអាកប្បកិរិយារបស់ជនជាប់

ចោទដូចជា ការចុះចាញ់ដោយស្ម័គ្រចិត្ត ឬការព្រមទទួលស្គាល់កំហុសជាដើម ។ សម្រាប់ករណីរបស់ ឌុច ការរៀបរាប់របស់ ឌុច តែមួយមុខអាចនឹងឆ្លងផុតការសាកល្បងប្រកបដោយសត្យានុម័តពីភាពស្មោះត្រង់នេះបាន ប៉ុន្តែខ្រិដ្ឋកម្មរបស់ ឌុច ហាក់បីដូចជាចង្អុលបង្ហាញផ្សេងពីនេះ ។ ជនជាប់ចោទរូបនេះបានព្យាយាមបង្ហាញពីវិប្បដិសារីដ៏ស្មោះត្រង់របស់ខ្លួននៅពេលដែលខ្លួនបាននិយាយសុំទោសកាលពីថ្ងៃអង្គារ ទី៣១ ខែមីនា ឆ្នាំ២០០៩ ជាថ្ងៃទីពីរនៃអង្គសវនាការនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ។ ខណៈពេលនោះ ឌុច បានសម្តែងនូវ «ភាពសោកស្តាយ និងទុក្ខសោកដ៏ជ្រាលជ្រៅនិងការបាត់បង់ទាំងអស់ដោយសារតែខ្រិដ្ឋកម្មដែលបានប្រព្រឹត្ត ដោយ «បក្សកុម្មុយនីស្តកម្ពុជា» ចាប់ពីឆ្នាំ ១៩៧៥ - ១៩៧៩» ហេតុដូច្នេះហើយ គាត់ពិតជា «សោកស្តាយនិងមានវិប្បដិសារីយ៉ាងខ្លាំង» ។ ឌុច បានបន្តនិយាយទៀតថាគាត់បានបួងសួងសូមការអត់ឱនទោសរហូតទាំងពីគ្រួសារជនរងគ្រោះ និងពីជនរងគ្រោះផ្ទាល់ ។ ជាមួយគ្នានេះដែរ ឌុច ក៏បាននិយាយថាគាត់មិនដែលចង់ប្រព្រឹត្តខ្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្តនេះទេ ប៉ុន្តែត្រូវបានបង្ខំដោយពួកខ្មែរក្រហមដោយសារតែភាពភ័យខ្លាចនឹងសេចក្តីស្លាប់ផ្ទាល់ខ្លួន ។

យ៉ាងណាមិញ វាពិតជាមានសារៈសំខាន់ក្នុងការចងចាំថា ឌុច គ្រាន់តែនិយាយពាក្យទាំងនេះ ក្រោយពេលដែលត្រូវបានចោទប្រកាន់ដោយអចេតនា និងនាំមកកាត់ទោសសម្រាប់ខ្រិដ្ឋកម្មរបស់ខ្លួនតែប៉ុណ្ណោះ ។ ក្រោយពេលវៀតណាមបានចូលដល់ភ្នំពេញ ឌុច មានឱកាសលាលែងពីតំណែងក្នុងរបបខ្មែរក្រហម ។ យ៉ាងណាមិញ ឌុច បានជ្រើសរើសការភៀសខ្លួនជាមួយ នឹងពួកខ្មែរក្រហមដោយស្ម័គ្រចិត្តទៅវិញ ហើយបានលាក់ខ្លួនក្រោមឈ្មោះក្លែងក្លាយមួយ ។ ដូច្នេះទោះបីជាបាននិយាយរៀបរាប់នៅក្នុងតុលាការដែលឆ្លុះបង្ហាញថា ឌុច បានប្រឆាំងនឹងនយោបាយរបស់ខ្មែរក្រហមក៏ដោយ ក៏ ឌុច បានរស់នៅជាមួយខ្មែរក្រហមជាងដប់ឆ្នាំ ក្រោយពីមានឱកាសលាលែងពីតំណែងរបស់គាត់ក៏ដោយ ។

ដោយសារតែការសម្តែងនូវវិប្បដិសារីរបស់ ឌុច ហាក់បីដូចជាមិនស៊ីសង្វាក់គ្នាជាមួយនឹងការប្រព្រឹត្តរបស់គាត់កាលពីមុន និងដោយសារតែវិប្បដិសារីនេះមិនបានធ្វើឡើងរហូតដល់ពេលដែលគាត់ត្រូវបានចាប់ខ្លួនដោយអចេតនានិងនាំមកកាត់ទោសនោះវិប្បដិសារីរបស់ ឌុច អាចនឹងមិនចាត់ទុកថាស្មោះត្រង់ពេញលេញឡើយ ។ ដូច្នេះ វាពិតជាមិនសមហេតុផលទេសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការរួមបញ្ចូលវិប្បដិសារីជាកត្តាសម្រាលទោស ។

ខណៈពេលដែលកំពុងតែពិចារណាថាតើការកាត់ទោសដ៏ពេញលេញត្រឹមត្រូវនឹងមានសភាពបែបណានោះ វាពិតជាមានសារៈសំខាន់ក្នុងការចងចាំថា ជនជាប់ចោទរូបនេះត្រូវបាននាំមកកាត់ទោសសម្រាប់ខ្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងបំផុតដែលមនុស្សធម្មតាទូទៅមិនមានសមត្ថភាពធ្វើបាន ។ លើសពីនេះ តម្រូវការសម្រាប់ការកាត់ទោសព្រហ្មទណ្ឌហាក់បីដូចជាដាក់ទម្ងន់ទោសដោយសារតែ ឌុច បានបំពេញតួនាទីដ៏សំខាន់ក្នុងការប្រព្រឹត្តខ្រិដ្ឋកម្មដែល ឌុច ត្រូវបាននាំមកកាត់ទោសនេះ និងដោយសារតែខ្រិដ្ឋកម្មរបស់ ឌុច ត្រូវបានប្រព្រឹត្តទៅលើយ៉ាងហោចណាស់ជនរងគ្រោះខ្លះដែលប្រហែលជាជនងាយនឹងរងគ្រោះជាពិសេស ។ យ៉ាងណាមិញ ក៏មានកត្តាសម្រាលទោសសំខាន់ៗខ្លះៗទៀតដែលមាននៅក្នុងករណីរបស់ ឌុច ដែលអាចឆ្លុះបង្ហាញពីតម្រូវការសម្រាប់ទណ្ឌកម្មដែលមានកម្រិតស្ថិតនៅក្រោមការជាប់ពន្ធនាគារអស់មួយជីវិតដែរ ។ ដូចដែលបានពិភាក្សារួចហើយនោះ ការប្រព្រឹត្តរបស់ ឌុច ជាច្រើនត្រូវបានធ្វើឡើងក្រោមបញ្ជារបស់រដ្ឋាភិបាលដែលទទួលបញ្ជាពីគណៈកម្មាធិការមជ្ឈិម ។ បន្ថែមលើនេះ ឌុច ក៏បានសហការយ៉ាងជិតស្និទ្ធជាមួយនឹងតុលាការកាត់ទោសដែលនាំឲ្យមានតុលាការកាត់ទោសមួយដែលមានល្បឿនលឿននិងជួយផ្តល់ភ័ស្តុតាងបន្ថែមដែលអាចបង្ហាញថាមានប្រយោជន៍ដើម្បីប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដូច្នេះ វាហាក់បីដូចជាសមហេតុផលសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញសាលាក្រមកាត់ទោសដែលជិតដល់ទណ្ឌកម្មកម្រិតខ្ពស់បំផុតដោយជាប់ពន្ធនាគារអស់មួយជីវិតប៉ុន្តែអាចតិចជាងនេះបន្តិច ។

**ឆាល វេគសាន់**

# វិធីទៅរកការផ្សះផ្សានៅកម្ពុជា

កាលពីសាមសិបឆ្នាំមុន ប្រជាជនកម្ពុជាបានទទួលរងនូវព្រឹត្តិការណ៍ដ៏អាក្រក់មួយអស់រយៈពេលប្រហែល៤៥ខែ ។ ខ្មែរក្រហមបានចាត់ចែងឲ្យកើតមានព្រឹត្តិការណ៍នេះឡើង ។ នៅក្នុងអំឡុងពេលនៃភាពអន្ធកាលនិងគួរឲ្យតក់ស្លុតនេះ ប្រជាជនជាងបីលាននាក់ត្រូវបានបាត់បង់ជីវិត ។ សព្វថ្ងៃនេះមានការប្រឹងប្រែងព្យាយាមយ៉ាងច្រើនត្រូវបានធ្វើឡើងដើម្បីស្វែងរកយុត្តិធម៌និងការផ្សះផ្សាដល់ប្រជាជនខ្មែរដែលបានឆ្លងកាត់អំពើប្រល័យពូជសាសន៍ ។ ខ្ញុំយល់ថា វិធីសាស្ត្រមួយចំនួនដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើឡើងរួមមានការកាត់ទោសបទឧក្រិដ្ឋកម្ម វិធីរំឭកនិងកម្មវិធីសំណងនឹងផ្តល់ឲ្យជាផ្លូវដ៏ជោគជ័យបំផុតឆ្ពោះទៅរកការផ្សះផ្សាជាតិ ។ លើសពីនេះទៅទៀត ដើម្បីឲ្យប្រទេសមួយអាចជាសះស្បើយពីសង្គ្រាមនិងដើរទៅមុខតទៅទៀត លុះត្រាតែប្រជាជនរបស់ប្រទេសនោះជាសះស្បើយពីរបួសផ្លូវចិត្តជាមុនសិន ។ ហេតុនេះហើយ បន្ថែមពីលើវិធីសាស្ត្រអន្តរកាលដែលបានរៀបរាប់ខាងលើ ខ្ញុំជឿជាក់ថា សាសនាក៏ដើរតួសំខាន់ខ្លាំងណាស់ដែរដើម្បីជួយឲ្យបុគ្គលនីមួយៗអាចព្យាបាលរបួសផ្លូវចិត្តខ្លួន ហើយនិងជំរុញឲ្យមានការផ្សះផ្សាកាន់តែទូលំទូលាយថែមទៀត ។

## យុត្តិធម៌មានលក្ខណៈផ្តន្ទាទោសនិងយុត្តិធម៌មានលក្ខណៈស្តារឡើងវិញ

យុត្តិធម៌អន្តរកាលអាចបែងចែកជាទស្សនៈចម្បងពីរ គឺយុត្តិធម៌ដែលមានលក្ខណៈផ្តន្ទាទោសនិងយុត្តិធម៌ដែលមានលក្ខណៈស្តារឡើងវិញ ។ យុត្តិធម៌ដែលមានលក្ខណៈផ្តន្ទាទោសសង្កត់ធ្ងន់ទៅលើការកាត់ទោសបទឧក្រិដ្ឋនិងការដាក់ទណ្ឌកម្ម ។ តាមទស្សនៈបែបប្រពៃណី នេះមានន័យថា «ភ្នែកត្រូវសងដោយភ្នែក» ។ ផ្ទុយទៅវិញ យុត្តិធម៌ដែលមានលក្ខណៈស្តារឡើងវិញជាចម្បងច្រើនតែស្វែងរកការផ្សះផ្សាតាមរយៈដំណើរការមួយចំនួនដូចជាការលើកតម្កើងជនរងគ្រោះ ដែលអាចផ្តល់កិត្តិយសឲ្យពួកគាត់វិញ ហើយជំរុញឲ្យមានភាពផ្សះផ្សា ។

យុត្តិធម៌មានលក្ខណៈផ្តន្ទាទោសប៉ុនប៉ងគូសបន្ទាត់ខណ្ឌចែករវាងអ្នកទាំងឡាយដែលត្រូវចាត់ទុកជាជនដៃដល់និងអ្នកទាំងឡាយដែលត្រូវបានមើលឃើញថាជាជនរងគ្រោះរបស់ខ្មែរក្រហម ។ ប៉ុន្តែ ដោយហេតុថាគ្រប់គ្នាសុទ្ធតែត្រូវទទួលរងឥទ្ធិពលពីអតីតកាលដ៏ខ្មៅងងឹត ព្រមទាំងបាត់បង់អ្នកជាទីស្រឡាញ់ ដូច្នេះហាក់បីដូចជាមិនមានបន្ទាត់មួយច្បាស់លាស់ដែលអាចញែកជនរងគ្រោះ និងជនដៃដល់ឲ្យដាច់ពីគ្នា ជាពិសេសចំពោះក្រុមកម្មាភិបាលថ្នាក់ក្រោម ។ សេចក្តីថ្លែងការណ៍របស់ខ្មែរក្រហមមួយបានបញ្ជាក់ថាខ្លាំង «គឺជាអ្វីៗដែលមិនបដិវត្តន៍និងដែលប្រឆាំងនឹងបដិវត្តន៍» ។ ដូច្នេះ កម្មាភិបាលខ្មែរក្រហមជាច្រើនពុំមានជម្រើសផ្សេងក្រៅពីធ្វើតាមបញ្ជាថ្នាក់លើឡើយ ប្រសិនបើមិនចង់បាត់បង់ជីវិតរបស់ខ្លួន ។ ហេតុដូច្នេះហើយ ជំនួសឲ្យការប៉ុនប៉ងបែងចែកភាពខុសគ្នារវាងអ្នកដែលត្រូវចាត់ទុកថាជាជនដៃដល់ និងអ្នកដែលត្រូវកំណត់ថាជាជនរងគ្រោះ ខ្ញុំជឿថា មធ្យោបាយល្អបំផុតដើម្បីសម្រេចយុត្តិធម៌អន្តរកាលនិងការផ្សះផ្សាគឺតាមរយៈការរួបផ្សំគ្នារវាងយុត្តិធម៌មានលក្ខណៈផ្តន្ទាទោសនិងយុត្តិធម៌មានលក្ខណៈស្តារឡើងវិញ ។

យុត្តិធម៌មានលក្ខណៈស្តារឡើងវិញផ្តោតទៅលើការព្យាបាលសង្គមនិងការផ្សះផ្សាសម្រាប់បុគ្គលនិងសហគមន៍ ។ ដោយហេតុថាមានភាពខ្វោចផ្សាដោយសារអំពើប្រល័យពូជសាសន៍ នេះគប្បីមានការបង្កើតឡើងនូវស្ថាប័នមួយចំនួននៅក្នុងប្រទេសកម្ពុជាដើម្បីផ្សះផ្សានិងបង្រួបបង្រួមជាតិ ។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនត្រូវបានដកហូតអត្តសញ្ញាណ ហើយត្រូវបានបង្ខំឲ្យបោះបង់វប្បធម៌របស់ខ្លួន ។ ដូច្នេះ យុត្តិធម៌មានលក្ខណៈស្តារឡើងវិញនឹងអាចជួយឲ្យប្រជាជនត្រឡប់ទៅរកជីវភាពជាមនុស្សដូចមុនវិញ ទន្ទឹមនឹងការព្យាបាលរបួសសង្គម ។ តាមរយៈកម្មវិធីមួយចំនួនរបស់យុត្តិធម៌មានលក្ខណៈស្តារឡើងវិញជួយឲ្យជនរងគ្រោះអាចបញ្ចេញសំឡេងរបស់ខ្លួននិងស្វែង

រកចម្លើយសម្រាប់សំណួររបស់ខ្លួន ថែមទាំងផ្តល់វិធីមួយឲ្យអ្នកដែលត្រូវគេចាត់ទុកថាជាជនដៃដល់ "ប្រឈមមុខនឹងសតិសម្បជញ្ញៈរបស់ខ្លួន" ។ ថ្វីត្បិតតែការសុំឲ្យជនរងគ្រោះលើកលែងទោសឲ្យជនដៃដល់ប្រហែលជារឿងដែលមិនអាចធ្វើទៅបានក៏ដោយ តែយុត្តិធម៌មានលក្ខណៈស្តារឡើងវិញផ្តល់ជាឧបករណ៍ចាំបាច់ដើម្បីតភ្ជាប់នូវគម្លាតរវាងក្រុមអ្នកទាំងពីរដែរ នេះនឹងអាចសម្រេចបាននូវការព្យាបាលសង្គមនិងដើម្បីឈានទៅរកការផ្សះផ្សាជាតិ ។

## ការផ្សះផ្សា

អាំស្មុស្ស បង្ហាញថា ការផ្សះផ្សាអាចជាដំណើរការ ឬជាលក្ខខណ្ឌមួយ ។ លោកបញ្ជាក់ថា "ក្នុងមុខងារជាដំណើរការ ការផ្សះផ្សាត្រូវបានចាត់ទុកជាឧបករណ៍មួយដើម្បីព្យាបាលទំនាក់ទំនងដែលបែកបាក់ ដោយផ្លាស់ប្តូរកំហឹងនិងគំនុំមកជាការស្វែងយល់ អត់ឱន និងទំនុកចិត្ត" ។ រីឯក្នុងន័យជាលក្ខខណ្ឌវិញ លោកបានបញ្ជាក់ថា "គឺជាសភាពស្ងប់សុខ ទំនាក់ទំនងចុះសម្រុងនឹងគ្នា និងជាបរិយាកាសមួយដែលអតីតសត្រូវសម្តែងពីការទុកចិត្តគ្នាទៅវិញទៅមកបង្ហាញពីសហប្រតិបត្តិការ និងដោះស្រាយការខ្វែងគំនិតគ្នាដោយសន្តិវិធី" ។ ខ្ញុំជឿថា និយមន័យដែល អាំស្មុស្ស ផ្តល់ទៅលើពាក្យ "ផ្សះផ្សា" មានអត្ថន័យប្រសព្វជាមួយយុត្តិធម៌មានលក្ខណៈស្តារឡើងវិញ ។ យោងតាម អេលីហ្សាប៊ែត ឃីស្ស យុត្តិធម៌មានលក្ខណៈស្តារឡើងវិញមានធាតុផ្សំបួន ។ ធាតុទាំងនេះគឺ "ការស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូរបស់ជនរងគ្រោះ ការទទួលខុសត្រូវចំពោះទោសកំហុសរបស់ជនល្មើស ការលើកស្ទួយការគោរពសិទ្ធិមនុស្សសាជាថ្មី និងការជំរុញឲ្យមានភាពផ្សះផ្សា" ។ ជាសរុប ការពន្យល់ទាំងពីរខាងលើសុទ្ធតែលើកស្ទួយនូវភាពយោគយល់គ្នា ហើយអាចនាំប្រទេសកម្ពុជាឆ្ពោះទៅកាន់ការផ្សះផ្សា ។

## ការស្នើសុំឲ្យមានការផ្សះផ្សា

លើសពីនេះ ខ្ញុំជឿថា តាមរយៈការរួមបញ្ចូលគ្នានៃកិច្ចខិតខំលើការរំឭកការកាត់ទោសលើបទឧក្រិដ្ឋ និងកម្មវិធីសំណងជំងឺចិត្ត ប្រទេសកម្ពុជានឹងអាចសម្រេចបាននូវការផ្សះផ្សា ។ ខ្ញុំជឿថា ការរួមបញ្ចូលដូច្នេះ រួមទាំងធាតុរបស់យុត្តិធម៌មានលក្ខណៈស្តារឡើងវិញដែល អេលីហ្សាប៊ែត ឃីស្ស បង្ហាញដល់យើងនេះ គឺជាវិធីដែលអាចអនុវត្តបាននិងស័ក្តិសមបំផុតចំពោះប្រទេសកម្ពុជា ។

## កិច្ចប្រឹងប្រែងលើការរំឭក

កម្មវិធីឬកិច្ចប្រឹងប្រែងលើការរំឭកមានសារៈសំខាន់ដើម្បីឲ្យប្រទេសមួយទាំងមូលរួមគ្នាប្រឈមមុខនឹងអតីតកាល ។ ខ្ញុំជឿថាកម្មវិធីប្រភេទនេះមានឥទ្ធិពលលើកម្រិតបុគ្គលនិងកម្រិតសង្គមច្រើនជាងកម្រិតថ្នាក់ជាតិ ។ ខ្ញុំមានជំនឿថាកម្មវិធីបែបនេះនឹងមានចំនួនកើនឡើងតាមដែលពេលវេលាកន្លងផុត ដោយសារពលិកម្មរបស់អង្គការក្រៅរដ្ឋាភិបាលមួយចំនួនដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាជាដើម ។ សារមន្ទីរទួលស្លែងនិងជើងឯកដែលធ្លាប់ជាកន្លែងដែលខ្មែរក្រហមប្រើសម្រាប់សម្លាប់រង្គាលឥឡូវបានក្លាយទៅជាបូជនីយដ្ឋាន ផ្តល់ជាកន្លែងដែលប្រជាជនអាចជួបជុំនិងកាន់ទុក្ខឲ្យព្រលឹងអ្នកស្លាប់ ។ នៅពេលប្រជាជនជួបជុំគ្នា ពួកគេនឹងមានកម្លាំងចិត្តដោយដឹងថាពួកគេមិនមែននៅតែឯងទេ ហើយអ្នកដែលបានបាត់បង់ជីវិតទាំងប៉ុន្មានមិនត្រូវគេបានបំភ្លេចឡើយ ។ នៅពេលធ្វើបទសម្ភាសមួយជាមួយ នង ចាន់ផល ដែលជាអ្នករួចជីវិតពីគុកទួលស្លែង គាត់រៀបរាប់ប្រាប់ខ្ញុំថាក្រោយឆ្នាំ១៩៧៩ គាត់បានទៅកាន់ទួលស្លែង ដើម្បីព្យាយាមចងចាំអតីតកាលរបស់គាត់ ។ លោក នង ចាន់ផល គឺជាឧទាហរណ៍ជាក់ស្តែងមួយបង្ហាញថា ការប្រឈមមុខនឹងអតីតកាលយ៉ាងក្លាហានគឺជាជំហានដំបូងហើយសំខាន់មួយក្នុងការផ្សះផ្សានិងការឈានដើរទៅអនាគត ។

បូជនីយដ្ឋានបែបនេះ ក៏ផ្តល់ឲ្យនូវសេចក្តីថ្លៃថ្នូរ និងការគោរពទៅចំពោះមុខអ្នកទាំងឡាយដែលស្លាប់បាត់បង់ជីវិតទៅយ៉ាងអាណោចអាធ័មមិនមានពិធីបញ្ចុះសពឲ្យបានល្អត្រឹមត្រូវឡើយ ។ បច្ចុប្បន្នទីកន្លែង ទាំងអស់នេះបានក្លាយទៅជាទិសដៅទេសចរណ៍ដែលជួយបង្កើនការយល់ដឹងជាអន្តរជាតិ ។ ខណៈពេលដែលអ្នកនៅរស់ជាច្រើនកំពុងតែព្យាយាមដើរទៅមុខក្នុងជីវិតរបស់ខ្លួន អ្នកនៅរស់ភាគច្រើនមិនចង់ឲ្យអ្នកជាទីស្រឡាញ់របស់ខ្លួនត្រូវបានបំភ្លេចចោលនោះទេ ។ លោក នង ចាន់ផល បានបញ្ជាក់ថា លោក "ជឿថាការអប់រំអំពីអតីតកាលដល់យុវជនសព្វថ្ងៃគឺជារឿងសំខាន់ខ្លាំងណាស់ ជាពិសេសដោយសារតែរឿងនេះជាសោក

នាដកម្មមួយដែលខ្មែរសម្លាប់ខ្មែរគ្នាឯង ។

កម្មវិធីលើការរំឭកមិនត្រូវបានកំណត់ថាជាអគារនិងការថែរក្សាទីតាំងជារូបរាងឡើយ ប៉ុន្តែក៏អាចទាក់ទងនឹងថ្ងៃទិវាពិសេសដែលត្រូវបានរំឭកដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ។ ថ្ងៃ២០ ខែឧសភា ត្រូវបានចាត់ទុកជា «ទិវាចងកំហឹង» ដើម្បីឧទ្ទិសដល់អ្នកទាំងឡាយដែលត្រូវស្លាប់ដោយសារខ្មែរក្រហម ។ នៅឆ្នាំនេះ ប្រជាជនប្រហែល២,០០០នាក់ បានជួបជុំគ្នានៅជើងឯកដែលជាអតីតវាលពិឃាដមួយ ។ នៅទីនោះ ក្រុមនិស្សិតបានសម្តែងឡើងវិញអំពីទារុណកម្មសាហាវឃោរឃៅនិងការសម្លាប់ ។ ព្រឹត្តិការណ៍បែបនេះនាំឲ្យសហគមន៍ជួបជុំគ្នានិងមានលទ្ធភាពអប់រំប្រជាជនក្នុងកម្រិតមួយដ៏ធំធេងជាង ។ នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ប្រជាជនភាគច្រើនកើតក្រោយរបបខ្មែរក្រហម ហើយមានការយល់ដឹងតិចតួចណាស់អំពីអតីតកាលដ៏សាហាវយង់ឃ្នងរបស់ប្រទេសខ្លួន ។ ហេតុដូច្នេះ ព្រឹត្តិការណ៍បែបនេះមានថាមពលមិនគ្រាន់តែរក្សាការនឹករឭកដល់ព្រលឹងអ្នកដែលចាកចេញទៅនោះទេ ប៉ុន្តែថែមទាំងមានលទ្ធភាពអប់រំដល់ប្រជាជនមួយក្រុមធំដែលមកពីស្រទាប់អាយុខុសៗគ្នា ។ ខណៈពេលដែលកិច្ចខិតខំប្រឹងប្រែងលើការរំឭកអាចត្រូវបានបង្ហាញជាសាធារណៈតាមទម្រង់ជាច្រើននោះ កិច្ចខិតខំប្រឹងប្រែងទាំងអស់សុទ្ធតែបម្រើឲ្យគោលបំណងដូចៗគ្នា គឺផ្តួចផ្តើមឡើងនូវដំណើរការព្យាបាលអប់រំអ្នកផ្សេងអំពីអតីតកាលនិងបង្កើតជំហានសំខាន់ៗដែលចាំបាច់ចំពោះការផ្សះផ្សាជាតិ ។

## កម្មវិធីសំណង

កម្មវិធីសំណងគឺជាកម្មវិធីដែលផ្តោតលើការកសាងនិងជួសជុលឡើងវិញនូវការខូចខាតដែលកើតមាន ។ យោងតាមមជ្ឈមណ្ឌលអន្តរជាតិនៃយុត្តិធម៌អន្តរកាល កម្មវិធីសំណង «គឺជាការផ្តួចផ្តើមគាំទ្រដោយរដ្ឋ ដែលជួយជួសជុលការខូចខាតខាងផ្នែកសម្ភារៈនិងសីលធម៌ ដោយសារការរំលោភបំពានពីអតីតកាល» ។ ប៉ុន្តែ ខ្ញុំជឿថាកម្មវិធីដែលបង្កើតឡើងដោយអង្គការក្រៅរដ្ឋាភិបាលពាំនាំនូវសេចក្តីសង្ឃឹមនិងការសន្យាឲ្យប្រទេសកម្ពុជាច្រើនជាង ដោយសារមានឧទាហរណ៍ជោគជ័យតាំងពីមុន ។ ខ្ញុំជឿថាប្រសិនបើរដ្ឋាភិបាលតែម្នាក់ឯងត្រូវទទួលបន្ទុកលើគម្រោងទាំងអស់នោះការិយាធិបតេយ្យ និងនយោបាយរាជរដ្ឋាភិបាលផ្សេងទៀតនឹងជ្រៀតចូលបណ្តាលឲ្យរាំងស្ទះដល់ភាពជោគជ័យរបស់កម្មវិធីទាំងនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាកម្មវិធីដ៏ជោគជ័យមួយក្នុងចំណោមកម្មវិធីសំណង ។ ឆ្លងកាត់បទពិសោធន៍របស់ខ្ញុំផ្ទាល់ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំឃើញថាទីនោះប្រជុំដោយមនុស្សមួយក្រុមដែលសុខចិត្តធ្វើដំណើរទៅទីឆ្ងាយដើម្បីទៅដល់ប្រជាជនកាន់តែច្រើនទៀត ។ ពួកគាត់ផ្តោតអារម្មណ៍លើគោលជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយធ្វើការដើម្បីមូលហេតុមនុស្សធម៌ជាជាងមូលហេតុហិរញ្ញវត្ថុ ។ ជាការពិតណាស់ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាជាកត្តាគោលដែលសម្រេចជោគជ័យក្នុងការចុះទៅដល់ប្រជាជននៅមូលដ្ឋាននិងកត់ត្រារឿងរ៉ាវរបស់ពួកគាត់ ។ ឧទាហរណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំជាអង្គភាពមួយដើម្បីលើកតម្កើងជនរងគ្រោះតាមរយៈការចូលរួមរបស់ពួកគាត់ ហើយថែមទាំងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីផ្សព្វផ្សាយដល់ពួកគាត់អំពីដំណើរការការកាត់ទោសខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាឧទាហរណ៍មួយដែលបញ្ជាក់ថា អង្គការក្រៅរដ្ឋាភិបាលអាចរួមចំណែកក្នុងការផ្សះផ្សានិងព្យាបាលរបួសផ្លូវចិត្តរបស់បុគ្គលនិងសង្គមទាំងមូល ។ មជ្ឈមណ្ឌលឯកសារកម្ពុជាផ្សព្វផ្សាយការអប់រំ បង្កើនការចាប់អារម្មណ៍ទៅលើអំពើប្រល័យពូជសាសន៍ ហើយជួយដល់ប្រជាជនឲ្យរកឃើញនូវចម្លើយទាក់ទងទៅនឹងអ្នកដែលខ្លួនស្រឡាញ់និងវាសនារបស់ពួកគាត់ក្នុងពេលនោះ ។ បើមិនមានការព្យាយាមរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការស្វែងរកនិងកត់ត្រាជាឯកសារទាំងនេះទេ នោះមានសំណួរជាច្រើននឹងមិនអាចរកចម្លើយបាន ។

## គណៈកម្មការស្វែងរកការពិត

គណៈកម្មការស្វែងរកការពិតក៏មានសារប្រយោជន៍ចំពោះអ្នកនៅរស់រានមានជីវិតផងដែរ ។ គណៈកម្មការស្វែងរកការពិតផ្តល់នូវវេទិកាមួយដែលប្រជាជនអាចមកសារភាពអំពីកំហុសខ្លួននិងផ្តល់ពន្លឺខ្លះដើម្បីឲ្យយើងអាចយល់ដឹងពីអតីតកាលដ៏ខ្មៅងងឹតនិងច្របូកច្របល់នៃប្រទេសជាតិមួយដែលបានរងទុក្ខក្រោមការប្រតិបត្តិផ្ទុយនឹងសិទ្ធិមនុស្ស ។ បទពិសោធន៍នៃគណៈកម្មការ

ស្វែងរកការពិតនិងការផ្សះផ្សាជាតិនៅប្រទេសអាហ្វ្រិកខាងត្បូងបានបញ្ជាក់ថា គណៈកម្មការបែបនេះអាចជួយដល់ដំណើរការផ្សះផ្សាជាតិនៅកម្ពុជា ។ អ្នកដែលនៅរស់រានមានជីវិតជាអ្នកដែលចង់ដឹងពីរឿងរ៉ាវដែលបានកើតឡើងបំផុត ។ ដោយហេតុអ្នកប្រព្រឹត្តខុសកាលពីអតីតកាលអាចទទួលបានការលើកលែងទោសពេលដែលគេសារភាព ពួកគេនឹងព្រមផ្តល់ការពិតកាន់តែច្រើនដល់ជនរងគ្រោះ ។ នៅប្រទេសអាហ្វ្រិកខាងត្បូង គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាជាតិបានសម្រេចនូវសាមគ្គីភាពសហគមន៍និងបង្កើនការចាប់អារម្មណ៍តាមរយៈប្រព័ន្ធផ្សព្វផ្សាយយ៉ាងទូលាយ ។ ខណៈដែលគណៈកម្មការស្វែងរកការពិតមានសក្តានុភាពក្នុងការរើកកាយរឿងអតីតកាល ខ្ញុំជឿជាក់ថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចនឹងបាត់បង់ប្រសិទ្ធភាពក្នុងវេទិការបែបនេះ ព្រោះថាអង្គជុំនំជម្រះនេះហាក់ដូចជាមិនមានការគាំទ្រគ្រប់គ្រាន់ពីរាជរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ សាធារណជននិងការជ្រោមជ្រែងខាងហិរញ្ញវត្ថុនៅពេលដែលកំពុងដំណើរការ ។

## ការកាត់ទោស

ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាមានប្រសាសន៍ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជា «តុលាការកម្ពុជាមួយដែលមានការចូលរួមពីសហគមន៍អន្តរជាតិ ហើយមានស្តង់ដារបែបអន្តរជាតិ» ។ អង្គជុំនំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលទ្ធភាពក្នុងការផ្សព្វផ្សាយការពិតទៅដល់ទស្សនិកជនទូទៅដោយដំណើរការទាំងមូលកំពុងត្រូវបានចាក់ផ្សាយតាមកញ្ចក់ទូរទស្សន៍ រលកវិទ្យុ និង ប្រព័ន្ធអ៊ីនធឺណេត ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាគំរូមួយនៃដំណើរការកាត់ក្តីក្នុងតុលាការបើកចំហ ហើយមានការបញ្ចូលនូវការផ្សព្វផ្សាយដល់យុវជននិងផ្តល់ការសម្រុះសម្រួលចិត្តដល់ជនរងគ្រោះ ដោយបានឃើញជនដៃដល់ត្រូវប្រឈមមុខនឹងការកាត់ទោស ។

យ៉ាងណាមិញ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានចំណុចខ្វះខាតមួយចំនួន ។ ជាបឋម ខ្ញុំយល់ថាមានបុគ្គលិកខ្លះមិនមានការត្រៀមខ្លួនបានល្អទេ ហើយនេះបណ្តាលឲ្យមានការអូសបន្លាយពេលវេលា ។ ព័ត៌មានទាំងឡាយមិនបានរៀបចំឲ្យរួចរាល់ជាមុន លើសពីនេះ ការបកប្រែដំណើរការជំនុំជម្រះទាំងមូលជាបីភាសាបណ្តាលឲ្យមានការពន្យារពេលកាន់តែវែងឆ្ងាយ ។ ប្រជាជនបានរង់ចាំលើសពីសាមសិបឆ្នាំដើម្បីទាមទារយុត្តិធម៌ ដូច្នេះខ្ញុំយល់ថាការខកខានបែបនេះមិនគួរទទួលយកបាននោះទេ ។

ចំណុចទីពីរគឺ ទោះជាកម្ពុជាហាក់ដូចជាមានប្រព័ន្ធផ្សព្វផ្សាយទូលាយក៏ដោយ ក៏មានប្រជាជនជាច្រើនដែលរស់នៅតំបន់ដាច់ស្រយាលក្រៅទីប្រជុំជនមិនបានដឹងអំពីដំណើរការកាត់ក្តីនេះដែរ ។ មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាជាដើមបាននិងកំពុងចូលរួមបង្កើនការយល់ដឹងអំពីការកាត់ក្តីនេះហើយ ថ្វីដ្បិតការខំប្រឹងប្រែងទាំងនេះត្រូវការពង្រីងបន្ថែមទីតាំងនៃអង្គជំនុំជម្រះនេះចោទជាបញ្ហាមួយក៏ដោយ ។ អាសយដ្ឋាននៃអង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺនៅក្នុងខណ្ឌដង្កោ ដែលជាតំបន់ជាយក្រុងនៃរាជធានីភ្នំពេញ ។ ទីតាំងនេះមិនងាយនឹងធ្វើដំណើរដល់នោះទេ ជាពិសេសចំពោះប្រជាជនមានទីលំនៅនៅតាមខេត្តដែលឆ្ងាយពីរាជធានី ។

ចំណុចទីបីគឺអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដាក់បន្ទុកហិរញ្ញវត្ថុគួរឲ្យកត់សម្គាល់ទៅលើប្រទេសកម្ពុជា ។ ខ្ញុំមានយោបល់ថា គួរតែមានសម្ពាធអន្តរជាតិមួយទៅលើសមាគមប្រជាជាតិអាស៊ាន ដើម្បីជំរុញឲ្យអាស៊ានចូលរួមដើរតួសំខាន់និងផ្តល់ជាជំនួយផ្នែកហិរញ្ញវត្ថុផង ។

ចំណុចទីបួនគឺពាក្យចចាមអារ៉ាមពីអំពើពុករលួយប៉ះពាល់ដល់ទំនុកចិត្តលើតុលាការ ។ ជាឧទាហរណ៍ មានបុគ្គលិកមួយចំនួនបានផ្តល់មុខតំណែងក្នុងតុលាការដោយមានការដោះដូរតាមរយៈហិរញ្ញវត្ថុ ។ មេធាវីការពារក្តីធ្លាប់ប្រើការពិតនេះជាភ័ស្តុតាងបញ្ជាក់ថាកូនក្តីគាត់មិនទទួលបានការកាត់ក្តីយុត្តិធម៌ដោយហេតុថាចៅក្រមអាចមានចំណែកក្នុងរឿងអាស្រូវពុករលួយ ។ ខ្ញុំមានអារម្មណ៍ថាអង្គភាព «ឯករាជ្យ» មួយផ្សេងទៀត គួរតែធ្វើការស៊ើបអង្កេតលើបញ្ហានេះដើម្បីកុំឲ្យមេធាវីការពារក្តីអាចយកលេសនេះមកជារន្ធាស់នៃការកាត់ទោសមានភាពយុត្តិធម៌ ។

ទោះបីជាមានចំណុចខ្វះខាតទាំងនេះ ខ្ញុំនៅតែមានជំនឿថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរក្សានូវពាក្យសន្យាភាគច្រើន ហើយអង្គជំនុំជម្រះនេះជាការបោះជំហានធំមួយទៅ

កាន់ការផ្សះផ្សាជាតិ ។ លោក កូហ្វី អាណាន់ បានមានប្រសាសន៍ថា «ជោគជ័យនៃអង្គជំនុំជម្រះវិសាមញ្ញនឹងក្លាយជាសញ្ញាមួយក្នុងតំបន់បង្ហាញថាវប្បធម៌នៃការលើកលែងទោសកំពុងតែត្រូវបានជំនួសដោយវប្បធម៌នៃទំនួលខុសត្រូវ» ។ ដូច្នេះ ខ្ញុំជឿជាក់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាជំពូកថ្មីមួយនៃប្រវត្តិសាស្ត្រកម្ពុជា ហើយនឹងផ្តល់ជាវេទិកានិងមូលដ្ឋានសម្រាប់ឲ្យប្រទេសនេះឈានទៅកាន់អនាគត ។

## ពុទ្ធសាសនា និង ការផ្សះផ្សា

តាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំនៅប្រទេសស្រីលង្កា ខ្ញុំបានឃើញថាមពលនៃសាសនាក្នុងការផ្សះផ្សាចំពោះអ្នកដែលបានស៊ូទ្រាំនឹងការឈឺចាប់ជាច្រើនឆ្នាំ ។ ដូចគ្នានេះដែរ ខ្ញុំជឿជាក់ថា សាសនាដើរតួសំខាន់មួយក្នុងប្រទេសកម្ពុជា ។ ព្រះពុទ្ធសាសនាបែបហីនយាន គឺជាសាសនាដែលត្រូវបានគេប្រតិបត្តិច្រើនជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា ។ សាសនានេះបង្រៀនអំពីការអាណិតអាសូរ និងការអត់ឱនទោស ហើយជឿជាក់ថាអំពើល្អនឹងជម្នះលើអំពើអាក្រក់ ។ សាសនានេះថែមទាំងអប់រំថា ការធ្វើអំពើល្អទៅលើអ្នកនៅជុំវិញខ្លួននឹងអាចនាំមនុស្សឲ្យរួចផុតពីអតីតកាលអាក្រក់ ហើយរំសាប់អារម្មណ៍គុំគួន ។ ក្នុងការស្ទាបស្ទង់មតិមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា បុគ្គលម្នាក់បាននិយាយប្រាប់ថា «ពៀររំសាប់ដោយការមិនចងពៀរ» ។

ការបង្រៀនបែបព្រះពុទ្ធសាសនាជួយជំរុញការកាត់ក្តីដោយយុត្តិធម៌មួយ ។ ក្នុងសៀវភៅដែលមានចំណងជើងថា «ការផ្សះផ្សានៅកម្ពុជា» អ្នកស្រី ស៊ូ ហ្សានឡិនគុន បានបង្ហាញពីឥទ្ធិពលដែលព្រះពុទ្ធសាសនាមានទៅលើការផ្សះផ្សាជាតិ ។ គាត់បានបង្ហាញការដកស្រង់សម្តីផ្សេងៗចេញពីមេដឹកនាំសាសនានៅកម្ពុជា ។ សម្តីដកស្រង់ខាងក្រោមបង្ហាញពីគោលការណ៍ព្រះពុទ្ធសាសនាដើរស្របទៅនឹងដំណើរការកាត់ទោសស្មើភាពមួយ ៖ «នៅពេលដែលអ្នកត្រូវគេចោទប្រកាន់ទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋកម្មរបស់ពួកគេ ប្រជាជននឹងរីករាយ ហើយឈប់ប្ញារម្ភនិងលើកលែងទោសឲ្យគ្នាទៅវិញទៅមក ។ មានតែពេលនោះទេទើបប្រជាជនកម្ពុជាចាប់ផ្តើមគិតអំពីសន្តិភាពដ៏យូរអង្វែង និងការផ្សះផ្សាជាតិ រាប់អានជាមួយអ្នកដទៃ មានការអាណិតអាសូរគ្នាទៅវិញទៅមក និងចាប់ផ្តើមកសាងប្រទេសឡើងវិញឆ្ពោះទៅរកសុខុមាលភាព ។

ព្រះពុទ្ធសាសនាមិនមែនជាសាសនាតែមួយដែលនឹងនាំមកនូវការផ្សះផ្សាជាតិនោះទេ ។ ប្រទេសកម្ពុជាគឺជាកន្លែងដែលផ្តល់សិទ្ធិឲ្យមានការប្រតិបត្តិសាសនាដទៃទៀត ។ សាសនាទាំងអស់បង្រៀនគោលការណ៍ស្រដៀងៗគ្នាដូចជាសន្តិភាព ការលើកលែងទោស ការអត់ឱន និង ការអាណិតអាសូរ ។ ក្នុងរបបខ្មែរក្រហម ប្រទេសទាំងមូលត្រូវបានផ្លាស់ប្តូរទាំងស្រុង ហើយមនុស្សត្រូវបានបង្ខំឲ្យបោះបង់អត្តសញ្ញាណរបស់ខ្លួន សាសនា និង វប្បធម៌ ។ ប៉ុន្តែ ឥឡូវប្រជាជនអាចប្រតិបត្តិតាមសាសនាដែលពួកគេប្រាថ្នា ហើយលើកស្ទួយវប្បធម៌របស់ពួកគេឡើងវិញ ។ ដោយហេតុដែលអាចលើកស្ទួយសាសនា វប្បធម៌ និងអត្តសញ្ញាណខ្លួនឡើងវិញ ប្រជាជនកម្ពុជាបានឈានមួយជំហានយ៉ាងធំចេញពីសម័យកាលដ៏ខ្មៅងងឹតនៃរបបខ្មែរក្រហម ។

## តួនាទីរបស់យុវជន

ការផ្សះផ្សាជាតិទាមទារឲ្យមានការចូលរួមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កម្មវិធីរំឭក កម្មវិធីសំណង រួមជាមួយការប្រតិបត្តិសាសនា ។ ជាសរុប វិធីនីមួយៗមានតួនាទីក្នុងការអប់រំប្រជាជនកម្ពុជាអំពីអតីតកាល ។ ខ្ញុំជឿជាក់ថា ការអប់រំប្រជាជនកម្ពុជាមានសារៈសំខាន់ចំពោះអនាគតនៃប្រទេសកម្ពុជា ។ ឆ្លងតាមការអប់រំអ្នកជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រ យើងអាចធានាថា រឿងនេះនឹងមិនអាចកើតឡើងសាជាថ្មីម្តងទៀតទេ ។ ប្រសិនបើប្រទេសកម្ពុជាប្រាថ្នាចង់បានការផ្សះផ្សាជាតិ ខ្ញុំជឿថាត្រូវពឹងផ្អែកលើការយកចិត្តទុកដាក់របស់ប្រជាជន ។ ការផ្តួចផ្តើមលើវិស័យអប់រំនឹងអប់រំសិស្សានុសិស្សអំពីយុត្តិធម៌ និងការផ្សះផ្សា ដើម្បីឲ្យពួកអ្នកជំនាន់ក្រោយក្លាយជាអ្នកដឹកនាំមានចិត្តទៀងត្រង់និងមិនលម្អៀង ។ យុវជនខ្មែរជាប្រអប់ទ្រព្យសម្បត្តិដែលមានសក្តានុភាពអាចប្រែក្លាយប្រទេសកម្ពុជាឲ្យក្លាយជាប្រទេសដ៏រុងរឿងមួយ ។ អនាគតនៃកម្ពុជាស្ថិតនៅលើកណ្តាប់ដៃយុវជនបច្ចុប្បន្ន ហើយវិស័យអប់រំជាកូនសោសម្រាប់បញ្ចេញសក្តានុភាពរបស់ពួកគេ ។

**អាន នីរ៉ូស៊ីកា ខ៉ាស**

# ការអនុវត្តនៃការទទួលខុសត្រូវថ្នាក់លើរបស់មេដឹកនាំស៊ីវិល

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហៅកាត់ (*«ECCC»* ឬ «អង្គជុំនុំជម្រះ») បានបង្កើតឡើងដើម្បីដាក់ទំនួលខុសត្រូវបែបព្រហ្មទណ្ឌទៅលើអ្នកដឹកនាំថ្នាក់ខ្ពស់ខ្មែរក្រហមនិងជនដទៃទៀតដែលមានទំនួលខុសត្រូវខ្ពស់បំផុតទៅលើការរំលោភបំពានលើច្បាប់ព្រហ្មទណ្ឌនិងច្បាប់អន្តរជាតិយ៉ាងធ្ងន់ធ្ងររវាងខែមេសាឆ្នាំ១៩៧៥ និង ខែមករា ឆ្នាំ១៩៧៩ ។ មាត្រា២៩ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឆ្នាំ២០០៤ បានដាក់ការទទួលខុសត្រូវជាបុគ្គលទៅលើអ្នកដឹកនាំចំពោះទង្វើរបស់ថ្នាក់ក្រោម រួមជាមួយទំនួលខុសត្រូវដទៃទៀត ។ ដោយហេតុយុត្តាធិការនៃអង្គជុំនំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគ្របដណ្តប់តែលើជនជាប់ចោទដែលមានឋានៈខ្ពស់ប៉ុណ្ណោះ ការកាត់ទោសប្រហែលជាត្រូវសម្អាងយ៉ាងហោចមួយផ្នែកក្នុងគោលការណ៍ទំនួលខុសត្រូវថ្នាក់លើដើម្បីកំណត់ដាក់ទោសអតីតមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យចំពោះបទឧក្រិដ្ឋរបស់ថ្នាក់ក្រោម ។ នេះសមស្របក្នុងករណីថាការកាត់ទោសខ្មែរក្រហមនេះដោយសារថ្នាក់ដឹកនាំជាន់ខ្ពស់ប្រហែលជាមិនបានប្រព្រឹត្តបទល្មើសភាគច្រើនដោយខ្លួនឯងទេ តែពួកគាត់គួរតែបានជ្រាបដឹងថាថ្នាក់ក្រោមបានចូលរួមក្នុងការរំលោភបំពានច្បាប់ជាតិនិងអន្តរជាតិដ៏ធ្ងន់ធ្ងរបំផុតដែរ ។

ថ្វីដ្បិតតែទំនួលខុសត្រូវថ្នាក់លើគឺជាគោលការណ៍ដែលបានបង្កើតយ៉ាងបរិបូរក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិសព្វថ្ងៃក៏ដោយ តែដោយសារមានគោលការណ៍ទូទៅថា nullem crimen sine lege («គ្មានបទល្មើស បើគ្មានច្បាប់ចែង») អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចផ្តន្ទាទោសចំពោះតែជនដែលល្មើសនឹង



*សិស្សានុសិស្សកំពុងតម្រង់ជួរចូលមើលសវនាការកាត់ទោសឌុច*

ច្បាប់ដែលមានរួចហើយប៉ុណ្ណោះនៅពេលអំពើល្មើសនោះកើតឡើង ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកំណត់យុត្តាធិការបណ្តោះអាសន្នរបស់ខ្លួនដូចតទៅ ៖ អង្គជំនុំជម្រះអាចកាត់ក្តីតែលើករណីដែលបានបញ្ជាក់ថាកើតឡើងក្នុងចន្លោះឆ្នាំ ១៩៧៥ និង១៩៧៩ប៉ុណ្ណោះ ។ ដូច្នេះ ជនជាប់ចោទមានទំនួលខុសត្រូវចំពោះតែបទឧក្រិដ្ឋដែលបានប្រព្រឹត្តហើយបានបញ្ជាក់ថាកើតឡើងក្នុងអំឡុងពេលជាក់លាក់នេះ (១៩៧៥-៧៩) ។

អតីតមេដឹកនាំដែលត្រូវបានចោទប្រកាន់មាននាទីជាសមាជិកគណៈមជ្ឈិមនៃរបបកម្ពុជាប្រជាធិបតេយ្យ អាចលើកការជជែកតវ៉ាបែប «គ្មានបទល្មើស បើគ្មានច្បាប់ចែង» ដោយបញ្ជាក់ថា ការទទួលខុសត្រូវរបស់ថ្នាក់លើមិនអាចអនុវត្តលើទង្វើពួកគេនៅក្នុងអំឡុងពេលដែលអង្គជំនុំជម្រះវិសាមញ្ញបានកំណត់ក្នុងយុត្តាធិការបណ្តោះអាសន្ន(១៩៧៥-៧៩) ជាពិសេសការទទួលខុសត្រូវរបស់ថ្នាក់លើអាចប្រើបានតែក្នុងករណីយោធាប៉ុណ្ណោះនៅក្នុងពេលនោះ ដោយមិនបានរាប់បញ្ចូលទាំងមេដឹកនាំស៊ីវិលផងទេទេ ។ ដោយមានការស្មានទុកជាមុននូវការតវ៉ានេះ អត្ថបទយើងនឹងពិនិត្យទៅលើបញ្ហាថាតើការទទួលខុសត្រូវរបស់ថ្នាក់លើអាចប្រើនៅក្នុងករណីមេដឹកនាំស៊ីវិលក្នុងចន្លោះឆ្នាំ ១៩៧៥-៧៩ឬទេ ។ ពោលគឺយើងនឹងវិភាគថាតើការទទួលខុសត្រូវនេះអាចប្រកាន់ជំហរខ្លួនបាននៅមុខការជជែកតវ៉ាថា «គ្មានបទល្មើស បើគ្មានច្បាប់ចែង» ពីខាងជនជាប់ចោទដែរឬទេ ។

នៅក្នុងការវិភាគនេះ យើងគប្បីស្វែងយល់អំពីការឲ្យនិយមន័យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៅលើធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ។ បច្ចុប្បន្ន តុលាការមិនទាន់មានការសម្រេចចំពោះបញ្ហានេះនៅឡើយទេ តែច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតបានផ្តល់ជាឧទាហរណ៍មួយបង្ហាញពីរបៀបបញ្ចប់ជម្លោះនេះ ។ មាត្រា២៩នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ជាក់ថា៖ «អំពើឧក្រិដ្ឋកម្ម.... ដែលបានប្រព្រឹត្តដោយថ្នាក់ក្រោមម្នាក់មិនអាចដាក់ទំនួលខុសត្រូវទៅលើថ្នាក់លើនោះទេ លុះត្រាតែថ្នាក់លើមានសិទ្ធិបញ្ជាគ្រប់គ្រង ឬអំណាចគ្រប់គ្រងថ្នាក់ក្រោមយ៉ាងមានប្រសិទ្ធភាព ហើយថ្នាក់លើនោះបានជ្រាប ឬមានហេតុផលដឹងឮថាថ្នាក់ក្រោមអាចនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តអំពើនេះ ហើយថ្នាក់លើមិនបានចាត់វិធានការចាំបាច់ ឬសមស្របដើម្បីចៀសវាងសកម្មភាពនេះ ឬដាក់ទណ្ឌកម្មជនដែលដល់» ។ ការបង្ហាញគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើនេះស្រដៀងនឹងបទបញ្ញត្តិដែលមានទំនាក់ទំនងនៅក្នុងលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីនិងតុលាការព្រហ្មទណ្ឌអន្តរជាតិប្រទេសរ៉្វាន់ដា ។

យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានបញ្ជាក់យ៉ាងច្បាស់ស្តីអំពីលក្ខន្តិកៈគោល ហើយបានបង្កើតច្បាប់ថា ការទទួលខុសត្រូវរបស់ថ្នាក់លើមានធាតុផ្សំបីច្បាស់លាស់ពេលដែលប្រើទាំងទៅលើមេដឹកនាំយោធា និងមេដឹកនាំស៊ីវិល ។ ធាតុផ្សំទាំងនោះមានដូចតទៅ៖ ១) ទំនាក់ទំនងរវាងថ្នាក់លើនិងថ្នាក់ក្រោមដែលប្រកបដោយលក្ខណៈ «គ្រប់គ្រងដោយមានប្រសិទ្ធភាព» ធ្វើឡើងដោយថ្នាក់លើទៅលើថ្នាក់ក្រោម ២) ថ្នាក់លើជ្រាបដឹង ឬមានហេតុផលជ្រាបដឹងពីបទឧក្រិដ្ឋរបស់ថ្នាក់ក្រោម និង៣) មិនបានចាត់វិធានការចាំបាច់និងសមស្របដើម្បីចៀសវាងសកម្មភាពនេះឬដាក់ទណ្ឌកម្មជនដែលដល់ ។ បើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចង់ឲ្យនិយមន័យការទទួលខុសត្រូវរបស់ថ្នាក់លើស្រដៀងនេះ គេត្រូវបញ្ជាក់ថា ការប្រតិបត្តិដូចគ្នានេះធ្លាប់ត្រូវបានដាក់ទោសក្នុងយុត្តាធិការនៃតុលាការ ។

ក្នុងការឆ្លើយតបទៅនឹងការជជែកតវ៉ាថា «គ្មានបទល្មើស បើគ្មានច្បាប់ចែង» តុលាការអាចបញ្ជាក់ថារវាងឆ្នាំ១៩៧៥-៧៩ ការទទួលខុសត្រូវរបស់ថ្នាក់លើបានមានវត្តមានក្នុងច្បាប់អន្តរជាតិក្នុងទម្រង់ជាក់លាក់មួយ ហើយមានរូបមន្តស្រដៀងគ្នានិងដូចដែលបានរៀបរាប់ខាងលើ នេះអាចបញ្ជាក់ ថាមិនមានការដាក់បន្ទុកដោយអយុត្តិធម៌ទៅលើជនជាប់ចោទនោះទេ ។ ជាពិសេសការកាត់ទោសនេះត្រូវតែបញ្ជាក់ខ្លួនថា ១) អាចប្រើប្រាស់ចំពោះថ្នាក់ដឹកនាំស៊ីវិលក្នុងអំឡុងពេលពាក់ព័ន្ធ (១៩៧៥-៧៩) ក្នុងទម្រង់ជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល ២) ក្នុងទម្រង់ជាក់លាក់ និង ៣) បានប្រើទៅលើជនជាប់ចោទណាមួយជាក់លាក់ដើម្បីធ្វើការដាក់ឲ្យមានទណ្ឌកម្មព្រហ្មទណ្ឌដែលអាចគិតទុកជាមុន ។

យោងតាមយុត្តាធិការក្នុងការកាត់ទោសក្រោយសង្គ្រាមលោកលើកទីពីរដូចជា តុលាការយោធាអន្តរជាតិ និងតុលាការយោធាអន្តរជាតិបូព៌ានិងមាត្រា៨៧ ៣) នៃពិធីសារបន្ថែមទៅលើអនុសញ្ញាក្រុងហ្សឺណែវ យើងអាចឃើញជាក់ស្តែងថា យ៉ាងហោចណាស់ចំពោះមេដឹកនាំស៊ីវិលការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានប្រើប្រាស់ក្នុងទម្រង់ជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលក្នុងច្បាប់អន្តរជាតិក្នុងចន្លោះឆ្នាំ១៩៧៥-៧៩ ។

ដោយអាចបញ្ជាក់ថា ការទទួលខុសត្រូវរបស់ថ្នាក់លើពិតជាមានវត្តមានពិតមែន បន្ទាប់មកទៀតយើងអាចបន្តពិភាក្សាអំពីបញ្ហាដែលអាចបណ្តាលឲ្យមានជម្លោះកាន់តែធំ នោះគឺតើការទទួលខុសត្រូវរបស់ថ្នាក់លើអាចយកមកប្រើទៅលើជនស៊ីវិលក្នុងចន្លោះឆ្នាំ១៩៧៥-៧៩ ឬទេ ។ ក្នុងយុត្តាធិការថ្មីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិប្រទេសរ៉្វាន់ដារួមជាមួយលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានកំណត់ច្បាស់លាស់នូវទម្រង់នៃការទទួលខុសត្រូវបែបព្រហ្មទណ្ឌជាបុគ្គលរបស់ថ្នាក់លើស៊ីវិល ។ ផ្ទុយទៅវិញ ករណីសន្និសញ្ញាដែលមានពីមុនបានកំណត់ន័យទូទៅចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ ។ គេដាក់ការទទួលខុសត្រូវទៅលើថ្នាក់លើដោយមិនមានការបែងចែករវាងជនស៊ីវិលនិងយោធានោះទេ ។ លើសពីនេះ លក្ខន្តិកៈទីក្រុងរ៉ូមគឺជាការបែងចែកទំនួលខុសត្រូវស៊ីវិលនិងយោធាជាលើកដំបូង ហើយធ្វើការបែងចែកនូវសមាសធាតុខុសគ្នាបន្តិចបន្តួចទៅលើទំនួលខុសត្រូវទាំងពីរនេះ ។

យ៉ាងណាមិញ យោងតាមយុត្តាធិការនៃតុលាការក្រោយសង្គ្រាមលោកលើកទីពីរនិងពិធីសារបន្ថែម យើងអាចបញ្ជាក់យ៉ាងច្បាស់ថាការទទួលខុសត្រូវរបស់ថ្នាក់លើគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ។ ក្នុងខណៈពេលដែលតុលាការក្រោយសង្គ្រាមលោកលើកទីពីរមិនបានបង្កើតស្តង់ដារច្បាស់លាស់សម្រាប់កំណត់បំណងឧក្រិដ្ឋក្នុងកម្រិតនៃការគ្រប់គ្រងទៅលើអ្នកក្រោមបញ្ជាសម្រាប់កំណត់អ្នកដឹកនាំស៊ីវិល តែគេបានដាក់ទោសមេដឹកនាំស៊ីវិលខ្លះដោយការទទួលខុសត្រូវរបស់ថ្នាក់លើដោយសារលក្ខន្តិកៈរបស់ពួកគេ នេះជាការអភិវឌ្ឍដែលបានប្រមូលជាក្រមទៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយពិធីសារបន្ថែមទីមួយក្នុងឆ្នាំ១៩៧៧ ដែលអះអាងថាគ្រាន់តែបញ្ជាក់ឡើងវិញនូវច្បាប់ទំនៀមទម្លាប់ដែលមានរួចមកហើយ ។ ដូច្នេះ អង្គជុំនំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាអាចរកឃើញថាការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិតាំងពីមុនឆ្នាំ១៩៧៥-៧៩ ។

គោលបំណងដើមរបស់គោលការណ៍ «គ្មានបទល្មើស បើគ្មានច្បាប់ចែង» គឺដើម្បីការពារអ្នកដែលមានអំពើដោយសុខចិត្តតែមិនបានយល់ដឹងអំពីច្បាប់ ។ យុត្តាធិការក្រោយសង្គ្រាមលោកលើកទីពីរដែលបានពង្រឹងដោយពិធីសារបន្ថែមទីមួយបានបញ្ជាក់យ៉ាងច្បាស់ថាមេដឹកនាំស៊ីវិលអាចមានទំនួលខុសត្រូវបែបព្រហ្មទណ្ឌដោយសារតែការទទួលខុសត្រូវរបស់ថ្នាក់លើ ។ ដូច្នេះ ច្បាប់នេះមានវត្តមានក្នុងទម្រង់ជាក់លាក់ដើម្បីដាក់ទោសមេដឹកនាំស៊ីវិលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ។ ជនជាប់ចោទក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយគុណធម៌ក្នុងនាមជាជនដែលមានឋានៈខ្ពស់ក្នុងរដ្ឋអំណាច ពួកគេគប្បីជ្រាបថានឹងត្រូវប្រឈមមុខនឹងច្បាប់ដោយសារតែមិនបានចាត់វិធានការដើម្បីទប់ស្កាត់ការប្រព្រឹត្តអំពើល្មើសរបស់ថ្នាក់ក្រោម ។ ហេតុដូច្នេះ អង្គជំនុំជម្រវិសាមញ្ញក្នុងតុលាការកម្ពុជាអាចនឹងរកឃើញថាពួកគេត្រូវបានប្រាប់ឲ្យដឹងថាអំពើរបស់ពួកគេគឺល្មើសនឹងច្បាប់ ហើយច្បាប់មិនស្រពេចស្រពិលហួសហេតុរហូតមិនអាចប្រើចំពោះពួកគេបាននោះទេ ។

ជាសរុប ការជជែកតវ៉ាបែប «គ្មានបទល្មើស បើគ្មានច្បាប់ចែង» ដែលអះអាងថាការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំស៊ីវិលមិនមានចែងក្នុងច្បាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩ មិនអាចឈរជើងបាននោះទេ ។ ប្រសិនបើការការពារខ្លួននេះត្រូវបានលើកឡើងនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ភ័ស្តុតាងរួមមានច្បាប់យុត្តិសាស្ត្រ ច្បាប់ អនុសញ្ញានិងសមាសធាតុយុត្តិធម៌ក្នុងគោលការណ៍ «គ្មានបទល្មើស បើគ្មានច្បាប់ចែង» សុទ្ធតែប្រឆាំងនឹងជនជាប់ចោទ ។

**រីហាន អារះបយរ៉េនី**

# ស្ត្រីនៅប្រទេសកម្ពុជាៈ សង្កេតទៅលើឋានៈស្ត្រីខ្មែរ តាមរយៈរបាយការណ៍អភិវឌ្ឍន៍ធនធានមនុស្ស

ព្រះរាជាណាចក្រកម្ពុជាជាប្រទេសមួយធ្លាប់បង្ហាញអច្ឆរិយវត្ថុដ៏អស្ចារ្យ តែក៏ធ្លាប់ជាឧទាហរណ៍បញ្ជាក់អំពីភាពសាហាវឃោរឃៅបំផុតរបស់មនុស្សដែរ ។ ប្រទេសនេះបង្អួតបង្ហាញប្រាង្គប្រាសាទអង្គរវត្តដែលជាអច្ឆរិយវត្ថុបុរាណមួយបញ្ជាក់ពីភាពប៉ិនប្រសប់ខាងស្ថាបត្យកម្ម ។ ប៉ុន្តែកម្ពុជាធ្លាប់ជាទីពិឃាតពោរពេញទៅដោយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមរបបខ្មែរក្រហមដែលប្រកាន់លទ្ធិកុម្មុយនីស្តម៉ៅនិយម ។ ដូចគ្នានឹងរូបភាពផ្ទុយគ្នាដែលប្រទេសនេះបង្ហាញការរំពឹងគិតចំពោះស្ត្រីកម្ពុជាក៏មានភាពប្រឆាំងគ្នាដែរ ។ ក្នុងខណៈពេលដែលកុមារីខ្មែរទទួលការប្រៀនប្រដៅឲ្យមានអត្តចរិតអៀនខ្មាសនិងស្តាប់បង្គាប់ពួកគេត្រូវបានរំពឹងឲ្យមានភាពរឹងប៉ឹង មានសមត្ថភាព និងចេះបញ្ចេញមតិផ្ទាល់ខ្លួន ។ ដើម្បីបញ្ជាក់អំពីស្ថានភាពប្រវត្តិសាស្ត្រក្នុងការពិភាក្សានេះ អត្ថបទយើងនឹងបង្ហាញពីប្រវត្តិសាស្ត្របច្ចុប្បន្ននៃប្រទេសកម្ពុជា ។ បន្ទាប់មក ខ្ញុំនឹងវិភាគលើស្ថិតិដែលបានមកពីរបាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សនៃអង្គការសហប្រជាជាតិដើម្បីធ្វើការសន្និដ្ឋានអំពីស្ថានភាពដែលស្ត្រីខ្មែរជួបប្រទះ ។

## ព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាស្ថិតនៅអាស៊ីអាគ្នេយ៍ ហើយមានប្រជាជនប្រមាណ១៤លាននាក់ ។ កម្ពុជាទទួលបានឯករាជ្យនិងប្រកាន់យករបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៥៣ ក្រោមអធិបតីភាពរបស់សម្តេចព្រះបាទនរោត្តម សីហនុ ។ ក្នុងឆ្នាំ១៩៧០ លោកសេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារក្នុងខណៈពេលដែលសម្តេច សីហនុ ពុំមានវត្តមាននៅក្នុងប្រទេស ។ ក្រោយពីហេតុការណ៍នយោបាយនេះ ប្រទេសកម្ពុជាធ្លាក់ចូលក្នុងភ្លក់ភ្លើងសង្គ្រាមស៊ីវិលអស់រយៈពេលកន្លះទសវត្ស ។ ខ្មែរក្រហមដែលជារដ្ឋអំណាចប្រកាន់មនោគមន៍វិជ្ជាកុម្មុយនីស្តម៉ៅនិយមបានគ្រប់គ្រងប្រទេសទាំងមូលក្នុងឆ្នាំ១៩៧៥ ។ ក្រុមឧទ្ទាមនេះមកពីតំបន់ដាច់ស្រយាល ហើយដឹកនាំដោយ ប៉ុល ពត ដ៏សាហាវឃោរឃៅ ។ ក្រោយពីបានឡើងកាន់អំណាច ពួកគេបានជម្លៀសប្រជាជនចេញពីទីក្រុង ហើយបញ្ជូនទៅកាន់ជនបទក្នុងគោលបំណងលុបបំបាត់គំនិតពុករលួយបែបបស្ចិមឲ្យអស់ទាំងឫសពីប្រទេសកម្ពុជា ។ ទាហានខ្មែរក្រហមបានសម្លាប់ឬចាប់ខ្លួនជនទាំងឡាយណាដែលមានកម្រិតអប់រំខ្ពស់ទូទាំងផ្ទៃប្រទេសដោយគិតថាពួកនេះអាចគំរាមកំហែងដល់រដ្ឋអំណាចរបស់ខ្លួន ។ ខ្មែរក្រហមបានសម្លាប់ទាំងបុរស ស្ត្រី និង កុមារអស់ប្រមាណ២លាននាក់ដោយផ្ទាល់ ឬដោយប្រយោលតាមរយៈការបង្អត់អាហារនិងកង្វះខាតអនាម័យ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់នូវឯកសារជាច្រើនអំពីប្រវត្តិរបស់ខ្មែរក្រហម ដូចជា ដំណើរការកាត់ទោសខ្មែរក្រហមការអប់រំអំពីអំពើប្រល័យពូជសាសន៍ និងកំណត់ត្រារឿងហេតុរបស់ជនរងគ្រោះ ។

ទីបំផុតរបបខ្មែរក្រហមដ៏ព្រៃផ្សៃត្រូវបានបញ្ចប់ដោយយុទ្ធនាការយោធាក្រោមការគាំទ្ររបស់រដ្ឋាភិបាលវៀតណាមកុម្មុយនីស្ត ។ ប៉ុន្តែជោគជ័យនេះមិនបានផ្តល់នូវស្ថិរភាពនយោបាយដល់តំបន់នេះទេ ដោយប្រទេសកម្ពុជាបានធ្លាក់ទៅក្នុងសង្គ្រាមផ្ទៃក្នុងសាជាថ្មីម្តងទៀត ។ ការសិក្សាអំពីប្រទេសកម្ពុជាភាគច្រើនផ្តោតទៅលើអំពើប្រល័យពូជសាសន៍ តែមិនមានការសិក្សាអំពីហេតុការណ៍ក្រោយពីនោះឡើយ ។ រហូតដល់ឆ្នាំ១៩៩១ អង្គការសហប្រជាជាតិទើបទទួលស្គាល់ប្រទេសកម្ពុជាក្នុងមជ្ឈដ្ឋានអន្តរជាតិតាមរយៈសន្ធិសញ្ញាក្រុងប៉ារីស ។ ក្រោមការជ្រោមជ្រែងរបស់អង្គការសហប្រជាជាតិ ប្រទេសកម្ពុជាបានធ្វើការបោះឆ្នោតជាសាកលនៅឆ្នាំ១៩៩៣រវាងគណបក្សប្រជាជននិងគណបក្សហ៊្វុនស៊ិនប៉ិច ដែលបង្កើតដោយអ្នកគាំទ្ររាជវង្សស្តេច ។ បន្ទាប់ពីមានការទទួលស្គាល់របស់អង្គការសហប្រជាជាតិមានការកើនឡើងយ៉ាងគួរឲ្យកត់សម្គាល់នូវជំនួយសម្រាប់អភិវឌ្ឍន៍ពីបរទេសនិងវត្តមាននៃអង្គការក្រៅរដ្ឋាភិបាល ។ សព្វថ្ងៃ អង្គការទាំងនេះកំពុងចូលរួមក្នុងការបញ្ចប់នូវអស្ថិរភាពសង្គមនិងអំពើអយុត្តិធម៌

ដែលមានជាច្រើនឆ្នាំមកនេះដើម្បីជំរុញប្រទេសកម្ពុជាឲ្យទៅកាន់អនាគតដ៏ភ្លឺស្វាង ។

## កម្ពុជា និង ការអភិវឌ្ឍ

បន្ទាប់ពីបានបង្ហាញអំពីប្រវត្តិសាស្ត្របច្ចុប្បន្នរបស់កម្ពុជា ឯកសារនេះនឹងវិភាគទៅលើស្ថិតិក្នុងរបាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សរបស់អង្គការសហប្រជាជាតិ ។ ដើម្បីស្វែងយល់អំពីស្ថិតិទាំងនេះ ខ្ញុំនឹងរៀបរាប់អំពីប្រទេសជិតខាងរបស់កម្ពុជាក្នុងតំបន់អាស៊ីអាគ្នេយ៍ រួមមាន ថៃ ភូមាមានឈ្មោះជាផ្លូវការថា (មីយ៉ាន់ម៉ា) និងសាធារណរដ្ឋប្រជាមានិតឡាវត្រូវបានស្គាល់ផងដែរថា (ឡាវ) ។ ជាដំបូង ឯកសារនេះនឹងធ្វើការប្រៀបធៀបទៅលើប្រជាសាស្ត្រនៃប្រទេសទាំងនេះក្នុងវិស័យអភិវឌ្ឍន៍ បន្ទាប់ពីព័ត៌មានទូទៅនេះ ខ្ញុំនឹងពិនិត្យទៅលើឋានៈនៃស្ត្រីខ្មែរធៀបទៅនឹងប្រទេសដែលបានរៀបរាប់ខាងលើក្នុងវិស័យខុសៗគ្នារួមមានសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ និង អប់រំ ។

ក្រោយពីបានសង្កេតមើលកម្រិតអភិវឌ្ឍន៍នៃប្រទេសកម្ពុជាតាមរយៈការវាយតម្លៃលើការអភិវឌ្ឍធនធានមនុស្ស យើងឃើញថាក្នុងវិស័យមួយចំនួនដូចជា ភាគរយនៃប្រជាជនដែលរស់នៅដោយសាររកបានតិចជាងពីរដុល្លារក្នុងមួយថ្ងៃ ចំនួនប្រជាជនមានអាយុតិចជាង១៥ឆ្នាំ អត្រានៃការប្រើប្រាស់ថាមពលអគ្គិសនី អាយុកាលមធ្យម និង ចំនួនជនភៀសខ្លួនរបស់ប្រទេសកម្ពុជា បង្ហាញនូវស្ថានភាពមួយដ៏គួរឲ្យព្រួយបារម្ភ ។ ជាបឋម ការវាយតម្លៃលើការអភិវឌ្ឍធនធានមនុស្សធ្វើការវាស់ស្ទង់ទៅលើ «មុខព្រួញទាំងបីនៃការអភិវឌ្ឍធនធានមនុស្សៈ អាយុវែងប្រកបដោយសុខភាព ចំណេះវិជ្ជា និងកម្រិតជីវភាពសមស្រប» ។ ពិន្ទុក្នុងការវាយតម្លៃលើការអភិវឌ្ឍធនធានមនុស្សរបស់កម្ពុជាគឺ០.៦អាចចាត់ទុកថាជាប្រទេស «អភិវឌ្ឍន៍កម្រិតមធ្យម» យោងតាមចំណាត់ថ្នាក់ធូររលុងរបស់អង្គការសហប្រជាជាតិ ។ ប្រទេសថៃនៅជិតខាងនេះស្ថិតនៅក្នុងចំណាត់ថ្នាក់តែមួយដែរ ថ្វីត្បិតតែមានពិន្ទុដល់ទៅ០.៧៨ ដែលខ្ពស់ជាងកម្ពុជាយ៉ាងគួរឲ្យកត់សម្គាល់ ។ មីយ៉ាន់ម៉ា (០.៥៨) មានចំណាត់ថ្នាក់ក្រោមកម្ពុជាបន្តិច រីឯ ឡាវ (០.៦) ខ្ពស់ជាងបន្តិច ។ ក្នុងសាកលលោក កម្ពុជាមានចំណាត់ថ្នាក់នៅក្នុងមួយភាគបួនក្រោមបំផុតក្នុងចំណោមប្រទេសដែលត្រូវបាន



សកម្មភាពលើកទំនប់ដីកប្រឡាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

អង្គការសហប្រជាជាតិទទួលស្គាល់ (លំដាប់ថ្នាក់លេខ១៣១) ។

ស្ថិតិផ្សេងៗទៀតបានបំភ្លឺកាន់តែច្បាស់អំពីការអភិវឌ្ឍនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលបូកបញ្ចូលទាំងព្រះរាជាណាចក្រកម្ពុជា ។ មានប្រជាជនកម្ពុជាលើសពីបីភាគបួនកំពុងរស់នៅដោយសាររកបានតិចជាងពីរដុល្លារក្នុងមួយថ្ងៃ ។ ផ្ទុយទៅវិញក្នុងប្រទេសថៃមានតែប្រជាជនមួយភាគបួនប៉ុណ្ណោះដែលកំពុងស្ថិតក្នុងជីវភាពក្រលំបាក ។ ក្នុងចំណោមប្រទេសទាំងនេះ កម្ពុជាមានប្រជាជនក្មេងជាងគេដោយក្នុងរាល់ប្រាំនាក់មានពីរនាក់មានអាយុតិចជាង ១៥ឆ្នាំ ។ ដោយឡែកនៅក្នុងប្រទេសថៃនិងមីយ៉ាន់ម៉ាវិញ ប្រជាជនអាយុមធ្យមខ្ពស់ជាងនេះឆ្ងាយណាស់ ដោយក្នុងរាល់ប្រាំនាក់នៃប្រជាជនថៃឬមីយ៉ាន់ម៉ា មានតែកុមារម្នាក់ប៉ុណ្ណោះ ។ យុវវ័យខ្មែរបានធ្វើឲ្យទំនាក់ទំនងគ្រួសារមានភាពតានតឹង ហើយរួមចំណែកបង្កឲ្យមានក្មេងអនាថាជាច្រើននៅរាជធានីភ្នំពេញនិង



កំណើននៃមុខរបរជួញដូរផ្លូវភេទកុមារ ។

ការប្រើប្រាស់ថាមពលអគ្គិសនីរបស់ប្រជាជនក៏អាចឆ្លុះបញ្ចាំងពីកម្រិតអភិវឌ្ឍន៍នៃប្រទេសមួយដែរ ។ ប្រៀបធៀបទៅនឹងប្រទេសថៃដែលប្រជាជនស្ទើរតែទាំងអស់មានថាមពលអគ្គិសនីប្រើប្រាស់ប្រជាជនកម្ពុជាមានតែ២០ភាគរយប៉ុណ្ណោះដែលមានចរន្តអគ្គិសនីប្រើប្រាស់ ។ ក្នុងខណៈពេលដែលមានប្រជាជនស្ទើរតែ១៩.៧ភាគរយតាំងទីលំនៅនៅទីប្រជុំជន ស្ថិតិបានបង្ហាញថាការប្រើប្រាស់អគ្គិសនីនៅជនបទមានកម្រិតតិចតួចបំផុត ។ ប្រទេសមីយ៉ាន់ម៉ាដែលនៅជិតនេះមានភាគរយនៃប្រជាជនប្រើប្រាស់អគ្គិសនីកាន់តែតិច គឺមានតែប្រហែល១១ភាគរយប៉ុណ្ណោះ ។ ភាពងងឹតដោយសារខ្វះអគ្គិសនីនេះជះឥទ្ធិពលយ៉ាងខ្លាំងដល់សកម្មភាពសំខាន់ជាច្រើនដូចជាកិច្ចការសាលារបស់កុមារជាដើម ។ លើសពីនេះទៀត សន្តិសុខរបស់ស្ត្រីក៏ទទួលរងការប៉ះពាល់ជាខ្លាំងដែរ ។

អាយុកាលមធ្យមរបស់ប្រទេសមួយអាចបង្ហាញពីកម្រិតអភិវឌ្ឍន៍នៃប្រទេសនោះក្នុងវិស័យសុខាភិបាល ។ ប្រជាជនកម្ពុជាសព្វថ្ងៃមានអាយុកាលមធ្យមទាបត្រឹមតែ៥៨ឆ្នាំប៉ុណ្ណោះ ប្រៀបធៀបនឹងប្រទេសថៃដែលមានអាយុកាលមធ្យមដល់ទៅ៦៩ឆ្នាំ ។ មីយ៉ាន់ម៉ានិងឡាវសុទ្ធតែមានអាយុកាលមធ្យមខ្ពស់ជាងកម្ពុជា នេះបង្ហាញថាប្រព័ន្ធសុខាភិបាលក្នុងកម្ពុជាត្រូវការពង្រឹងបន្ថែម ។

ចំនួនប្រជាជនដែលស្វែងរកសិទ្ធិជ្រកកោននៅបរទេសដោយមូលហេតុនយោបាយ សង្គមកិច្ច ឬសេដ្ឋកិច្ច ស្តែងឲ្យឃើញពីស្ថិរភាពក្នុងប្រទេស ។ ក្នុងចំណោមប្រទេសក្នុងអាស៊ីអាគ្នេយ៍ មីយ៉ាន់ម៉ាមានប្រជាជនច្រើនបំផុតភៀសខ្លួនចេញពីប្រទេសដោយសារតែអស្ថិរភាពក្នុងប្រទេសនាពេលថ្មីៗនេះដោយមានប្រជាជនប្រមាណ២០៣.០០០នាក់ចាកចេញពីប្រទេស ។ ប្រទេសឡាវមានចំនួនជនភៀសខ្លួនខ្ពស់បន្ទាប់ គឺចំនួន២៦.០០០នាក់ ។ រីឯប្រទេសកម្ពុជា ថ្វីត្បិតតែមិនច្រើនដូចប្រទេសខាងលើ តែនៅមានប្រជាជនប្រហែល១៨.០០០នាក់ធ្វើចំណាកស្រុក ភាគច្រើនទៅកាន់ប្រទេសថៃឬសហរដ្ឋអាមេរិក ។ មូលហេតុដែលបង្កើនចំនួនជនភៀសខ្លួននេះគឺអតីតកាលប្រល័យពូជសាសន៍នៃកម្ពុជា ។ បន្ទាប់ពីការបំផ្លិចបំផ្លាញរបស់ខ្មែរក្រហម ប្រទេសខ្លះដូចជាថៃ អាមេរិក និង កាណាដាបានទទួលយកជនដែលរួចរស់មានជីវិតពីអំពើប្រល័យពូជសាសន៍ឲ្យមករស់នៅក្នុងប្រទេសរបស់ខ្លួន ។ ហេតុដូចនេះ ប្រជាជនកម្ពុជាមួយចំនួនបានធ្វើចំណាកស្រុកដើម្បីជួបជុំញាតិសន្តានដែលបានធ្វើនិរប្រវេសន៍ ។ នៅឆ្នាំ២០០៤ ប្រទេសថៃទទួលយកជនភៀសខ្លួនប្រមាណ១៣៣.០០០នាក់ពីប្រទេសជិតខាងដែលមានវិបត្តិផ្ទៃក្នុង ។ ចំណែកប្រទេសអាមេរិកវិញ ក៏បានអនុញ្ញាតប្រជាជន៨៤៤.០០០នាក់ឲ្យមករស់នៅក្នុង

ប្រទេសរបស់ខ្លួន ។ ការវិភាគជាទូទៅទៅលើប្រជាសាស្ត្រកម្ពុជាបានបញ្ចប់ត្រឹមនេះ ។ ជាបន្តទៅទៀត យើងនឹងផ្តោតអារម្មណ៍ទៅលើស្ថិតិនៃស្ត្រីខ្មែរវិញ ។

## ស្ត្រីខ្មែរ

ខ្ញុំពឹងផ្អែកទៅលើកត្តាចង្អុលបង្ហាញនៃការវាយតម្លៃលើការអភិវឌ្ឍធនធានមនុស្សមួយចំនួនដូចជា កម្រិតនៃការលើកតម្កើងឋានៈស្ត្រី រួមទាំងធនធានសេដ្ឋកិច្ច សង្គមកិច្ច អប់រំ នយោបាយ និងសម្ភារៈ ដើម្បីបង្ហាញពីឋានៈស្ត្រីខ្មែរនៅក្នុងសង្គម ។ យោងទៅតាមគេហទំព័ររបស់ការវាយតម្លៃនៃការអភិវឌ្ឍធនធានមុស្សកម្រិតនៃការលើកតម្កើងឋានៈស្ត្រី «គឺជាការគួបផ្សំនៃរង្វាស់ដើម្បីបង្ហាញអំពីភាពមិនស្មើគ្នារវាងភេទទាំងពីរតាមរយៈវិស័យបីសំខាន់ៗរួមមានកម្រិតនៃការចូលរួមរបស់ស្ត្រីក្នុងនយោបាយនិងការកំណត់គោលនយោបាយ ការចូលរួមក្នុងវិស័យសេដ្ឋកិច្ចនិងសិទ្ធិក្នុងការសម្រេចចិត្ត រួមទាំងសិទ្ធិដែលទទួលបានដោយសារធនធានសេដ្ឋកិច្ច» ។ ប្រទេសកម្ពុជាទទួលបានពិន្ទុទាបក្នុងរង្វាស់នេះ(០.៣៨) ប្រៀបធៀមទៅនឹងប្រទេសថៃដែលនៅក្បែរខាង(០.៤៧) ។ ប៉ុន្តែពិន្ទុប្រទេសទាំងពីរនេះមានលក្ខណៈទាបយ៉ាងគួរឲ្យកត់សម្គាល់ពេលដែលធៀបទៅនឹងសហរដ្ឋអាមេរិក (០.៧៦) ។ ដើម្បីកត់ត្រាអំពីស្ថានភាពរបស់ស្ត្រីខ្មែរឲ្យកាន់តែប្រសើរ គេចាប់អារម្មណ៍ទៅលើពិន្ទុរង្វាស់បង្ហាញកាន់តែច្រើន ហើយធ្វើការប្រៀបធៀបជាមួយប្រទេសជិតខាង ។

នៅក្នុងទីផ្សារការងារ ស្ត្រីខ្មែរត្រូវបានបង្ហាញថាមានការចូលរួមយ៉ាងសំខាន់ក្នុងសកម្មភាពសេដ្ឋកិច្ច ហើយទទួលបានប្រាក់ចំណូលសមរម្យដូចបុរសដែរ ។ ផលធៀបរវាងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ស្ត្រីនិងបុរសស្មើនិង៩៣ភាគរយ ។ ផលធៀបខ្ពស់នេះអាចបណ្តាលមកពីកម្លាំងជំរុញនៃភាពក្រីក្រ ។ ដោយសារមានប្រជាជនភាគច្រើនរស់នៅដោយសាររកបានតិចជាងពីរដុល្លារក្នុងមួយថ្ងៃ ស្ត្រីដែលមានកាយសម្បទាពេញលេញទាំងអស់សុទ្ធតែចូលធ្វើការដើម្បីទ្រទ្រង់ជីវភាពគ្រួសារ ។ លើសពីនេះទៅទៀត ការងារភាគច្រើនស្ថិតក្នុងវិស័យកសិកម្ម ។ ក្នុងប្រទេសថៃដែលនៅជិតខាងមានតែស្ត្រី៨១ភាគរយប៉ុណ្ណោះដែលកំពុងបម្រើការងារធៀបទៅនឹងបុរស ។ នេះបង្ហាញពីកង្វះខាតភាពចាំបាច់ក្នុងប្រទេស និងការផ្លាស់ប្តូរពីកម្លាំងពលកម្មពីវិស័យកសិកម្មទៅកាន់វិស័យឧស្សាហកម្មសេវាកម្ម ។ ស្ត្រីនៅសហរដ្ឋអាមេរិកមានកម្រិតចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចប្រហាក់ប្រហែលនឹងប្រទេសថៃនេះបញ្ជាក់ថាសេដ្ឋកិច្ចដែលកំពុងតែធ្លាក់ចុះនឹងបណ្តាលឲ្យចំនួនស្ត្រីដែលចូលធ្វើការងារថយចុះដែរ ។ ខុសគ្នាទៅនឹងស្ត្រីនៅអាមេរិកនិងថៃ ប្រាក់ចំណូលសរុបក្នុងប្រទេសរបស់ស្ត្រីខ្មែរបានដល់ទៅបីភាគបួននៃចំណូលសរុបរបស់បុរស ។ ចំណែកនៅក្នុងសហរដ្ឋអាមេរិកនិងប្រទេសថៃ ស្ត្រីបានជួយបង្កើនចំណូលតិចតួចប៉ុណ្ណោះសម្រាប់គ្រួសារ ។

រីឯក្នុងវិស័យសង្គមកិច្ច ការប្រើប្រាស់វិធានការពន្យារកំណើតបង្ហាញពីលទ្ធភាពដែលស្ត្រីអាចគ្រប់គ្រងពេលវេលាដែលមានកូន និងទំហំគ្រួសាររបស់ពួកគេ ។ រង្វាស់បង្ហាញនេះអាចបង្ហាញទាំងចំណេះដឹងអំពីផ្លូវភេទ ឥទ្ធិពលរបស់គំនិតផែនការគ្រួសារមកពីបស្ចិមប្រទេស រួមទាំងសិទ្ធិស្ត្រីជាម្ចាស់ការលើរាងកាយរបស់ខ្លួន ។ មានតែមួយភាគបួននៃស្ត្រីខ្មែរដែលរៀបការរួចនិងស្ថិតក្នុងវ័យអាចមានកូនប៉ុណ្ណោះដែលបានប្រើប្រាស់វិធីពន្យារកំណើត ។ ប្រទេសឡាវនិងមីយ៉ានម៉ាក៏មានរបាយការណ៍ប្រហាក់ប្រហែលគ្នាដែរ ។ ស្ថិតិនេះបង្ហាញអំពីកង្វះខាតចំណេះដឹងផ្លូវភេទ ការមិនចាប់អារម្មណ៍ទៅលើផែនការគ្រួសារបែបអឺរ៉ុប និងការប្រើប្រាស់វិធីសាស្ត្របុរាណដើម្បីពន្យារកំណើត ។ លើសពីនេះទៅទៀតទិន្នន័យនេះបង្ហាញថាស្ត្រីខ្មែរមិនមានម្ចាស់ការលើខ្លួនឯងក្នុងការមានកូននោះទេ ។ ស្ត្រីដែលមានផ្ទៃពោះត្រូវបង្ខំចិត្តបោះបង់ក្តីសង្ឃឹមបន្តការសិក្សាឬស្វែងរកការងារក្រៅផ្ទះ ។ ផ្ទុយទៅវិញស្ត្រីថៃច្រើនលើសលុបប្រហែល៨០ភាគរយបានប្រើប្រាស់ស្រោមអនាម័យ ។ កម្រិតប្រើប្រាស់វិធានការពន្យារកំណើតខ្ពស់នេះបានបង្ហាញអំពីឥទ្ធិពលនៃឧស្សាហកម្មផ្លូវភេទនិងការទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ក្នុងប្រទេសថៃ ។

ប្រទេសថៃនិងកម្ពុជាមិនត្រឹមតែទាក់ទាញភ្ញៀវទេសចរណ៍ដោយសម្រស់ធម្មជាតិប៉ុណ្ណោះទេ តែដោយសារការលួតលាស់នៃមុខរបរជួញដូរផ្លូវភេទផងដែរ ។ ការរួមភេទមិនមានសុវត្ថិភាពនៅតាមផ្ទះបនបណ្តាលឲ្យជំងឺអេដស៍ឆ្លងទៅកាន់ភ្ញៀវបុរសដែលជាប្តីរួចទៅកាន់ប្រពន្ធ ហើយចុងក្រោយទៅកាន់ទារកដែលមិន

ទាន់ចាប់កំណើតដ៏គួរឲ្យអាណិតទៀត ។ ដូចនេះ អង្គការក្រៅរដ្ឋាភិបាលនៅប្រទេសថៃកំពុងអប់រំស្ត្រីរកស៊ីផ្លូវភេទនិងមហាជនទូទៅអំពីការរួមផ្លូវភេទដោយមានសុវត្ថិភាពនិងវិធានការផែនការគ្រួសារ ។ ក្នុងខណៈពេលធ្វើការផ្តួចផ្តើមទាំងនេះមានភាពជោគជ័យក្នុងប្រទេសថៃ គប្បីមានកិច្ចខំប្រឹងប្រែងបន្ថែមនៅកម្ពុជាដើម្បីអប់រំស្ត្រីខ្មែរនិងដៃគូអំពីការប្រើប្រាស់ស្រោមអនាម័យនិងវិធីពន្យារកំណើតដទៃទៀត ។

វិស័យអប់រំជាមូលដ្ឋាននៃការលើកតម្កើងឋានៈស្ត្រីក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ ផលធៀបអក្ខរភាពនៃមនុស្សពេញវ័យរវាងបុរសនិងស្ត្រីគឺជាវិធីសម្រាប់ប្រៀបធៀបកម្រិតអប់រំរបស់ស្ត្រីនិងបុរសនៅក្នុងប្រទេសមួយ ។ ពិន្ទុទាបបង្ហាញថាស្ត្រីមិនសូវមានឱកាសរៀនចេះអាននិងសសេរដូចបុរសទេ ។ ផលធៀបអក្ខរភាពនៃមនុស្សពេញវ័យរវាងបុរសនិងស្ត្រី នៅកម្ពុជាគឺ ០.៧៦ នេះបង្ហាញថាបុរសនៅកម្ពុជាទទួលបានឱកាសអប់រំច្រើនជាងស្ត្រីបំផុតធៀបទៅនឹងប្រទេសក្នុងតំបន់ ។

ការសន្និដ្ឋាននេះទទួលបានការគាំទ្របន្ថែមពីស្ថិតិចំនួនយុវនារីដែលចូលរៀនក្នុងមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា ។ ធៀបទៅនឹងប្រទេសជិតខាងកម្ពុជាមានចំនួនសិស្សស្រីក្នុងវិទ្យាល័យនិងសាកលវិទ្យាល័យតិចបំផុត ។ មានតែសិស្សវិទ្យាល័យមួយភាគបួនក្នុងកម្ពុជាដែលជាយុវនារី ។ ចំណែកឯប្រទេសឡាវ និង មីយ៉ាន់ម៉ា មាននារីដល់ទៅ៤០ភាគរយដែលបានចូលរៀននៅក្នុងវិទ្យាល័យ ។ រីឯប្រទេសថៃវិញគឺជាប្រទេសដែលមានអត្រាចូលរៀនរបស់សិស្សស្រីខ្ពស់បំផុត ។ មានដល់ទៅជិតបីភាគបួននៃយុវនារីថៃបន្តការសិក្សានៅវិទ្យាល័យ ។ ទោះជាយ៉ាងនេះក្តីស្ត្រីដែលបានបន្តការសិក្សារហូតដល់សាកលវិទ្យាល័យមានភាគរយតិចក្នុងបណ្តាប្រទេសទាំងអស់ខាងលើ ។ ជាក់ស្តែង មានតែចំនួនពាក់កណ្តាលនៃនារីថៃប៉ុណ្ណោះដែលបានរៀនបន្តដល់កម្រិតឧត្តមសិក្សា ។ ចំណែកឯក្នុងប្រទេសកម្ពុជាវិញ មានត្រឹមតែនារីពីរភាគរយប៉ុណ្ណោះដែលមានសំណាងទទួលបានកម្រិតអប់រំថ្នាក់ឧត្តមសិក្សា ។ ក្នុងក្រសែភ្នែកប្រជាពលរដ្ឋអាមេរិកដែលគិតថាការអប់រំជារឿងមួយសាមញ្ញ ស្ថិតិនេះធ្វើឲ្យពួកគេភ្ញាក់ផ្អើលជាខ្លាំង ។

បន្ទាប់ពីនេះទៀត ឯកសារនេះនឹងផ្តោតទៅលើលក្ខខណ្ឌធនធានសម្ភារៈ ភាពទូទៅនៃការប្រើប្រាស់ទឹកស្អាត និងសំឡេងស្ត្រីក្នុងនយោបាយនៅប្រទេសកម្ពុជា ។ ក្នុងប្រវត្តិសាស្ត្រស្ត្រីខ្មែរមានតួនាទីជាកសិករខ្លួនទីពឹងខ្លួន និង ជាមាតានេះ បណ្តាលឲ្យពួកគាត់ទទួលឥទ្ធិពលយ៉ាងខ្លាំងដោយសារភូមិសាស្ត្រ ។ ការសិក្សាស្រាវជ្រាវក៏បានបង្ហាញផងដែរថាស្ត្រីខ្មែរទទួលឥទ្ធិពលយ៉ាងគួរឲ្យកត់សម្គាល់ដោយទីតាំងនៃប្រភពទឹក និងគុណភាពនៃទឹកនៅទីនោះ ព្រោះស្ត្រីជាអ្នកទទួលបន្ទុកក្នុងការផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារ និងថែរក្សាកូនដែលមានជំងឺ ។ ហេតុដូចនេះ ប្រសិនបើមានប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ ស្ត្រីនឹងមានសេរីភាពនិងពេលវេលាកាន់តែច្រើនសម្រាប់បន្តការសិក្សានិងស្វែងរកការងារក្រៅផ្ទះ ។

ក្នុងចំណោមប្រទេសអាស៊ីអាគ្នេយ៍ដែលបានសិក្សាខាងលើ ប្រទេសកម្ពុជាជាប្រទេសដែលមានទឹកស្អាតប្រើប្រាស់តិចបំផុត ។ ចំណែកឯប្រទេសថៃដែលនៅជិតខាងប្រជាជនទាំងអស់សុទ្ធតែមានទឹកស្អាតប្រើប្រាស់ ។ ដោយសារមូលហេតុខាងលើ ពេលដែលកូនមានជំងឺដោយសារទឹកមិនស្អាត ស្ត្រីខ្មែរត្រូវបង្ខំចិត្តបោះបង់ឱកាសសម្រាប់កិច្ចការផ្សេងៗដើម្បីថែទាំកូនរហូតដល់ជាសះស្បើយវិញ ។ នេះអាចពន្យល់មូលហេតុមួយចំណែកដែលបណ្តាលឲ្យស្ត្រីខ្មែរមិនបានបន្តការសិក្សា ។

ការទាមទារសិទ្ធិនារីដែលមានការផ្តួចផ្តើមដោយរដ្ឋាភិបាលមានប្រសិទ្ធភាពបំផុត ។ ប៉ុន្តែ នៅប្រទេសកម្ពុជាក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនសំឡេងនយោបាយស្ត្រីមានកម្រិតជាខ្លាំង ។ លោក ភីធី អេស់ហៀល និង លោក លី ហេងថាយ បានកត់សម្គាល់ឃើញថា រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាមានការណែនាំជាក់លាក់មួយចំនួនអំពីសិទ្ធិនារី ។ ទោះជាយ៉ាងនេះក្តី អ្នកនយោបាយមិនសូវយកចិត្តទុកដាក់លើបញ្ហាជាច្រើនដូចជា អំពើហិង្សាក្នុងគ្រួសារ ការចាប់រំលោភ និង ទេសចរណ៍ផ្លូវភេទ ។ ដោយសារក្នុងជួររដ្ឋាភិបាលមានបុរសដល់ទៅ៩៣ភាគរយ ស្ត្រីមិនមានសំឡេងនយោបាយគ្រប់គ្រាន់ដើម្បីកែប្រែស្ថានភាពលំបាករបស់ពួកគេឲ្យមានប្រសិទ្ធភាពឡើយ ។ ចំណែកនៅសហរដ្ឋអាមេរិកជាប្រទេសដែលឲ្យតម្លៃទៅលើភាពស្មើគ្នាជាងអ្វីៗទាំងអស់មានស្ត្រីត្រឹមតែ១៨ភាគរយប៉ុណ្ណោះដែលបម្រើក្នុងជួររដ្ឋាភិបាល ។

បច្ចុប្បន្ន មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួនកំពុងរួមចំណែកជួយលើកកម្ពស់សិទ្ធិនារី និងព្យាយាមស្វែងរកសំឡេងគាំទ្រក្នុងរដ្ឋាភិបាល តែពួកគេជួបប្រទះនឹងការលំបាកក្នុងរបបសព្វថ្ងៃដែលគ្រប់គ្រងដោយបុរសស្ទើរតែទាំងអស់ ។

## ស្ត្រីខ្មែរ និង ការអភិវឌ្ឍ

ស្ថានភាពប្រទេសកម្ពុជាដែលស្ថិតក្នុងលំដាប់ប្រទេស «អភិវឌ្ឍន៍កម្រិតមធ្យម» បង្កជាមជ្ឈដ្ឋានមិនអំណោយផលដល់ស្ត្រីខ្មែរ ។ ដំណើរការប្រកបដោយជោគជ័យរបស់ប្រព័ន្ធមូលធននិយមទូទាំងសាកលលោកតម្រូវឲ្យមានការស្វែងរកកម្លាំងពលកម្មដែលមានតម្លៃទាបបំផុត ។ ក្រុមហ៊ុនជាច្រើនបានចាប់អារម្មណ៍ឃើញថា ស្ត្រីនិងកុមារនៅកម្ពុជាអាចធ្វើការដើម្បីប្រាក់កម្រៃតិចបំផុត នេះបណ្តាលឲ្យប្រទេសកម្ពុជាដែលមានប្រជាជនភាគច្រើនរស់នៅដោយសាររកបានតិចជាងពីរដុល្លារ បានក្លាយជាទីតាំងចម្បងរបស់ក្រុមហ៊ុនអន្តរជាតិទាំងនេះ ។ អ្នកស្រី រ៉ាប្លឹមបឹគ បានផ្តោតអារម្មណ៍ទៅលើ «ធម្មជាតិរបស់យេនឌ័រនៃកំណែទម្រង់សេដ្ឋកិច្ច» ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ គាត់បានលើកយោបល់ថា «លទ្ធភាពស្ត្រីក្នុងការគ្រប់គ្រងធនធានសេដ្ឋកិច្ច ជាពិសេសទៅលើប្រាក់ចំណូលគឺជាកត្តាចាំបាច់បំផុត»សម្រាប់បង្ហាញអំពីសមភាពរវាងភេទទាំងពីរ ។ គាត់បានបន្តទៀតថា ការគ្រប់គ្រងនេះអាចផ្តល់ជូនស្ត្រីនូវជំនឿចិត្តខ្ពស់លើខ្លួនឯង សិទ្ធិចូលរួមក្នុងការសម្រេចចិត្តក្នុងគ្រួសារ និងការគ្រប់គ្រងលើ «ជម្រើសក្នុងជីវិត» ដូចជាការរៀបការនិងការលែងលះ ។ ដូច្នេះ ថ្វីត្បិតតែស្ត្រីកម្ពុជាចូលរួមក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារមួយផ្នែកធំក៏ដោយក៏នេះមិនតំណាងថាពួកគេមានម្ចាស់ការលើខ្លួនឯងនោះដែរ ។

ស្ត្រីខ្មែរបានក្លាយជាផ្នែកមួយនៃ «ការព្រមព្រៀងក្រោមការគ្រប់គ្រងរបស់បុរស» ដោយបង្ខំ ។ ប្លឹមបឹគ បានប្រើពាក្យនេះដើម្បីពណ៌នាសភាពដែលស្ត្រីបោះបង់សេរីភាពដោយជ្រើសរើសឋានៈក្រោមបុរសដើម្បីទទួលបានការគាំពារ ។ ហេតុដូចនេះ ស្ត្រីខុសប្លែកពីបុរសក្នុងជម្រើសសេដ្ឋកិច្ចនិងដែនការគ្រួសារ ។ លើសពីនេះ ផ្នត់គំនិតដែលសន្មតថាបុរសជាអ្នកផ្គត់ផ្គង់គ្រួសារជាចម្បងគឺជាដើមកំណើតនៃការព្រមព្រៀងក្រោមការគ្រប់គ្រងរបស់បុរសនេះ ។ នៅប្រទេសកម្ពុជាក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតគ្រួសារដែលគ្មានមេគ្រួសារជាបុរសតែងតែជាគ្រួសារដែលក្រីក្របំផុត ។ ការគោរពលើអំណាចបុរសនិងកង្វះខាតប្រាក់ចំណូលនេះក៏រួមចំណែកក្នុងការដុះដាលនៃការជួញដូរផ្លូវភេទក្នុងប្រទេស ។

ក្នុងខណៈពេលដែលការជួញដូរផ្លូវភេទស្ទើរតែត្រូវទទួលស្គាល់ជាសាធារណៈ កម្រិតនៃពេស្យាចារនិងការជួញដូរស្ត្រីភេទនៅតែបន្តកើនឡើង ។ មុខរបរនេះលូតលាស់ដោយសារភាពក្រីក្រ ។ ឪពុកបានបញ្ជូនកូនស្រីឲ្យទៅធ្វើការដោយចាញ់ការបោកបញ្ឆោតថាកូននឹងទទួលបានសុវត្ថិភាព ។ មុខរបរនេះមិនត្រឹមតែនាំមកនូវការប៉ះពាល់ទៅលើឪពុកម្តាយស្ត្រីទាំងនេះទេ ថែមទាំងជះឥទ្ធិពលទៅលើបុរស ស្ត្រី និងកុមារដែលទទួលការចម្លងមេរោគអេដស៍ផង ។ លោក ភីធី អេស៍ហៀល និង លោក លី ហេងថាយ បានបង្ហាញថារៀងរាល់ថ្ងៃនៅប្រទេសកម្ពុជាមានអ្នកផ្ទុកមេរោគអេដស៍ថ្មីដល់ទៅជិត២០ នាក់ ។ ដោយសារតែ ៩៧ភាគរយនៃការឆ្លងមេរោគអេដស៍កើតឡើងតាមរយៈការរួមភេទ ស្ត្រីនិងទារកដែលមិនទាន់ចាប់កំណើតជាច្រើនកំពុងប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺនេះដែរ ។ ហេតុដោយមិនមានថ្នាំព្យាបាល ឪពុកម្តាយជាច្រើនត្រូវបាត់បង់ជីវិតដោយសារជំងឺនេះ ហើយបន្សល់ទុកកូនដែលនៅក្មេងខ្ចី ។ ការរីករាលដាលរបស់ជំងឺអេដស៍ ប្រហែលជាមូលហេតុមួយដែលចូលរួមបណ្តាលឲ្យប្រជាជនភាគច្រើននៃប្រទេសកម្ពុជាស្ថិតក្រោមអាយុ១៥ឆ្នាំ ។ ដូចនេះគប្បីមានការអប់រំអំពីជំងឺឆ្លងនេះដល់ស្ត្រីនៅកម្ពុជា ។

បន្ថែមទៅលើនេះទៅទៀត មុខរបររកស៊ីផ្លូវភេទបានបង្ហាញនូវទិដ្ឋភាពទូទៅនៅក្នុងប្រទេស ។ ការចាត់ទុកស្ត្រីជាវត្ថុសម្រាប់ជួញដូរបង្ហាញអំពីកង្វះខាតមុខរបរចិញ្ចឹមជីវិតផ្សេងទៀត ។ ការវិភាគនេះបញ្ជាក់យ៉ាងច្បាស់ថាទោះបីមានជំនួយពីអង្គការសហប្រជាជាតិក្នុងវិស័យមួយចំនួន ប្រទេសកម្ពុជាត្រូវការដំណោះស្រាយលើបញ្ហាជាច្រើនទៀត ជាពិសេសក្នុងបញ្ហាយេនឌ័រ ។ ឋានៈស្ត្រីក្នុងកត្តាសេដ្ឋកិច្ច សង្គម អប់រំ សម្ភារៈ និង នយោបាយ សុទ្ធតែត្រូវការលើកស្ទួយបន្ថែម ដូចនេះការអភិវឌ្ឍរបស់កម្ពុជាត្រូវបូកបញ្ចូលទាំងស្ត្រីផងដែរ ។

**ម៉ាក់ អាដាម**

# ក្លាយជាអ្នកទោសនៅកោះមុខឈ្លាង

នៅសម័យបដិវត្តន៍របស់ខ្មែរក្រហម ខ្ញុំបានប្តូរឈ្មោះពី ទា គិមឆែ ទៅជា ឡុង ឆែម ។ ក្រោយមកទៀត បានប្តូរមកឈ្មោះ ទា ឡុង វិញ ។ ពីឆ្នាំ១៩៧៥-១៩៧៧ ខ្ញុំជាអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសជាច្រើនដែលជាប់ឃុំឃាំងនៅលើ «កោះមុខឈ្លាង» ដែលមានព្រៃឫស្សី ចម្ការដំណាំ និងអូរព័ទ្ធជុំវិញ ។ នៅលើកោះនេះមានអគារចំនួន៣ខ្នងមួយសម្រាប់ដាក់អ្នកទោស ចំណែកអគារពីរទៀតសម្រាប់សួរចម្លើយនិងសម្រាប់កងយោធាខ្មែរក្រហមស្នាក់នៅព្រមទាំងមានស្ពានមួយសម្រាប់ឆ្លងទៅវត្តចែងទៀតផង ។

ឆ្នាំ១៩៧៥ គ្រួសារខ្ញុំត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅភូមិចម្ការស្រូវ ក្រោយមកអង្គការក៏ចាប់បញ្ជូនឲ្យទៅរស់នៅវត្តចែងដែលស្ថិតនៅក្នុងឃុំអូរដំបងតំបន់៤ទីរួមខេត្តបាត់ដំបងវិញ ។ គ្រួសារភាគច្រើនដែលរស់ភូមិចម្ការស្រូវកម្រនឹងមានឱកាសរត់ចេញទៅតំបន់ផ្សេងណាស់ ព្រោះមានការយាមការពារយ៉ាងតឹងរ៉ឹងពីខ្មែរក្រហម ។

រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៦ ខ្ញុំត្រូវអង្គការចាប់ខ្លួនយកទៅដាក់ក្នុងមន្ទីរឃុំឃាំងនៅកោះមុខឈ្លាងដោយមិនដឹងពីមូលហេតុបន្ទាប់ពីខ្ញុំធ្វើដំណើរត្រឡប់មកពីភូមិអូរស្រឡៅវិញ ។ ទៅដល់កន្លែងឃុំឃាំងខ្ញុំបានឃើញអ្នកទោសប្រមាណជា១៥នាក់ផ្សេងទៀត ដែលត្រូវចាប់ខ្លួនពីកន្លែងផ្សេងបញ្ជូនមកស្របពេលជាមួយគ្នាដែរ ។ ខ្ញុំនិងអ្នកទោសទាំងអស់នោះត្រូវកងការពារខ្មែរក្រហមយកទៅដាក់ក្នុងអគារមួយ រួចដាក់ខ្នោះជើង និងឲ្យដេកតម្រៀបជាជួរជាមួយអ្នកទោសដទៃទៀតក្នុងអគារនោះ ។ អ្នកទោសទាំងអស់សរុបមានប្រមាណជា៣០-៤០នាក់រួមមានក្មេងចាស់ និងស្រី-ប្រុសនៅលាយឡំគ្នា ។ អ្នកទោសមានសភាពស្គមស្គាំងទឹកមុខស្លេកស្លាំងដោយសារពុំមានអាហារបរិភោគគ្រប់គ្រាន់និងភាពភ័យខ្លាច ។ ខ្ញុំឃើញអ្នកទោសស្ត្រីម្នាក់អាយុប្រហែលជាង២០ឆ្នាំ មានសភាពទ្រុឌទ្រោមយ៉ាងខ្លាំង ជើងម្ខាងជាប់ខ្នោះកំពុងអង្គុយបំបៅដោះទារកដែលទើបមានអាយុប្រហែល៨ខែ ប៉ុន្តែដោយសារគាត់ពុំមានទឹកដោះគ្រប់គ្រាន់ធ្វើឲ្យទារកនោះយំមិនឈប់សោះ ។ រៀងរាល់ថ្ងៃនៅពេលជិតភ្លឺ សំឡេងកញ្ចែបានបន្លឺឡើងជាមួយគ្នានោះមានយោធាពីរនាក់មកចាក់សោខ្នោះជើងអ្នកទោសឲ្យចេញទៅធ្វើការដោយមានកងយោធាស្ពាយកាំភ្លើងអាកា៤៧យាមការពារផង ។ ចំណែកអ្នកទោសដែលមានជំងឺមិនអាចទៅធ្វើការបាន ត្រូវកងយោធាទាំងនោះវាយធ្វើបាបនិងផ្តាច់របបម្ហូបអាហារ ។ អ្នកទោសទាំងអស់មានរបបបបររាវមួយវែកជាមួយនឹងអំបិលតែពីរបីគ្រាប់ប៉ុណ្ណោះ ។

ក្រោយពីធ្វើការចប់នៅពេលល្ងាច អ្នកទោសត្រូវបានកងការពារបណ្តើរចូលអគារឃុំឃាំងវិញ ។ នៅពេលនោះអ្នកទោសបានប្រវេប្រវាដណ្តើមយកខ្នោះឈើដែលមានទំហំធំដើម្បីកុំឲ្យកកិតជាមួយកជើងខ្លាំងពេក ទោះជាយ៉ាងនេះក្តី ក៏កជើងទាំងសងខាងរបស់ខ្ញុំនៅតែមានដំបៅនិង «បន្សល់ទុកស្លាកស្នាមដល់សព្វថ្ងៃនេះ» ។ រៀងរាល់ថ្ងៃមានអ្នកទោសផ្សេងៗត្រូវបានបញ្ជូនមកឃុំឃាំងបន្ថែម ចំណែកអ្នកទោសខ្លះ ត្រូវបានសម្លាប់ចោលតែម្តង ។ អ្នកទោសមួយចំនួនត្រូវបញ្ជូនបន្តយកទៅដាក់នៅកន្លែងឃុំឃាំងថ្មីក្នុងភូមិកាច់រទេះដែលសម្បូរដោយព្រៃឫស្សី ចម្ការអំពៅ និងចម្ការស្វាយ ។

ជារៀងរាល់យប់កងការពារបានចងអ្នកទោសចំនួន៥នាក់ម្តងបណ្តើរចេញពីអគារទៅវាយសួរចម្លើយ អ្នកទោសខ្លះទៀតបាត់ខ្លួន ចំណែកអ្នកទោសខ្លះ ដេកស្លាប់ដោយមានដំបៅនិងឈាមនៅកន្លែងឃុំឃាំងបន្ទាប់ពីត្រឡប់មកវិញ ។ ខ្ញុំតែងតែឮសំឡេងស្រែករបស់អ្នកទោសដោយការឈឺចាប់ សំឡេងយំខ្សឹកខ្សួល ។ នៅយប់មួយ ខ្ញុំត្រូវបានកងការពារដាក់បញ្ចូលទៅក្នុងខ្នោះឈើជាមួយអ្នកទោស៥នាក់ទៀត ស្រាប់តែពេលនោះមានឮសូរសំឡេងកញ្ចែផ្លុំស្រែកហៅជាបន្ទាន់កងការពារម្នាក់នោះ ក៏ប្រញាប់ប្រញាល់ចេញទៅខាងក្រៅ ដោយភ្លេចចាក់សោរនងខ្នោះ ។ អ្នកទោសឈ្មោះ ថ្វាន់ ជាអ្នកភូមិនៅវត្តចែង ខ្ញុំនិងអ្នកទោសពីរនាក់ទៀតបានពិគ្រោះយោបល់គ្នាដើម្បីរត់ចេញពីគុកនៅពេលយប់ងងឹត

ដោយឈ្មោះ ថ្វាន់ ជាអ្នកនាំផ្លូវ ។ ដោយសារត្រូវរង់ចាំយូរគួបផ្សំជាមួយការហេវហត់អស់កម្លាំង បន្ទាប់ពីធ្វើការនឿយហត់ពេលថ្ងៃផង ធ្វើឲ្យខ្ញុំលង់លក់ក្នុងដំណេកដោយមិនដឹងខ្លួន ។ នៅពេលព្រឹកស្រាប់តែឮសូរសំឡេងកញ្ចែទើបធ្វើឲ្យខ្ញុំភ្ញាក់ពីដំណេក កងការពារម្នាក់បានចូលមកបើកសោខ្នោះ ស្រាប់តែបាត់អ្នកទោស៣នាក់ ។ កង ការពារនោះបានវាយទាត់ធាក់ខ្ញុំ និងអ្នកទោសពីរនាក់ទៀត ។ នៅពេលថ្ងៃត្រង់ខ្ញុំឃើញកងយោធាបណ្តើរអ្នកទោសពីរនាក់ដែលបានរត់ចេញពីគុកត្រឡប់មកវិញ ប៉ុន្តែមិនឃើញឈ្មោះ ថ្វាន់ទេ ។ អ្នកទោសទាំងពីនាក់នោះ ត្រូវកងយោធាធ្វើទារុណទាត់ធាក់យ៉ាងសាហាវឃោរឃៅរួចយកចេញទៅបាត់ ។ មួយរយៈក្រោយមកអ្នកទោសនៅសល់ត្រឹមតែ១០-១៥នាក់ប៉ុណ្ណោះ ព្រោះខ្លះស្លាប់ដោយសារជំងឺ អត់អាហារ និងខ្លះទៀតត្រូវយកទៅសម្លាប់ ។ អ្នកទោសដែលនៅសល់សុទ្ធតែមានជំងឺ និងមានរូបរាងស្គមស្គាំង ហើយត្រូវប្រមូលផ្តុំឲ្យមកធ្វើការនៅជិតកន្លែងឃុំឃាំងវិញ ។ នៅថ្ងៃមួយខ្ញុំជាមួយអ្នកទោស៣-៤នាក់កំពុងបោចស្មៅក៏ឃើញយោធាខ្មែរក្រហមកំពុងអង្គុយស៊ីអំពៅ ប៉ុន្តែដោយការស្រេកឃ្លានខ្ញុំបានរើសយកកាកអំពៅដែលគេបោះចោលមកជញ្ជក់ ។ ដោយសារពុំមានអាហារបរិភោគគ្រប់គ្រាន់បានធ្វើឲ្យខ្ញុំកើតជំងឺហើម និងជំងឺស្ពឹកដងខ្លួន ។ នៅថ្ងៃមួយបន្ទាប់ពីធ្វើការងាររួចនៅម៉ោង៥-៦ល្ងាចអ្នកទោសមួយចំនួនបានដើរទៅមុខបាត់អស់ចោលខ្ញុំឲ្យនៅតែម្នាក់ឯង ។នៅពេលនោះស្រាប់តែមានយោធាម្នាក់ដើរស្រែកច្រៀងចម្រៀងបដិវត្តន៍នៅក្បែរនោះធ្វើឲ្យខ្ញុំភ័យស្ទន់ស្ទារួចរអិលដួល ប៉ុន្តែខ្ញុំមិនអាចងើបដើរបានទេ ។ នៅពេលមកដល់កន្លែងខ្ញុំដួល យោធានោះបានទាត់ខ្ញុំមួយជើង ហើយស្រែកគំរាមថា «អ្ហែង ចង់ងាប់ណាស់ឬ» រួចក៏ដើរហួសចោលខ្ញុំបាត់ទៅ ។ ខ្ញុំខំប្រឹងលូននិងងើបដើររហូតដល់កន្លែងរោងបាយនៅពេលយប់ ។ នៅម៉ោង៨ព្រឹកអ្នកទោសទាំងអស់ត្រូវបានដោះខ្នោះចេញហើយឲ្យមកអង្គុយជុំគ្នានៅមុខអគារឃុំឃាំង ។ ខ្ញុំឃើញកម្មាភិបាលខ្មែរក្រហមស្លៀកសម្លៀកបំពាក់ខោអាវខ្មៅថ្មីៗ ខ្លះអង្គុយ ខ្លះឈរ បន្ទាប់មកយោធាម្នាក់បានកាន់បញ្ជីហៅឈ្មោះអ្នកទោសឈើពីរកំណាត់ដែលធ្វើជាឈើច្រត់ទប់ខ្លួន កុំឲ្យដួលរួចដើរសំដៅទៅផ្ទះវិញ ។ នៅមុខផ្ទះខ្ញុំបានឃើញម្តាយខ្ញុំដែលមានរូបកាយស្គមស្គាំងស្លេកស្លាំងអង្គុយកាន់កញ្ច្រែងបេះប៉េងប៉ោះ ត្រសក់ ត្រប់ ។ នៅពេលក្រឡេកឃើញខ្ញុំ ម្តាយខ្ញុំបានឈរទ្រឹង ហើយកញ្ច្រែងបន្លែបានធ្លាក់ពីដៃរបស់គាត់ដោយមិនដឹងខ្លួនជាមួយទឹកភ្នែកយំខ្សឹកខ្សួល ។ នៅ ពេលនោះប្អូនប្រុសរបស់ខ្ញុំឈ្មោះ សុខា អាយុ៩ឆ្នាំពិការជើងទាំងពីរបានវារមកជិតរួចស្រែកហៅខ្ញុំឲ្យប្រញាប់ចូលក្នុងផ្ទះ ព្រោះខ្លាចកងឈ្លបខ្មែរក្រហមឃើញ ។ ម្តាយខ្ញុំបានដាំទឹកក្តៅអ៊ុនៗលាយជាមួយស្លឹកអម្ពិលយកមកលាងដំបៅនៅលើខ្លួនខ្ញុំដោយសារកងការពារគុកយកខ្សែតីវាយ រួចយកសម្លៀកបំពាក់មកឲ្យខ្ញុំផ្លាស់ប្តូរ ។ ចំណែកប្អូនប្រុសខ្ញុំ បានវាររើសកួរស្រូវរហូតទៀបភ្លឺបានស្រូវប្រហែលកន្ទះកំប៉ុងទើបត្រឡប់មកផ្ទះវិញ ។ ម្តាយខ្ញុំបានយកស្រូវនោះទៅលីង រួចបុកឲ្យម៉ត់រួចឲ្យហូបទាំងអស់ ។ រយៈពេល៤ថ្ងៃក្រោយមកជំងឺហើមរបស់ខ្ញុំបានស្រកវិញ ប៉ុន្តែខ្ញុំគ្មានកម្លាំងអាចងើបឈរដើរដោយគ្មានឈើច្រត់បានទេ ។ ក្រោយមក ខ្ញុំក៏សម្រេចចិត្តចាកចេញទៅនៅភូមិអូរខ្ជាយ ឃុំអូរដំបង តំបន់៣ ស្ថិតនៅចម្ងាយ២គីឡូម៉ែត្រពីផ្ទះម្តាយខ្ញុំ ។ ខ្ញុំដើរចូលសុំបាយអ្នកភូមិហូបហើយពេលយប់ខ្ញុំទៅដេកលើដំបូកនៅខាងក្រៅភូមិវិញព្រោះខ្លាចកងឈ្លបឃើញ ។ ពេលខ្លះដោយសារឃើញខ្ញុំស្លៀកសម្លៀកបំពាក់រហែកមានបំណះគ្រប់កន្លែង និងមានដំបៅពេញខ្លួន ព្រមទាំងដំណើរទ្រេតទ្រោតអ្នកភូមិក៏បានឲ្យពោត ចេក ដំឡូង អំពៅជាច្រើនមកដល់ខ្ញុំ ប៉ុន្តែក៏មានអ្នកភូមិខ្លះស្រែកបណ្តេញខ្ញុំចេញពីផ្ទះរបស់គេព្រមទាំងមានក្មេងៗយកដុំថ្មដេញតាមគប់ខ្ញុំមកចំក្បាលរបស់ខ្ញុំធ្វើឲ្យបែកចេញឈាមទៀតផង ។

ក្រោយមក មានអ្នកភូមិនៅសហករណ៍អូរខ្ជាយម្នាក់ឈ្មោះ អ៊ួង សារិទ្ធ និងប្រពន្ធឈ្មោះ រី បានយកខ្ញុំទៅជាមួយគាត់ ។ នៅទីនោះ ខ្ញុំបានរៀនធ្វើទឹកត្នោតនិងកូរស្ករត្នោតជាមួយគាត់រហូតចេះស្ទាត់អាចធ្វើដោយខ្លួនឯងបាន ។ នៅទីនោះដោយសារប្រធានសហករណ៍ឈ្មោះ ចន និង វន និងគណៈឃុំអូរដំបង ឈ្មោះ លី មិនសូវតឹងតែងនិងតែងតែមានការអនុគ្រោះទើបប្រជាជនក្មេងចាស់ប្រុស-ស្រី មានម្ហូបអាហារគ្រប់គ្រាន់ មាននាឡិកាពាក់ មានកង់ជិះ និងបានអនុញ្ញាតឲ្យខ្ញុំជិះកង់ទៅលេងចោលឈូង បោះអង្គញ់ ក្នុងពេលចូលឆ្នាំថ្មីទៀតផង ។ ទោះបីជាមានសេរីភាព និងបានហូបគ្រប់គ្រាន់យ៉ាងនេះក្តីក៏ ប្រជាជននៅឃុំក្នុងអូរដំបងនៅតែខិតខំប្រឹង

ប្រែងធ្វើស្រែចម្ការ និងបង្កបង្កើនផលបានយ៉ាងប្រសើរទៀតផង ។ ប៉ុន្តែមកដល់ដើមឆ្នាំ៧៨ នៅពេលដែលកម្មាភិបាលភូមិភាគនិរតីចូលមកគ្រប់គ្រង គាលី ព្រមទាំងគ្រួសារត្រូវផ្លាស់ចេញទៅនៅឃុំស្ទឹងវិញ ។

នៅពេលខ្ញុំរៀនឆ្នាំទី៣នៅសាកលវិទ្យាល័យម៉ូដេស្តូ សហរដ្ឋអាមេរិកខ្ញុំមានជំងឺ «សសៃប្រសាទ» ធ្វើឲ្យខ្ញុំបោះបង់ការសិក្សាមួយរយៈរហូតមកដល់ឆ្នាំ១៩៩៣ ទើបខ្ញុំអាចបញ្ចប់បរិញ្ញាប័ត្រ និងធ្វើជាគ្រូបង្រៀនផ្នែកគណិតវិទ្យា ។ ទោះបីរបបខ្មែរក្រហមដ៏ព្រៃផ្សៃបានកន្លងផុតទៅក្តី ប៉ុន្តែស្រមោលខ្មៅនៃការឈឺចាប់នៅតែតាមលងខ្ញុំជានិច្ចហើយខ្ញុំតែងតែមានអារម្មណ៍ភ្លូកភ្លាំងនិងភ័យខ្លាច ។ ខ្ញុំសម្រក់ទឹកភ្នែក នៅពេលខ្ញុំគិតទៅដល់គុកកោះមុខឈ្នាង ។ ខ្ញុំនៅតែមានចម្ងល់ថា តើហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមដែលសុទ្ធ តែជាបញ្ញវន្តស្នេហាជាតិដ៏ពិតប្រាកដ ប៉ុន្តែបែរជាសម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃទៅវិញ ។ **ឆា ឡុង**

# ដំណឹងស្វែងរកគ្រួសារ

ខ្ញុំបាទឈ្មោះ ស៊ុន ភី មានអាយុ៤៣ឆ្នាំ រស់នៅភូមិតាគង់ ឃុំណាតាវ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ មានឪពុកឈ្មោះ ស៊ុន ហ្វូ និង ម្តាយឈ្មោះ ធី ។ ខ្ញុំសូមប្រកាសសួររកបងប្អូន៦នាក់ ដែលបានបាត់ខ្លួននៅឆ្នាំ១៩៧៦ ១)បងប្រុស ស៊ុន ហ្វូង, បងស្រី ស៊ុន រិន, បងប្រុស ស៊ុន ពន្ទក, បងស្រី ស៊ុន នឿន, និង ប្អូនប្រុស ស៊ុន ថៃ និង ប្អូនស្រី ស៊ុន ថុល ។ នៅឆ្នាំ១៩៧៦ រយៈពេលពីរទៅបីថ្ងៃក្រោយការចាប់ខ្លួនឪពុករបស់ខ្ញុំ ខ្មែរក្រហមបានជម្លៀសគ្រួសាររបស់ខ្ញុំពីភ្នំពេញទៅព្រៃស ។ ចាប់តាំងពីថ្ងៃនោះមកគ្រួសាររបស់ខ្ញុំក៏បាត់ដំណឹងរហូត មិនដឹងថានៅរស់ឬក៏ស្លាប់ទេ ។

ប្រសិនបើបងប្អូនណាបានឃើញ ឬបានស្គាល់ សូមទាក់ទងមកអាសយដ្ឋានខាងលើ ឬតាមរយៈលេខ ទូរស័ព្ទ ០១២ ២៩ ០៨ ៨១ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា ។ សូមអរគុណ ។

# ដំណឹងស្វែងរកឪពុក

ខ្ញុំបាទឈ្មោះ ធៀម ជេដ្ឋា ហៅ សុទ្ធា រស់នៅភូមិពងពស់ ឃុំរោងដំរី ស្រុកបាភ្នំ ខេត្តព្រៃវែង ។ សូមសួររកឪពុកឈ្មោះ ធៀម ផុង ហៅ កុង មានស្រុកកំណើតនៅសង្កាត់ដងពែង ស្រុកកំពង់សោម ខេត្តកោះកុង ដែលបានបាត់ខ្លួនពីភូមិពងពស់ ឃុំរោងដំរី ស្រុកបាភ្នំ ខេត្តព្រៃវែង នៅដើមខែមេសា ឆ្នាំ១៩៧៧ ដោយសារអង្គការប្រាប់ថាទៅដឹកក្រណាត់ ។ ឪពុករបស់ខ្ញុំបាទជាអតីតគ្រូបង្រៀននៅសម័យសាធារណរដ្ឋខ្មែរ (លន់ នល់) ។ ឥឡូវនេះ ខ្ញុំមិនដឹងថា គាត់ស្លាប់ ឬរស់នៅកន្លែងណាទេ ។

ប្រសិនបើលោកឪពុកបានឃើញដំណឹង ឬញាតិមិត្តណាបានស្គាល់ឈ្មោះខាងលើនេះ សូមមេត្តាទំនាក់ទំនងតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជាតាមលេខទូរស័ព្ទ ០២៣ ២១១ ៨១៥ ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# ដំណឹងស្វែងរកប្អូនប្រុស

ខ្ញុំបាទឈ្មោះ ចិន សុំដល្លី ហៅ ចិន សំអាត រស់នៅភូមិស្តៅ ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង បច្ចុប្បន្នជានាយកវិទ្យាល័យកំចាយមារ ស្រុកកំចាយមារ ខេត្តព្រៃវែង ។ សូមសួររកបងប្អូនប្រុសចំនួនពីរនាក់ ១) ចិន សុធីរ ហៅ ចិន សំអុល និង ២) ចិន វិចិត្រ ហៅ ចិន សំអាន ។ នៅអំឡុងឆ្នាំ១៩៧០-៧៨ ប្អូនប្រុសរបស់ខ្ញុំគឺជាយុទ្ធជនរំដោះរបស់ភូមិភាគ២០៣ (បូព៌ា) ហើយក៏បាត់ខ្លួននៅឆ្នាំ១៩៧៨ដែរ ។ ប្រសិនបើបងប្អូនណាបានស្គាល់ ឬបានដឹងដំណឹងប្អូនទាំងពីរនេះ សូមទាក់ទងមកខ្ញុំបាទតាមលេខទូរស័ព្ទ ០១២ ៤១ ៩២ ២៨ ឬទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សូមអរគុណ ។



**សឺន** : បង្កើតឡើងនៅឆ្នាំ១៨៣៤ សឺននេះមានទីតាំងស្ថិតនៅលើច្រាំងទន្លេមេគង្គនៅក្នុងភូមិស្វាយឃ្លាំង ខេត្តកំពង់ចាម ។ ភូមិនេះធ្លាប់ជាបេះដូងនៃសហគមន៍ជនជាតិភាគតិចមូស្លីមជាច្រើនសតវត្សរ៍និងបានដើរតួនាទីជាផ្នែកមួយនៅក្នុងការបះបោររបស់ចាមប្រឆាំងនឹងខ្មែរក្រហមនៅឆ្នាំ១៩៧៥ ។ បន្ទាប់ពីទទួលការធ្វើទុកបុកម្នេញយ៉ាងព្រៃផ្សៃនិងជាប្រព័ន្ធដោយខ្មែរក្រហម សហគមន៍ចាមនៅក្នុងនិងនៅជុំវិញស្វាយឃ្លាំងបច្ចុប្បន្នមានមានភាពរឹងមាំឡើងវិញ ហើយបានស្នើជំនួយពីមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យជួយការពារវិមានវប្បធម៌ដ៏ពិសេសមួយនេះ ។ កាលពីមុនសឺនត្រូវបានយកមកប្រើប្រាស់ប្រាំដងក្នុងមួយថ្ងៃដើម្បីប្រកាសហៅជនជាតិមូស្លីមឲ្យមកចូលរួមសំពះយ៉ាំងនិងមើលព្រះច័ន្ទដើម្បីជាកំណត់ពីការចាប់ផ្ដើមនិងការបញ្ចប់នៃពិធីបុណ្យរ៉ាម៉ាដាន (រ៉ាម៉ាទន) ។ សំណង់របស់សឺនបានធ្លាក់ក្នុងសភាពទ្រុឌទ្រោម ហើយដោយសារតែសំណង់នេះមិនមានភាពរឹងមាំ យើងមិនអាចឡើងទៅកំពូលរបស់សឺនដើម្បីជួសជុលបានឡើយ ។ ភាពសឹករិចរិលនេះកាន់តែមានសភាពទ្រុឌទ្រោមដោយសារសំណឹកដែលបង្កឡើងដោយទឹកទន្លេមេគង្គដែលហូរនៅចម្ងាយ៥០ម៉ែត្រពីសឺន ។ អាស្រ័យហេតុនេះ វាមានសារសំខាន់ក្នុងការជួយឧបត្ថម្ភការជួសជុលសំណង់នេះនៅក្នុងរយៈពេលខ្លី និងខិតខំប្រឹងប្រែងអភិរក្សសឺននេះ ។ កិច្ចខំប្រឹងប្រែងនេះត្រូវបានតាក់តែងឡើងដើម្បីអភិរក្ស និងការពារសឺនរបស់ចាមមូស្លីមតែមួយគត់នៅក្នុងកម្ពុជា ។ ផ្ទះនៅជិតសឺនដែលមានអាយុជាងមួយរយឆ្នាំត្រូវបានប្រគល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីធ្វើការការពារ ។ យើងមានក្ដីសង្ឃឹមថាគម្រោងពីរនេះអាចជួយបង្កើតការចាប់អារម្មណ៍ទៅលើវប្បធម៌ចាមនិងអាចទាក់ទាញភ្ញៀវទេសចរណ៍មកភូមិប្រវត្តិសាស្ត្រមួយនេះផងដែរ ។

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 120, December 2009 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.